ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា  ព្រះមហាក្សត្រ

វិទ្យាស្ថាន

និក្ខេបបទ

ស្ថានភាពនៃការបង្រៀន  និងរៀនអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១២

ករណីសិក្សាខេត្តកំពង់ចាម

# Teaching and Studying Khmer Literature for grade 12 in Kampong Cham Province

ដោយ / By

សាម សុនិត

**SAM SONITH**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ   ជំនាន់ទី៦

ឯកទេស ៖   ការគ្រប់គ្រង  និងផែនការអប់រំ

ឆ្នាំសិក្សា ២០១៧ - ២០១៨

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថាន

និក្ខេបបទ

ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១២ ករណីសិក្សាខេត្តកំពង់ចាម

# Teaching and Studying Khmer Literature for grade 12 in Kampong Cham Province

**ដោយ** / By


សាម សុនិត

**SAM SONITH**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេសៈ ការគ្រប់គ្រង និងផែនការអប់រំ

ឆ្នាំសិក្សា២០១៧ - ២០១៨

# និក្ខេបបទ

# ស្ថានភាពនៃបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១២

## ករណីសិក្សា ៖ ខេត្តកំពង់ចាម

## Teaching and Studying Khmer Literature for grade 12

## in Kampong Cham Province


**ដោយ** / By

សាម សុនិត

**SAM SONITH**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ ការគ្រប់គ្រង និងផែនការអប់រំ**

**ឆ្នាំសិក្សា២០១៧ - ២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត ឈូក ច័ន្ទណាយា**

**សាស្ត្រាចារ្យជំនួយ៖ លោក គួយ សូគាន**


**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education (NIE)


គណៈកម្មការវាយតម្លៃនៃការការពារនិក្ខេបបទ

សម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

វិទ្យាស្ថានជាតិអប់រំ

# និក្ខេបបទ

# ស្ថានភាពនៃបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១២
# ករណីសិក្សា ៖ ខេត្តកំពង់ចាម

## Teaching and Studying Khmer Literature for grade 12 in Kampong Cham Province

និក្ខេបបទនេះ ត្រូវបានឯកភាពដោយ

(១). សាស្ត្រាចារ្យណែនាំ៖

បណ្ឌិត ឈូក ច័ន្ទឆាយា

(២). តំណាងវិទ្យាស្ថានជាតិអប់រំ៖

បណ្ឌិត សៀង សុវណ្ណា

(៣). តំណាងគណៈកម្មការវាយតម្លៃ៖

បណ្ឌិត ជ័យ សារិន

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា **ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១២ ករណីសិក្សា ៖ ខេត្តកំពង់ចាម** សម្រាប់បំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង ។

ស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានណាមួយនៅឡើយទេ។

ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ គឺពិតជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

សាម សុនិត

ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យដឹកនាំការសរសេរនិក្ខេបបទ
ស្រាវជ្រាវនេះ សូមបញ្ជាក់ថាបេក្ខជនឈ្មោះ សាម សុនិត
ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

ហត្ថលេខា សាស្ត្រាចារ្យដឹកនាំ

បណ្ឌិត ឈូក ច័ន្ទឆាយា


# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិ

អប់រំ និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា Cambodia International Education Support Foundation (CIESF) ដែលបានរៀបចំ និងផ្តល់នូវសិទ្ធិបង់ថ្លៃក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណអស់ពីចិត្តចំពោះបងប្អូន ភរិយា និងកូនស្រីរបស់ខ្ញុំបាទ ដែលអ្នកទាំងអស់គ្នា តែងតែជួយឧបត្ថម្ភលើការសិក្សា ផ្តល់កម្លាំងចិត្ត និងផ្តល់នូវភាពកក់ក្តៅដល់រូបខ្ញុំគ្រប់ពេលវេលា ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា ដោយមិនគិតពីការលំបាក និងពេលវេលាដ៏មានតម្លៃឡើយ ។ ជាពិសេសជាងនេះទៅទៀតនោះ ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យបណ្ឌិត ឈូក ច័ន្ទឆាយា ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីពន្យល់ណែនាំ ដល់រូបខ្ញុំគ្រប់ជំហាន ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវ របស់ខ្ញុំនាពេលនេះ ទទួលបានជោគជ័យ និងបញ្ចប់ប្រកបដោយភាពរលូន ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យដឹកនាំរង **គួយ សូគាន** ដែលតែងតែផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង និងចែករំលែកបទពិសោធដល់រូបខ្ញុំទាំងការសិក្សាស្រាវជ្រាវ ទាំងក្នុងអំឡុងពេលសិក្សា ។ ជាមួយគ្នានេះដែរខ្ញុំសូមថ្លែងអំណរគុណដល់មិត្តរួមថ្នាក់រួមជំនាន់ទី៦ទាំងអស់ ដែលតែងតែចែករំលែកចំណេះដឹង បទពិសោធ និងព័ត៌មានទាំងឡាយ ដែលធ្វើឱ្យរូបខ្ញុំបាទមានមោទនភាពយ៉ាងខ្លាំង ដែលមានមិត្តល្អៗបែបនេះ ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលាគោលដៅទាំង១៤ ដែលបានអនុញ្ញាត និងចូលរួមសហការក្នុងអំឡុងពេលដំណើរការប្រមូលទិន្នន័យដែលធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះអ្នកទាំងអស់គ្នា សូមមានសុខភាពល្អបរិបូណ៌ ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការស្រាវជ្រាវមួយនេះមានបំណងស្វែងរក និងបង្ហាញឱ្យឃើញពីស្ថានភាពជាក់ស្តែងនៃការបង្រៀនអក្សរសាស្ត្រខ្មែររបស់គ្រូអក្សរសាស្ត្រខ្មែរនៅថ្នាក់ទី១២ និងបញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរនៅសាលារដ្ឋសព្វថ្ងៃ ជាពិសេសនៅក្នុងខេត្តកំពង់ចាមតែម្តង ។

វិធីសាស្ត្រដែលអ្នកសិក្សាស្រាវជ្រាវយកមកប្រើ ដើម្បីប្រមូលទិន្នន័យនោះគឺវិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Method) និងវិធីសាស្ត្របែបគុណវិស័យ (Qualitative Method) ។ ក្នុងការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរបែបពហុជ្រើសរើសសម្រាប់សួរគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស រីឯវិធីសាស្ត្របែបគុណវិស័យវិញ អ្នកស្រាវជ្រាវចងក្រងជាកម្រងសំណួរបែបសំណួរបើក សម្រាប់ឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្សបំពេញលើបញ្ហាប្រឈម និងដំណោះស្រាយបញ្ហានានា ដើម្បីទទួលបាននូវព័ត៌មានបន្ថែមសម្រាប់គាំទ្រដល់ចម្លើយមួយចំនួននៅក្នុងកម្រងសំណួរបែបបរិមាណវិស័យ។ ធាតុសំណាកដែលបានចូលរួមនៅក្នុងការស្រាវជ្រាវ ត្រូវបានជ្រើសរើសយកចេញពីវិទ្យាល័យចំនួន១៤ ក្នុងក្រុង០១ និងស្រុក០៥ ផ្សេងៗគ្នា ក្នុងខេត្តកំពង់ចាម (០២វិទ្យាល័យ នៅក្រុងកំពង់ចាម និង ១២វិទ្យាល័យទៀតនៅតាមស្រុកចំនួន ០៥) ។ ធាតុសំណាកទាំងអស់មានចំនួន ១៣៣៨ នាក់ ដោយក្នុងនោះមានគណៈគ្រប់គ្រងសាលារៀនចំនួន ១៤នាក់ គ្រូបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចំនួន ២៤នាក់ និងសិស្សានុសិស្សថ្នាក់ទី១២ ចំនួន ១៣០០នាក់ ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ស្ថានភាពជាក់ស្តែងទាក់ទងទៅនឹងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ មានភាពល្អប្រសើរច្រើន ដោយក្នុងនោះគ្រូបង្រៀនរហូតដល់ទៅ ៩១.៧០% ដែលបង្រៀននៅថ្នាក់ទី១២ មានក្របខណ្ឌជាគ្រូបង្រៀនកម្រិតឧត្តម និង ៩៥.៨០% មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ។ ជាងនេះទៅទៀត លោកគ្រូ អ្នកគ្រូ ចំនួន ៦២.៥០% តែងតែធ្វើកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការបង្រៀន ជាប្រចាំ ព្រមជាមួយទម្លាប់ល្អក្នុងការដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែលម្អលើកិច្ចការសិស្ស បានដល់ទៅ ៩១.៧០% ការវាយតម្លៃក្នុងពេល និងក្រោយការបង្រៀនមេរៀនចប់ បាន ៨៧.៥០% និងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានល្អប្រសើរ ដល់ទៅ ៩១.៧០% នៅក្នុងពេលបង្រៀន និងរៀន ។

ចំណែកឯសិស្សានុសិស្សវិញ ក៏មានចំណាប់ចំណូលចិត្តចូលចិត្តរៀន និងមករៀនម៉ោងអក្សរសាស្ត្រខ្មែរបានយ៉ាងល្អប្រសើរ ក្នុងនោះ សិស្ស ៩១.៧០ % បានមករៀនទៀងទាត់ តាម

ម៉ោងចេញ និងម៉ោងចូល សិស្ស ៧៩.៨០ % ចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ គួបផ្សំនឹងការយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់មេរៀនបានដល់ទៅ ៨៧.៦០% ។

ទាក់ទងនឹងការងារដឹកនាំ និងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀនវិញ ក៏បានបង្ហាញលទ្ធផលវិជ្ជមានមួយចំនួនផងដែរ ដូចជា ការបែងចែកគ្រូបង្រៀនតាមឯកទេសវិជ្ជាជីវៈ ការគ្រប់គ្រងម៉ោងចេញ ម៉ោងចូលរបស់បុគ្គលិក មានចំនួន ៨៥.៧០% ព្រមជាមួយនឹងការរៀបចំបរិស្ថាន សោភណភាព និងអនាម័យសាលារៀន ឱ្យក្លាយជាសាលាកុមារមេត្រី ដើម្បីទាក់ទាញអារម្មណ៍សិស្សក្នុងការសិក្សា មានចំនួន ៩២.៨០% ជាពិសេស ការចូលរួមក្នុងការតាមដានលទ្ធផលនៃការសិក្សារបស់សិស្ស ការលើកទឹកចិត្តគ្រូបង្រៀន ក្នុងការប្រើប្រាស់នូវវិធីសាស្ត្រថ្មីៗ និងការរៀបចំប្រឡងសិស្សពូកែមុខវិជ្ជាអក្សរសាស្ត្រខ្មែរ សម្រាប់ទាក់ទាញសិស្សឱ្យចូលប្រឡងសិស្សពូកែឱ្យបានច្រើន ។

ទន្ទឹមនឹងចំណុចវិជ្ជមានខាងលើ ក្នុងនោះក៏មានចំណុចខ្វះខាតមួយចំនួនដែលជាបញ្ហាប្រឈមទាមទារឱ្យមានដំណោះស្រាយផងដែរ។ បញ្ហាទាំងនោះរួមមានដូចជាកង្វះសម្ភារៈសម្រាប់ទ្រទ្រង់ចាំបាច់ សម្រាប់ការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរមួយចំនួន រួមមានម៉ាញ៉េចាក់កាសែត ឬស៊ីឌី សម្រាប់បង្រៀនលើអត្ថបទស្តាប់ ការប្រើប្រាស់ស្លាយ LCD សម្រាប់ចាក់ជាវីដេអូបញ្ចាំងស្នាដៃរឿងអក្សរសិល្ប៍ ឱ្យសិស្សបានមើលជាក់ស្តែង ដោយសារទិន្នន័យដែលទទួលបានបានបង្ហាញថា គ្រូបង្រៀនដែលបានផលិតសម្ភារៈឧបទេសបង្រៀនជាប្រចាំ មានត្រឹមតែ ៣៧.៥០% និងគ្រូបង្រៀនដែលបានប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បង្រៀន ជាប្រចាំ មានត្រឹមតែ ៣៣.៣០% តែប៉ុណ្ណោះ ។

ក្រៅពីនេះ សកម្មភាពក្លឹបសិក្សារបស់សិស្សមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អនៅតាមវិទ្យាល័យ នៅមានកម្រិតទាបនៅឡើយ ដោយលទ្ធផលបានបង្ហាញថា មានសិស្សត្រឹមតែ ១៦.៧០%ប៉ុណ្ណោះ ដែលតែងតែចូលរួមជាប្រចាំក្នុងសកម្មភាពក្លឹបសិក្សាលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ។ រីឯការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលក៏នៅមានកម្រិតទាបនៅឡើយដែរ ដោយសិស្សានុសិស្សភាគច្រើនបានវាយតម្លៃលើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមតែ ៣០% ប៉ុណ្ណោះ ដែលអនុវត្តបានល្អប្រសើរ ។

ម្យ៉ាងវិញទៀត ការរៀបចំធ្វើថ្នាក់និទស្សន៍ជាប្រចាំនៅតាមវិទ្យាល័យ ក៏ជាបញ្ហាប្រឈមផងដែរ ដោយទិន្នន័យបានបង្ហាញថា ការរៀបចំដឹកនាំធ្វើថ្នាក់និទស្សន៍ ដើម្បីអភិវឌ្ឍនូវសមត្ថភាពរបស់គ្រូបង្រៀននៅមានចំនួនតិចតួចនៅឡើយ ត្រឹមតែចំនួន ២៨.៥០% ប៉ុណ្ណោះ ដែលបានរៀបចំធ្វើថ្នាក់និទស្សន៍ និងប្រជុំបច្ចេកទេសជាប្រចាំ បានល្អប្រសើរ ។

## Abstract

The research is aimed at finding out and revealing the true state of things Teaching Khmer language teachers in grade 12 and the challenges related to teaching and learning Khmer literature at public schools today, especially in Kampong Cham.

The method that the researchers used to collect the data was the method Quantitative Method and Qualitative Method ). In quantitative research, the field of study used a multiple - choice questionnaire for school administrators, teachers, and students, while a qualitative approach, the researcher compiles a questionnaire open to school administrators, teachers, and students fill in the challenges and solutions to get more information to support some of the answers in the quantitative questionnaire. The sample participants participated in the study were recruited from 14 high schools in one city and five different districts in Kampong Cham ( two high schools in Kampong Cham and 12 high schools in five districts ). The total sample consisted of 1338 students, including 14 school administrators, 24 grade 12 Cambodian literacy teachers, and 1,300 12th grade students.

The results of this study suggest that the real situation is related The teaching and learning of Khmer literature in grade 12 has improved significantly, with 91.70% of teachers in grade 12 have a high school teacher qualification and 95.80% have a diploma. From undergraduate level. In addition, 62.50% of teachers are committed to teaching and teaching on a regular basis with a good routine of assigning student tasks and improving student affairs. 70% evaluation during and after the lesson

Was 87.50% and the Center's student performance was 91.70% better during teaching and learning.

Whereas, students are also more motivated to study and study Khmer literature better, of which 91.70% of students are in regular attendance and 74.80% prefer to study Khmer literature. Combined with listening, the teacher explained 87.60% of the lessons.

In terms of school management and leadership, the school has also shown some positive results, such as the distribution of teachers by specialties 85.70% of staff are out of office with 92.80% of all children participating in the study having the environment, beauty and hygiene, they are especially interested in monitoring student learning outcomes. Utilize new methods and prepare students for outstanding Khmer literature for students as many outstanding students.

Along with the above positive points, there are some shortcomings that are a problem Challenges demand solutions too. Issues include the lack of necessary support material for teaching and learning some of the Khmer literature, including magnetic, tape, or CD for teaching text, using LCD slides for video streaming of student literature, the data obtained shows that 37.5% of teachers who make regular teaching materials and teachers who use teaching materials regularly have Only 33.30%. Also, internal inspection Low levels of schools have yet to fully respond to improving the quality of education - just 46%

In addition, the number of students working in the Khmer literature class and the club performance of the high school was low, with only 16.70% of students attending regular club activities. In Khmer literature.

Also, teaching center methodology is still low, with most students evaluating teachers 'teaching using only 30% of students' core curriculum. Better.

On the other hand, preparing for a regular classroom in high school is also a challenge, as the data suggests that preparing for a virtual Classroom for developing Teacher capacity is still small at 28.50% better organized regular classes and technical meetings.

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ប្រទេសនីមួយៗនៅលើពិភពលោក តែងតែខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ខ្លាំងទៅលើការផលិតធនធានមនុស្ស ដើម្បីធានានូវការអភិវឌ្ឍប្រទេស ប្រកបទៅដោយនិរន្តរភាព ភាពសុខដុមរមនា និងចិរភាព។ ក្នុងនោះ វិស័យអប់រំ មានកាតព្វកិច្ចយ៉ាងចម្បងក្នុងការបង្កើត និងធ្វើឱ្យប្រទេសមានការរីកលូតលាស់លើគ្រប់វិស័យទៅមុខជានិច្ច ពីព្រោះការអប់រំគឺជាកាតាលីករដ៏ចម្បងបំផុត ក្នុងការបំពេញនូវធនធានមនុស្សដែលពោរពេញទៅដោយចំណេះដឹង ជំនាញឯកទេស និងឥរិយាបថ ក្រមសីលធម៌ពេញលេញ សក្តិសមជាធនធានដ៏មានសក្តានុពល ដែលជាតម្រូវការរបស់ប្រទេសទាំងនោះ។ ការលើកកម្ពស់វិស័យអប់រំរបស់ពិភពលោក នៅតែបន្តឥតឈប់ឈរដោយឆ្លុះបញ្ចាំងតាមរយៈចក្ខុវិស័យឆ្ពោះទៅរកឆ្នាំ២០៣០ និងផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរជីវិតឱ្យប្រសើរឡើង តាមរយៈការអប់រំដោយមិនប្រកែកបាន ពីតួនាទីសំខាន់នៃការអប់រំថាជាវិស័យចម្បងនៃការអភិវឌ្ឍ និងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្រោមពាក្យស្លោកថា " ធានាឱ្យបាននូវការអប់រំដែលមានគុណភាព បរិយាប័ន្ន សមធម៌ រួមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា **"វិស័យអប់រំ ឆ្នាំ២០៣០ អង្គការយូណេស្កូ ឆ្នាំ២០១៥** " ។

ដើម្បីឆ្លើយតបទៅនឹងនិន្នាការពិភពលោកដែលកំពុងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់វិស័យអប់រំនោះ សមាគមអាស៊ានក៏បានកំណត់ចក្ខុវិស័យរបស់ខ្លួនដោយជំរុញប្រទេសនីមួយៗនៅក្នុងតំបន់ដែលជាសមាជិក ឱ្យខិតខំធ្វើការកំណែទម្រង់លើគ្រប់វិស័យដើម្បីឱ្យមានកម្រិតស្តង់ដាប្រហាក់ប្រហែលគ្នារវាងប្រទេសជាសមាជិកទាំងអស់ តាមរយៈការធ្វើសមាហរណកម្មអាស៊ាននៅឆ្នាំ២០១៥។ ក្នុងនោះវិស័យអប់រំ ជាវិស័យអាទិភាពមួយដែលប្រទេសទាំងអស់ក្នុងតំបន់ជាសមាជិកត្រូវធានាលើកកម្ពស់គុណភាពអប់រំ របស់ខ្លួនធ្វើយ៉ាងណារៀបចំប្រជាពលរដ្ឋរបស់ខ្លួនឱ្យក្លាយទៅជាធនធានមនុស្ស ដែលប្រកបដោយចំណេះដឹងជំនាញឯកទេស និងក្លាយទៅជាកម្មករជំនាញ ។

ដោយផ្អែកលើបរិបទពិភពលោក និងប្រទេសក្នុងតំបន់ដែលផ្តោតការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជានៅក្នុងអាណត្តិទី៦នេះបានផ្តល់អាទិភាពទី១ទៅលើការអភិវឌ្ឍធនធានមនុស្សទៅក្នុងយុទ្ធសាស្រ្តចតុកោណរបស់ខ្លួននេះ ក៏ព្រោះតែកម្ពុជាក៏មាន

មហិច្ឆតាចង់ប្រែក្លាយខ្លួនឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ " **យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៣** " ។

មកដល់សម័យកាលសាកលភាវូបនីយកម្ម ភាសា និងអក្សរសាស្ត្រខ្មែរក៏បានដើរតួនាទីសំខាន់ ក្នុងការចូលរួមចំណែកក្នុងការអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ ពីព្រោះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ ហើយរដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរ ឱ្យសមស្របតាមតម្រូវការ ។ បច្ចុប្បន្ននេះ តម្រូវការនៃការប្រើប្រាស់ភាសា និងអក្សរសាស្ត្រខ្មែរមានការកើនឡើងខ្ពស់ផងដែរ ជាពិសេស ក្នុងវិស័យពាណិជ្ជកម្ម ទេសចរណ៍ បរិស្ថាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ។ល។ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងលឿននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា សង្គម និងសេដ្ឋកិច្ច " **គោលនយោបាយជាតិស្តីពីភាសាខ្មែរ ឆ្នាំ២០១៩ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ឆ្នាំ២០១៩** " ។

ដើម្បីសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមធ្វើកំណែទម្រង់វិស័យអប់រំ ដោយដាក់ចេញយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំរយៈពេល ៥ឆ្នាំ (២០១៨ - ២០២៣) និងផ្តោតសំខាន់ទៅលើការអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហ ដោយពង្រឹងគុណភាពអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា " **យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨ ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា ខែវិច្ឆិកា ឆ្នាំ២០១៨** " ។ ស្របពេលជាមួយគ្នានេះដែរ ក្រសួងបានដាក់ចេញនូវផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ដែលជាកំណែទម្រង់យ៉ាងហ្មត់ចត់ និងមានលក្ខណៈជាប្រព័ន្ធ ដោយបានបង្កើតឡើងដើម្បីបង្កើនគុណភាពអប់រំទូទាំងប្រទេស។ ដើម្បីឱ្យគុណភាពអប់រំកាន់តែប្រសើរឡើង យើងចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការសិក្សាភាសាខ្មែរ ដែលជាហេតុនាំឱ្យក្រសួងអប់រំយុវជន និងកីឡាបានកំណត់យុទ្ធសាស្ត្រលើកកម្ពស់ការសិក្សាអក្សរសាស្ត្រខ្មែរផងដែរ ។ មានកត្តាចំនួនពីរដែលជំរុញឱ្យមានការសិក្សាលើអក្សរសាស្ត្រខ្មែរ គឺកត្តាអភិរក្សនូវកេរមត៌កវប្បធម៌ជាតិ និងកត្តាអភិវឌ្ឍនូវចំណេះដឹង ដើម្បីធ្វើទំនើបកម្មឱ្យទាន់សម័យកាលរីកចម្រើន ។

ដោយមើលឃើញពីសារៈសំខាន់នៃការប្រើប្រាស់ភាសាខ្មែរ ទើបក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ការរៀន និងបង្រៀនអក្សរសាស្ត្រខ្មែរ តាមរយៈការកែប្រែកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ និងសៀវភៅសិក្សាគោលផងដែរ ។

## ១.២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

បន្ទាប់ពីការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាទៅលើចំណុចអាទិភាពទាំង១៥ និងសសរស្តម្ភទាំង៥ ជាពិសេសទៅលើការបង្រៀន ការរៀន និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីធ្វើឱ្យគុណភាពអប់រំបានល្អប្រសើរឡើងរួចមក យើងសង្កេតឃើញថាសិស្សភាគច្រើនបានកែប្រែឥរិយាបថ ដោយខិតខំប្រឹងប្រែងរៀនសូត្រគួរឱ្យកត់សម្គាល់ ។ ការលើកឡើងបែបនេះ គឺដោយផ្អែកទៅលើលទ្ធផលការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលមានអត្រាសិស្សជាប់ពី៤៤% នៅឆ្នាំ២០១៤ ទៅ ៥៥,៨៨% នៅឆ្នាំ២០១៥ និង ៦២,១៨% នៅឆ្នាំ២០១៦ ទៅ ៦៣.៨៤% នៅឆ្នាំ២០១៧ ទៅ ៦៧,០៧% នៅឆ្នាំ២០១៨ និង ៦៨.៦២% នៅក្នុងឆ្នាំ២០១៩ ។ ទន្ទឹមនឹងនេះលទ្ធផលប្រឡងរបស់សិស្សលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរក៏នៅមានកម្រិតនៅឡើយ ពោលគឺមិនទាន់ឆ្លើយតបតាមការចង់បានរបស់លោកគ្រូ អ្នកគ្រូ ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។ លទ្ធផលនេះបង្ហាញថា ការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ របស់សិស្សនៅមធ្យមសិក្សានៅមានចំណុចខ្វះខាតនៅឡើយ។ កត្តាមួយចំនួន គឺអាចនឹងចាប់ផ្តើមតាំងពីមធ្យមសិក្សាបឋមភូមិក៏មានដែរ ដែលជាហេតុបន្តរហូតទៅដល់មធ្យមសិក្សាទុតិយភូមិ។ ក្រៅពីនេះទៀត តាមការសង្កេត ពិភាក្សា និងសម្ភាសរបស់អ្នកសិក្សាស្រាវជ្រាវ ជាមួយគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ បង្រៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ផ្ទាល់ ឃើញថាសិស្សនៅក្នុងកម្រិតថ្នាក់នេះ មិនសូវបានខិតខំព្យាយាមរៀនសូត្រមុខវិជ្ជាអក្សរសាស្ត្រខ្មែរឱ្យបានខ្លាំងក្លានៅឡើយទេ ជាពិសេស នៅតាមសាលារបស់រដ្ឋ ។

## ១. ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ដោយសារមានចម្ងល់ពាក់ព័ន្ធទៅនឹងគុណភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅសាលារដ្ឋនាពេលបច្ចុប្បន្ននេះហើយ ទើបធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវសម្រេចចិត្តជ្រើសរើសយកបញ្ហានេះមកធ្វើជាប្រធានបទស្រាវជ្រាវ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ខ្លួន។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗពីរគឺ៖

១. សិក្សាពីស្ថានភាពនៃការដឹកនាំ គ្រប់គ្រង ការបង្រៀន ការរៀន និងបញ្ហាប្រឈមនានា ដែលបានជួបប្រទះក្នុងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២
២. សិក្សាពីវិធានការដោះស្រាយនូវបញ្ហាប្រឈមនានា ក្នុងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ អ្នកសិក្សាស្រាវជ្រាវបានលើកយកនូវ

សំណួរស្រាវជ្រាវចំនួនពីរគឺ៖

១. តើការដឹកនាំ និងគ្រប់គ្រង បានជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះចំពោះការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ?

២. តើមានវិធានការដូចម្តេចខ្លះដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានាដែលអ្នកស្រាវជ្រាវបានរកឃើញ នៅក្នុងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ?

## ១.៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ពីព្រោះវានឹងបង្ហាញឱ្យឃើញនូវបញ្ហាប្រឈមមួយចំនួនសម្រាប់ជួយដល់គ្រូក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលា និងកែលម្អគុណភាព ប្រសិទ្ធភាពនៃការរៀន និងបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយ និងបន្តពង្រឹងវិស័យអប់រំរបស់រដ្ឋ ឱ្យរឹតតែមានប្រសិទ្ធភាពខ្ពស់ជាងបច្ចុប្បន្ននេះទៀត។ ការស្រាវជ្រាវនេះនឹងផ្តល់ជារបកគំហើញថ្មីមួយសម្រាប់ចូលរួមវិភាគទានដល់អ្នកសិក្សាជំនាន់ក្រោយៗ ការស្រាវជ្រាវបន្តទៅទៀតទៅលើប្រធានបទនេះ។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានសម្រេចជ្រើសរើសយកខេត្តកំពង់ចាម សម្រាប់ធ្វើការស្រាវជ្រាវនេះ ពីព្រោះតែខេត្តនេះជាខេត្តធំ មានការរីកចម្រើនខ្លាំងទាំងផ្នែកសេដ្ឋកិច្ច ការអប់រំ និងទីផ្សារការងារ ដូច្នេះការរៀន និងបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ នៅក្នុងខេត្តនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ជួយលើកកម្ពស់ជីវភាព និងផលិតកម្លាំងពលកម្មឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ។ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានតម្លៃ និងស៊ីជម្រៅគ្រប់ជ្រុងជ្រោយ អ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសយក គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ និងសិស្សថ្នាក់ទី១២ ចេញពីវិទ្យាល័យចំនួន១៤ នៅក្នុងខេត្តកំពង់ចាម (០២វិទ្យាល័យនៅក្នុងក្រុងកំពង់ចាម និង ១២វិទ្យាល័យទៀត ជាសាលារៀននៅតាមស្រុកចំនួន ០៥ មកធ្វើជាសំណាកក្នុងការស្រាវជ្រាវ) ។ ក្នុងនោះសិស្សចំនួន ១៣០០ នាក់ និងគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចំនួន ២៨នាក់ ត្រូវជ្រើសរើសឱ្យបំពេញកម្រងសំណួរដាច់ដោយឡែកពីគ្នា ដែលរៀបចំឡើងដោយអ្នកសិក្សាស្រាវជ្រាវ ។ ក្រៅពីនេះ គណៈគ្រប់គ្រងសាលារៀនចំនួន ១៤ នាក់ទៀត នៃវិទ្យាល័យគោលដៅនីមួយៗ ក៏ត្រូវបានអញ្ជើញឱ្យបំពេញកម្រងសំណួរ ឆ្លើយជាសំណួរទម្រង់បើក និងឆ្លើយតាមរយៈការសម្ភាសផ្ទាល់មាត់បន្ថែមទៀត ។

## ១.៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

**ជំពូកទី២៖** រំឭកទ្រឹស្តី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះ ដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ និងប្រភេទគំរូ ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម ។

**ជំពូកទី៤៖** លទ្ធផលនៃការសិក្សាស្រាវជ្រាវ នៅក្នុងជំពូកនេះ អ្នកសិក្សា ស្រាវជ្រាវនឹងបង្ហាញនូវទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ តាមរយៈការប្រើប្រាស់កម្មវិធីវិភាគស្ថិតិ និងសង់តារាងលទ្ធផលជាក់ស្តែងដែលទទួលបានពីកម្រងសំណួរ ។

**ជំពូកទី៥៖** ការពិភាក្សា សន្និដ្ឋាន និងសំណូមពរ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវ នឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អ នៅក្នុងស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ។ បន្ទាប់មកទៀត អ្នកសិក្សាស្រាវជ្រាវ ត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងផ្តល់ជាសំណូមពរ មួយចំនួនក្នុងបំណងចូលរួមចំណែកធ្វើឱ្យស្ថានភាពបង្រៀន និងរៀនប្រសើរឡើងថែមទៀត។

# ជំពូកទី២
# រំឭកទ្រឹស្តី

## ២.១. និយមន័យពាក្យគន្លឹះ

តើការបង្រៀន និង រៀន គឺជាអ្វី?

**ការបង្រៀន ៖** ជាការញុំាងអ្នកដទៃឱ្យរៀន ប្រៀនឱ្យចេះ ឱ្យមានចំណេះ ដោយការបង្ហាត់ និងបង្ហាញឱ្យចេះ " **វចនានុក្រមខ្មែរ ភាគ១ និងភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧** " ។

**ការបង្រៀន** ៖ ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្ត ឱ្យចេះរៀនដោយខ្លួនឯង ពង្រឹង និងពង្រីកចំណេះដឹង បទពិសោធ ដល់សិស្សគ្រប់រូប ។ សកម្មភាពនៃការបង្រៀនរួមមាន ការពន្យល់ ការដាក់ចំណោទ ការសួររកហេតុ និង ផល ការសួរសំណួរ ការលើកទឹកចិត្ត ការតាមដានសាវតាររបស់សិស្ស ការប្រឡង ឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីមានចិត្ត គរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដទៃទៀតដែរ ចាំបាច់ត្រូវតែបន្តស្រាវជ្រាវរកអ្វីដែលថ្មី អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ " **នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ឆ្នាំ២០១៥** " ។

**ការរៀន ៖** មានន័យថា សិក្សា ខំសង្កេតឱ្យចេះ ទទួលយកចំណេះ ហាត់ ហ្វឹក ដោយទន្ទេញស្វាធ្យាយឱ្យចងចាំ " **វចនានុក្រមខ្មែរ ភាគ១ និងភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧** " ។

**ការរៀន៖** គឺជាទង្វើនៃការទទួលបានអ្វីដែលថ្មី ឬការកែប្រែ និងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិន គុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធនឹងការសំយោគព័ត៌មានប្រភេទផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់ " **នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ឆ្នាំ២០១៥** " ។

## ២.២. លក្ខណវិនិច្ឆ័យនៃនាយក - នាយិកាសាលារៀនល្អ

តាមរយៈឧបករណ៍វាយតម្លៃនាយក - នាយិកាសាលារៀនល្អ ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ៧៦១ អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ បានបង្ហាញយ៉ាងច្បាស់ពីលក្ខណវិនិច្ឆ័យនៃនាយក - នាយិកាសាលារៀនល្អ ដែលមានសូចនាករគោលចំនួន ១១ សមាសភាគ ដូចជា ៖

**១. គុណវុឌ្ឍិ** ជាលក្ខណវិនិច្ឆ័យនៃការវាយតម្លៃ ដោយគិតលើកម្រិតសញ្ញាបត្រដែលនាយក - នាយិកា បានទទួលនៅក្នុងក្របខណ្ឌ ក្នុងពេលបំពេញការងាររបស់ខ្លួន ។

២. **សមត្ថភាពជំនាញ** សំដៅលើការយល់ដឹងពីគោលនយោបាយអប់រំ ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការដឹកនាំ គ្រប់គ្រង សម្របសម្រួល ច្នៃប្រតិដ្ឋ ការងារអធិការកិច្ច ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យា ភាសាបរទេស ប្រវត្តិ និងបទពិសោធក្នុងការងារ ការអភិវឌ្ឍស្ថាប័ន ជំនាញវិភាគ និងការបកស្រាយព័ត៌មាន ការលើកទឹកចិត្តសិស្ស គ្រូ និងបុគ្គលិកអប់រំឱ្យចូលរួមក្នុងសកម្មភាពអប់រំជាប្រចាំ ។

៣. **ការរៀបចំផែនការ** សំដៅលើចក្ខុវិស័យ បេសកកម្ម គោលបំណងច្បាស់លាស់ ការរៀបចំផែនការដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ការអនុវត្តការងារប្រកបដោយគុណតម្លៃ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍ និងផែនការអភិវឌ្ឍន៍សាលារៀន ។

៤. **ការដឹកនាំការរៀន និងបង្រៀន** សំដៅលើការផ្តួចផ្តើម និងការគាំទ្រក្រុមបច្ចេកទេស ការត្រួតពិនិត្យ និងការវាយតម្លៃការរៀន និងការបង្រៀនជាប្រចាំ ការបំប៉នវិធីសាស្ត្រ និងផ្តល់ប្រឹក្សាបច្ចេកទេសដល់គ្រូបង្រៀន ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន ការប្រើវិធីសាស្ត្រដោយមានភាពឆ្លើយតប និងមានភាពច្នៃប្រតិដ្ឋសម្រាប់ការរៀន និងការបង្រៀន ការលើកទឹកចិត្ត និងការធ្វើការជាក្រុមដើម្បីបង្កើតវប្បធម៌ចែករំលែក និងធានាឱ្យមានសម្ភារៈសិក្សា និងសម្ភារៈឧបទេស ។

៥. **ការអភិវឌ្ឍខ្លួនឯង** សំដៅលើការកសាងវប្បធម៌សហការ និងការចូលរួម ពង្រឹងអភិបាលកិច្ចល្អ ស្វ័យវាយតម្លៃ ការបន្តអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ខ្លួនឯង និងគ្រូបង្រៀន ការច្នៃប្រតិដ្ឋ និងការបង្កើតថ្មីដើម្បីឧត្តមភាពការងារ ។

៦. **ការគ្រប់គ្រងសាលារៀន** សំដៅលើការរៀបចំរចនាសម្ព័ន្ធ និងបំណែងចែកភារកិច្ច ការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ការរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប ការរៀបចំបរិស្ថានសាលារៀនល្អ អនាម័យស្អាត ឯកសណ្ឋានសិស្ស គ្រូ ការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាក្នុងដំណើរការគ្រប់គ្រងសាលារៀន និងធានាសុវត្ថិភាពគ្រូបង្រៀន និងសិស្ស ។

៧. **ការធានាគណនេយ្យភាព** សំដៅលើការគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ការឆ្លើយតបទៅនឹងព័ត៌មានទាន់ពេលវេលា ការប្រមូល និងប្រើប្រាស់នូវទិន្នន័យដើម្បីវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយរបស់សាលារៀន ការផ្តួចផ្តើមអភិវឌ្ឍអភិក្រមចំណាយដោយផ្អែកលើលទ្ធផលបំពេញការងារ ការបិទផ្សាយលទ្ធផល

សិក្សារបស់សិស្សដោយតម្លាភាព ការរៀបចំកិច្ចបញ្ជិកាគណនេយ្យហិរញ្ញវត្ថុ បញ្ជីសារពើភណ្ឌ និងបញ្ជីគ្រប់គ្រងវត្តមានបុគ្គលិកបានត្រឹមត្រូវ ការបិទផ្សាយតារាងតម្លាភាពហិរញ្ញវត្ថុ សម្ភារៈទ្រព្យសម្បត្តិ និងមន្ត្រីអប់រំ ។

៨. **ការពង្រឹងទំនាក់ទំនងជាមួយសហគមន៍** សំដៅលើការផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ ការបង្កើត និងរក្សាស្នាដៃសិស្សដើម្បីជំរុញឪពុកម្ដាយ និងសហគមន៍ឱ្យចូលរួមឧបត្ថម្ភ និងគាំទ្រ ការបង្កើតមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និងការផ្ដល់ព័ត៌មានត្រឡប់ជាប្រព័ន្ធដល់សិស្ស គ្រូ មាតាបិតា និងសាលារៀន ។

៩. **ក្រមសីលធម៌វិជ្ជាជីវៈ** សំដៅលើការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ ការពង្រឹងសាមគ្គីភាព និងការទទួលខុសត្រូវ ការគោរពវិន័យការងារ សីលធម៌រស់នៅល្អ គុណធម៌ និងយុត្តិធម៌ ។

១០. **លទ្ធផលគ្រប់គ្រង** សំដៅលើគ្រូបង្រៀនយល់ដឹងកម្មវិធីសិក្សាតាមកម្រិតថ្នាក់ គ្រូបង្រៀនមានសមត្ថភាពលើវិធីសាស្ត្រ និងបច្ចេកទេសបង្រៀន និងរៀនតាមមុខវិជ្ជាបានត្រឹមត្រូវ អត្រាសិស្សបោះបង់ការសិក្សាទាបជាង ឬស្មើថ្នាក់ជាតិ បរិស្ថានសិក្សាកុមារមេត្រី អត្រាសិស្សឡើងថ្នាក់ស្មើ ឬខ្ពស់ជាងថ្នាក់ជាតិ សិស្សមានសមត្ថភាពសមនឹងកម្រិតថ្នាក់ ការផ្គត់ផ្គង់ និងថែរក្សាសៀវភៅសិក្សាគោល ។

១១. **ការអភិវឌ្ឍយុវជន** សំដៅលើរចនាសម្ព័ន្ធ និងកិច្ចដំណើរការក្រុមប្រឹក្សាកុមារ យុវជន ក្លឹបសិក្សាយ៉ាងតិចមួយ ក្នុងកងកាយរឹទ្ធិមួយ សកម្មភាពសង្គមដែលបានជំរុញ ឬសម្របសម្រួល ឬដឹកនាំ សកម្មភាពបណ្ដុះបណ្ដាលកុមារ យុវជន និងការបូកសរុប និងវាយតម្លៃការងារក្រុមប្រឹក្សាកុមារ យុវជន ។

## ២.៣. លក្ខណវិនិច្ឆ័យនៃគ្រូបង្រៀនល្អ

តាមរយៈឧបករណ៍វាយតម្លៃគ្រូបង្រៀនល្អ ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសលេខ ៧៦១ អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ បានបង្ហាញយ៉ាងច្បាស់ពីលក្ខណវិនិច្ឆ័យនៃគ្រូបង្រៀនល្អ ដែលមានសូចនាករគោលចំនួន ៩ សមាសភាគ ដូចជា ៖

១. **គុណវុឌ្ឍិ** ជាលក្ខណវិនិច្ឆ័យនៃការវាយតម្លៃ ដោយគិតលើកម្រិតសញ្ញាបត្រដែលគ្រូបង្រៀនបានទទួលនៅក្នុងក្របខណ្ឌ ក្នុងពេលបំពេញការងាររបស់ខ្លួន ។

២. **សមត្ថភាពជំនាញ** សំដៅលើការយល់ដឹងពីគោលនយោបាយអប់រំ ការដឹកនាំ និង គ្រប់គ្រង សម្របសម្រួល ច្នៃប្រតិដ្ឋ សមត្ថភាពជំនាញក្នុងការបង្រៀន ចំណេះដឹង មូលដ្ឋានផ្នែកព័ត៌មានវិទ្យា ភាសាបរទេស ប្រវត្តិ និងបទពិសោធក្នុងការបង្រៀន ជំនាញវិភាគ និងការបកស្រាយព័ត៌មាន ការបង្រៀនថ្នាក់និទស្សន៍ និងការលើកទឹក ចិត្តសិស្សឱ្យចូលរួមក្នុងសកម្មភាពសិក្សាជាប្រចាំ ។

៣. **ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង** សំដៅលើការវិនិច្ឆ័យបានត្រឹមត្រូវ តម្លាភាព និង យុត្តិធម៌ ការដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍ ការរៀបចំសៀវភៅរដ្ឋ បាលថ្នាក់រៀន ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការគ្រប់គ្រង សកម្មភាពរៀន និងបង្រៀន ការផ្តល់ការទទួលខុសត្រូវ កំណែលម្អ និងឱកាសដល់ សិស្ស និងការសម្របសម្រួល និងជំរុញសកម្មភាពក្លឹបសិក្សា ។

៤. **ការស្រាវជ្រាវ និងគំនិតច្នៃប្រតិដ្ឋ** សំដៅលើការស្រាវជ្រាវបន្ថែមលើវិធីសាស្រ្ត និង បច្ចេកទេសបង្រៀនថ្មីៗ ការចូលរួមប្រជុំបច្ចេកទេសនិងការផលិតសម្ភារៈឧបទេស កិច្ចតែងការបង្រៀន ការរៀបចំផែនទីគំនិតថ្មីៗក្នុងដំណើរការបង្រៀន ការរិះរកវិធី សាស្រ្តជួយបង្រៀនបន្ថែមដល់សិស្សរៀនយឺត ការដឹកនាំសិស្សឱ្យធ្វើការសិក្សា ស្រាវជ្រាវ និងទេពកោសល្យ ឬគំនិតច្នៃប្រតិដ្ឋដែលធ្វើឱ្យថ្នាក់រៀនមានសកម្មភាព រស់រវើក ។

៥. **បំណិនប្រាស្រ័យទាក់ទង** សំដៅលើទំនាក់ទំនងល្អជាមួយគ្រូ សិស្ស គណៈគ្រប់គ្រង សាលារៀន មាតាបិតាសិស្ស សហគមន៍ រដ្ឋអំណាច និងអ្នកពាក់ព័ន្ធ ការផ្តល់ព័ត៌មាន ដល់មាតាបិតា ឬអាណាព្យាបាលសិស្សជាប្រចាំ ការផ្លាស់ប្តូរនូវបទពិសោធរៀន និង បង្រៀន និងការស្វែងយល់ពីសតិអារម្មណ៍របស់សិស្សឱ្យបានច្បាស់លាស់ ។

៦. **លទ្ធផលសិក្សារបស់សិស្ស** សំដៅលើ សិស្សដែលមានចំណេះដឹងសមស្រប តាម កម្មវិធីសិក្សា អត្រាសិស្សបោះបង់ការសិក្សាទាបជាង ឬស្មើថ្នាក់ជាតិ អត្រាសិស្សឡើង ថ្នាក់ស្មើ ឬខ្ពស់ជាងថ្នាក់ជាតិ ការជួយសិស្សរៀនយឺត សិស្សមានគំនិតច្នៃប្រតិដ្ឋ សិស្ស ពូកែថ្នាក់រាជធានី ខេត្ត ឬថ្នាក់ជាតិ ការផ្គត់ផ្គង់ និងថែរក្សាសៀវភៅសិក្សាគោល និង និយ័តភាពនៃការសិក្សា ។

៧. **ការសង្កេតការបង្រៀន និងរៀន** សំដៅលើការអនុវត្តតាមកិច្ចតែងការបង្រៀន ការប្រើ ប្រាស់សម្ភារៈឧបទេស ការប្រើប្រាស់វិធីសាស្រ្តបង្រៀន ការរៀបចំសកម្មភាពសិស្ស

អន្តរកម្មរវាងសិស្ស និងគ្រូបង្រៀន លទ្ធផលសិក្សាសម្រេចតាមវត្ថុបំណងមេរៀន ការចូលរួមសកម្មភាពសិស្សជាមួយគ្រូបង្រៀន ការបណ្តុះគំនិតច្នៃប្រតិដ្ឋ ទម្លាប់ល្អ និងសមត្ថភាពដល់សិស្ស ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃ និងមុខវិជ្ជាដទៃទៀត ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពបំណិននិងឥរិយាបថរបស់គ្រូបង្រៀន ។

៨. **ក្រមសីលធម៌វិជ្ជាជីវៈ** សំដៅលើការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន ការពង្រឹងសាមគ្គីភាព និងការទទួលខុសត្រូវ ការគោរពវិន័យការងារ និងការសម្ងាត់វិជ្ជាជីវៈ ភក្តីភាពចំពោះអង្គភាព វិជ្ជាជីវៈ និងផ្តល់តម្លៃអ្នកសិក្សា ការមិនរើសអើង និងមិនប្រើអំពើហិង្សា សីលធម៌រស់នៅល្អ គុណធម៌ និងយុត្តិធម៌ ការថែរក្សា និងទុកដាក់សម្ភារៈ បរិក្ខារមានសណ្តាប់ធ្នាប់ល្អ ។

៩. **ការអភិវឌ្ឍយុវជន** សំដៅលើការប្រឹក្សាយោបល់ក្នុងដំណើរការរៀបចំក្រុមប្រឹក្សាកុមារយុវជន ការចូលរួមក្នុងក្លឹបសិក្សា កងកាយរឹទ្ធិ ការជំរុញ ការដឹកនាំសកម្មភាពសង្គម និងការចូលរួមសកម្មភាពបណ្តុះបណ្តាលកុមារ យុវជន ។

## ២.៤. គោលបំណងនៃកម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២

អក្សរសាស្ត្រខ្មែរ ជាអត្តសញ្ញាណនៃវប្បធម៌ និងប្រពៃណីរបស់ជាតិខ្មែរ ។ ការចេះដឹងយល់ ស្គាល់ ប្រើប្រាស់ ថែរក្សា និងឱ្យតម្លៃភាសា និងអក្សរសាស្ត្រខ្មែរ ជាមោទនភាពរបស់ជាតិយើង ជាពលរដ្ឋខ្មែរគ្រប់រូប " **កម្មវិធីសិក្សាលម្អិត មុខវិជ្ជាអក្សរសាស្ត្រខ្មែរ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨** " ។ កម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ មានគោលបំណងដូចតទៅ ៖

- បន្តអភិវឌ្ឍសមត្ថភាពផ្នែកភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ពីមធ្យមសិក្សាបឋមភូមិ ដោយតម្រង់ទិស ការសិក្សារបស់សិស្សទៅតាមជម្រើសបណ្តុំមុខវិជ្ជា (វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រ) ដើម្បីបន្តការសិក្សា ឬចាប់យកអាជីពការងារក្នុងសង្គម
- ផ្តល់ដល់សិស្ស នូវការសិក្សាស៊ីជម្រៅទៅលើប្រវត្តិភាសា អក្សរ អក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់របស់ជាតិ និងអន្តរជាតិ
- ផ្តល់ការសិក្សាស៊ីជម្រៅទៅលើគ្រប់ទម្រង់ និងប្រភេទនៃអក្សរសិល្ប៍ ដោយបង្ហាញវិភាគវែកញែក បញ្ចេញយោបល់ ធ្វើការសន្និដ្ឋាន និងវាយតម្លៃបានត្រឹមត្រូវ ប្រកបដោយភាពច្បាស់លាស់ និងសុភវិនិច្ឆ័យ
- បណ្តុះសិស្សឱ្យមានជំនាញ ក្នុងការទទួលព័ត៌មាន (ស្តាប់) ការផ្តល់ព័ត៌មាន ការបង្ហាញ បញ្ចេញយោបល់ (និយាយ) ការស្វែងរកព័ត៌មាន ការស្វែងយល់ ការសិក្សា

ស្រាវជ្រាវ (អាន) និងការប្រើប្រាស់សំណេរគ្រប់ប្រភេទក្នុងការសិក្សាស្រាវជ្រាវ ទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃ ទីផ្សារការងារ និងអាជីព (សំណេរ)

- បណ្តុះសិស្សឱ្យចេះវិភាគបានច្បាស់លាស់ ទៅលើស្នាដៃអក្សរសិល្ប៍ជាតិអន្តរជាតិធំៗ ដោយបង្ហាញពីប្រវត្តិស្នាដៃ អ្នកនិពន្ធ អត្ថរូប អត្ថន័យ អត្ថរស និងគុណតម្លៃនៃស្នាដៃ
- ប្រើប្រាស់ភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ក្នុងទំនាក់ទំនងប្រចាំថ្ងៃ លើកិច្ចការរដ្ឋបាល ទីផ្សារការងារ ការសិក្សា ស្រាវជ្រាវ និងសិល្បៈ
- បណ្តុះស្មារតីសិស្សឱ្យចេះស្រឡាញ់ ថែរក្សា និងឱ្យតម្លៃទៅលើភាសា អក្សរសាស្ត្រជាតិ ប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ អរិយធម៌ខ្មែរ
- ចូលរួមអភិវឌ្ឍភាសា និងអក្សរសាស្ត្រជាតិ ឱ្យមានលក្ខណៈទំនើបទាន់សម័យ ឆ្លើយតបទៅនឹងការប្រើប្រាស់ក្នុងសង្គមរីកចម្រើន និងសាកលភាវូបនីយកម្ម
- បណ្តុះស្មារតីត្រិះរិះពិចារណា ចេះវិភាគរកហេតុផល ចេះវាយតម្លៃ ដោះស្រាយបញ្ហា និងអន្តរកម្មក្នុងក្របខណ្ឌជាតិ តំបន់ និងលើសាកលលោក ។

## ២.៥. ការអនុវត្តកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២

ការកែទម្រង់កម្មវិធីសិក្សាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរជាផ្នែកមួយក្នុងកំណែទម្រង់កម្មវិធីសិក្សា នៃកំណែទម្រង់វិស័យអប់រំ ពោលគឺជានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត ។ ការកែទម្រង់កម្មវិធីសិក្សាភាសាខ្មែរ ធ្វើឱ្យដោយផ្អែកតាមក្របខណ្ឌកម្មវិធីសិក្សា ដែលផ្តោតលើចំណុចសំខាន់ៗដូចជាប្រធានបទ លទ្ធផលសិក្សា ខ្លឹមសារ គន្លឹះសំខាន់ៗ វិធីសាស្ត្របង្រៀន របាយម៉ោង ការវាយតម្លៃ ការពិនិត្យតាមដាន សៀវភៅសិក្សាគោល និងសម្ភារៈសិក្សា ។ កម្មវិធីសិក្សាលម្អិតនេះមានបួនសមត្ថភាពគឺ ស្តាប់ និយាយ អាន និងសរសេរ ។ នៅក្នុងសមត្ថភាពនីមួយៗ បានកំណត់នូវលទ្ធផលសិក្សាទៅតាមកម្រិតថ្នាក់ ។ ដូច្នេះ ដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព ត្រូវ ៖

**- ការអនុវត្តម៉ោងសិក្សា** របាយម៉ោងសិក្សា អនុវត្តតាមម៉ោងកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា ។ ម៉ោងសិក្សាត្រូវបានបែងចែកទៅតាមសមត្ថភាព ស្តាប់ និយាយ អាន សរសេរ និងវេយ្យាករណ៍ ។ ការអនុវត្តម៉ោងសិក្សា ត្រូវមានភាពទន់ភ្លន់ និងត្រឹមត្រូវ ច្បាស់លាស់ ទើបមានប្រសិទ្ធភាព ។

**- ការវាយតម្លៃ** ការវាយតម្លៃត្រូវធ្វើជាប្រចាំ អាស្រ័យនឹងពេលវេលា និងប្រភេទតេស្ត

នីមួយៗ ។ រាល់ការធ្វើតេស្តត្រូវមានឧបករណ៍សម្រាប់វាយតម្លៃជាការចាំបាច់ ។ ឧបករណ៍តេស្ត គួររៀបចំជារួម ទៅតាមខណ្ឌ ក្រុង ស្រុក រាជធានី ខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ ។ ការវាយតម្លៃមានច្រើនប្រភេទគឺ ការសង្កេត ការសម្ភាស ការពិនិត្យតាមដាន និងការធ្វើតេស្ត ។ ការធ្វើតេស្តមានច្រើនប្រភេទដូចជា បុរេតេស្ត តេស្តតាមដំណាក់ (តេស្តវាយតម្លៃដំណើរការរៀន និងបង្រៀន និងតេស្តវាយតម្លៃសមត្ថភាពសិស្ស) តេស្តបញ្ចប់ តេស្តប្រចាំខែ តេស្តប្រចាំឆមាស តេស្តថ្នាក់ជាតិ និងការប្រឡងថ្នាក់ជាតិ ។ ចំពោះតេស្តប្រចាំខែ និងឆមាស គួរធ្វើឡើងដោយមានឧបករណ៍តេស្តរួមគ្នាទៅតាមកម្រង ខណ្ឌ ក្រុង ស្រុក រាជធានី ខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ ។

- **សម្ភារៈឧបទេស** សម្ភារៈឧបទេសគឺជាសមាសភាពចាំបាច់មួយ សម្រាប់ជួយឱ្យការរៀន និងបង្រៀនមានប្រសិទ្ធភាព ។ ការប្រើប្រាស់សម្ភារៈឧបទេស ត្រូវធានាថាបានប្រើប្រាស់ទាំងគ្រូ ទាំងសិស្ស ។ សម្ភារៈឧបទេសមានដូចជា សម្ភារៈជាក់ស្តែង សម្ភារៈច្នៃប្រតិដ្ឋករណីសិក្សា ឯកសារផ្សេងៗ សម្ភារៈអេឡិកត្រូនិក អ៊ីនធើណែត និងប្រព័ន្ធបណ្តាញសង្គមជាដើម ។

- **ឯកសារជំនួយ** ការប្រើប្រាស់សៀវភៅសិក្សាគោលតែមួយមុខមិនគ្រប់គ្រាន់ សម្រាប់ការអនុវត្តកម្មវិធីសិក្សាឱ្យបានល្អនោះទេ ។ ការផលិត និងប្រើប្រាស់ឯកសារជំនួយ គឺមានសារៈសំខាន់ណាស់សម្រាប់ជួយដល់ដំណើរការរៀន និងបង្រៀន ។ ឯកសារជំនួយមានដូចជា អំណានបន្ថែម សម្ភារៈសិក្សា គរុកោសល្យ វិធីសាស្ត្របង្រៀន លំហាត់កិច្ចការ ខ្លឹមសារគន្លឹះ ឧបករណ៍វាយតម្លៃ និងឯកសារយោងផ្សេងៗជាដើម ។

- **ការយល់ដឹងពីកម្មវិធីសិក្សា** សមាសភាគសំខាន់ៗមាន លទ្ធផលសិក្សា (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) វិធីសាស្ត្របង្រៀន របាយម៉ោងសិក្សា សម្ភារៈឧបទេស ឯកសារជំនួយ ការណែនាំអនុវត្តប្រធានបទ ការវាយតម្លៃ និងឯកសារជំនួយ ។ ដើម្បីអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាព គ្រូបង្រៀននិងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវយល់ដឹងពីកម្មវិធីសិក្សា និងចេះប្រើប្រាស់កម្មវិធីសិក្សា ព្រមទាំងដាក់បញ្ចូលលទ្ធផលសិក្សា ទៅក្នុងកិច្ចតែងការបង្រៀន និងបំណែងចែកកម្មវិធីនបង្រៀនប្រចាំខែ ។

- **ការផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង** ការរៀន និងការបង្រៀនអក្សរសាស្ត្រខ្មែរ ត្រូវផ្សារភ្ជាប់ជាមួយនឹងជីវភាពជាក់ស្តែង ។ ក្នុងការរៀន និងបង្រៀន ធ្វើយ៉ាងណាឱ្យសិស្សទទួលបាននូវចំណេះដឹង និងបំណិន ឬជំនាញ ។ សិស្សត្រូវយល់ដឹងពីសារៈសំខាន់ និងសារប្រយោជន៍នៃចំណេះដឹង និងបំណិន ឬជំនាញទាំងនោះហើយចេះយកចំណេះដឹង និងបំណិន ឬជំនាញទាំងនោះទៅប្រើប្រាស់ ឬអនុវត្ត សំដៅធ្វើឱ្យទទួលបាននូវគុណតម្លៃ ដែលកើតឡើង

ពីការសិក្សាភាសា និងអក្សរសាស្ត្រខ្មែរគ្រប់កម្រិត ។

## ២.៦. វិធីសាស្ត្របង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២

វិធីសាស្ត្របង្រៀន ការរៀន និងបង្រៀនអក្សរសាស្ត្រខ្មែរ ត្រូវធ្វើយ៉ាងណាឱ្យសិស្សយល់ដឹងពីរបៀបរៀនដោយខ្លួនឯង ពោលគឺមិនត្រូវឱ្យសិស្សរៀនបានត្រឹមតែត្រាប់តាមនោះទេ ។ គ្រូគប្បីប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែប ស្របតាមកាលៈទេសៈ និងស្ថានភាពជាក់ស្ដែង ជាពិសេស វិធីសាស្ត្របង្រៀនថ្មីៗមាន វិធីសាស្ត្របង្រៀនបែបស្រាវជ្រាវ បែបសហការ និងបែបរិះរកជាដើម ។ ការបង្រៀនត្រូវរកឱ្យឃើញចំណុចគន្លឹះ ដែលអាចធ្វើឱ្យសិស្សយល់ដឹងច្បាស់លាស់ ដូចជាចំណុចគន្លឹះក្នុងការបង្រៀនវេយ្យាករណ៍ បំណិន អក្សរសិល្ប៍ជាដើម ត្រូវឱ្យសិស្សចេះបកស្រាយបញ្ញត្តិ ចេះវិភាគ និងចេះប្រើប្រាស់ ។ ការរៀន និងបង្រៀនអក្សរសាស្ត្រខ្មែរ ត្រូវប្រើប្រាស់សំណួរទាំង៦កម្រិតគឺ ចងចាំ យល់ដឹង អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ។

ការរៀន និងបង្រៀនអក្សរសាស្ត្រខ្មែរ គ្រូត្រូវធ្វើយ៉ាងណារៀបចំសកម្មភាពក្នុងការរៀន និងបង្រៀន ដោយមានភាពទន់ភ្លន់ និងច្នៃប្រតិដ្ឋ ធ្វើយ៉ាងណាឱ្យសម្រេចតាមវត្ថុបំណងដែលបានគ្រោងទុក ។ មិនតែប៉ុណ្ណោះ ត្រូវនាំសិស្សឱ្យស្គាល់ពីគោលបំណង និងតម្លៃនៃសមត្ថភាពស្ដាប់ និយាយ អាន និងសរសេរឱ្យបានច្បាស់លាស់ ។ ចំពោះសកម្មភាពនៃការសិក្សាវិញ ត្រូវរៀបចំសិស្សឱ្យមានសកម្មភាពច្រើនដូចជា សកម្មភាពក្រុម ការងារដៃគូ ជាបុគ្គល ល្បែងដើរតួ ពិភាក្សា សម្របសម្រួល និងស្រាវជ្រាវជាដើម ។ លើសពីនេះ ត្រូវជួយជំរុញសិស្សឱ្យមានភាពក្លាហាន ក្នុងការបញ្ចេញមតិ យោបល់ គាំទ្រ បង្ហាញហេតុផល ហ៊ានសួរ ហ៊ានឆ្លើយ ហ៊ានទទួលខុសត្រូវ ស្ថិតក្នុងក្របខណ្ឌវិន័យ និងច្បាប់ ។ លើសពីនេះទៅទៀត ត្រូវជំរុញ និងលើកទឹកចិត្តសិស្សឱ្យចូលចិត្តអាន និងស្រាវជ្រាវឯកសារនានា ដែលមានប្រយោជន៍ សម្រាប់ការសិក្សា ដូចជា អត្ថបទព័ត៌មាន អត្ថបទអក្សរសិល្ប៍ខ្មែរ និងបរទេស ការតាក់តែងស្នាដៃដែលបម្រើឱ្យការសិក្សា និងការរស់នៅប្រចាំថ្ងៃដូចជា សំណេរតែងសេចក្ដី តែងកំណាព្យ តែងរឿងផ្សេងៗ លិខិតរដ្ឋបាល របាយការណ៍ កំណត់ហេតុ សន្ទរកថា ។ល។ ម្យ៉ាងទៀត ត្រូវបណ្ដុះទម្លាប់សិស្សឱ្យចេះរៀនដោយខ្លួនឯង រៀនជាក្រុម រៀនក្នុងក្លឹបសិក្សា ឬនៅក្នុងបណ្ណាល័យស្រាវជ្រាវ ។ មួយវិញទៀត ត្រូវបង្ហាញពីគុណតម្លៃនិងសម្រួចទេពកោសល្យរបស់សិស្សទៅតាមជំនាញរបស់សិស្ស ក្នុងការសិក្សាទៅតាមបណ្ដុំមុខវិជ្ជាសិក្សា (ថ្នាក់វិទ្យាសាស្ត្រ ឬថ្នាក់វិទ្យាសាស្ត្រសង្គម) ។

## ២.៧. សម្ភារៈឧបទេសសម្រាប់ដំណើរការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ

សម្ភារៈឧបទេស គឺជាធនធានទាំងឡាយណាដែលគ្រូ និងសិស្សយកមកប្រើប្រាស់ក្នុងការរៀន និងបង្រៀន ។ សម្ភារៈឧបទេស និងសម្ភារៈជំនួយ ជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់ សម្រាប់ប្រើប្រាស់ក្នុងដំណើរការរៀន និងបង្រៀន ប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់លាស់ ងាយយល់ ងាយចាប់បាន ហើយអាចសម្រេចវត្ថុបំណងមេរៀនបានល្អប្រសើរ ។ ការបង្រៀនដែលប្រើប្រាស់សម្ភារៈឧបទេស ជាការជួយពង្រឹងដល់ការសិក្សារបស់សិស្ស ឱ្យកាន់តែច្បាស់លាស់នូវន័យរបស់ពាក្យគន្លឹះ កន្សោមពាក្យ ខ្លឹមសារអត្ថបទ ជាពិសេសផ្នែកវេយ្យាករណ៍ ។ លោកគ្រូ អ្នកគ្រូ គប្បីឱ្យសិស្សហាត់ប្រើសម្ភារៈដោយខ្លួនឯង ចុះស្រាវជ្រាវ សង្កេតផ្ទាល់ដល់ទីកន្លែង ដើម្បីឱ្យសិស្សកាន់តែយល់ច្បាស់លើខ្លឹមសារមេរៀនដែលបានបង្រៀនរួច ។ កត្តាសំខាន់ គ្រូបង្រៀនត្រូវកំណត់សម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ទៅតាមតម្រូវការនៃមេរៀននីមួយៗ ។ សម្ភារៈឧបទេសដែលគ្រូបង្រៀនត្រូវប្រើប្រាស់ សម្រាប់ដំណើរការរៀន និងបង្រៀន គឺជាសម្ភារៈទាំងឡាយណា ដែលងាយរក ងាយផលិត ងាយសង្កេត និងប្រើប្រាស់ ហើយមានគុណភាព និងប្រសិទ្ធភាព ។

ចំពោះការរៀន និងការបង្រៀនអក្សរសាស្ត្រខ្មែរ សម្ភារៈឧបទេសដែលបម្រើឱ្យដំណើរការ ត្រូវបានចែកចេញជាបួនប្រភេទដូចជា ៖

- **សម្ភារៈរូបី** ជាសម្ភារៈទាំងឡាយណាដែលទាមទារឱ្យគ្រូបង្រៀនចេះប្រើប្រាស់វត្ថុពិតជាក់ស្តែង រុក្ខជាតិ សត្វ ធម្មជាតិ វត្ថុសិល្បៈ ទីកន្លែង បេតិកភណ្ឌ សម្ភារៈប្រពៃណី ទស្សនីយភាពពិត ដូចជា ចម្រៀងវីដេអូជាដើម ដោយគ្រូចេះដឹកនាំសិស្សចុះសិក្សា សង្កេត ស្រាវជ្រាវ រិះរក ពន្យល់ បង្ហាញជាក់ស្តែង ដើម្បីបង្កើនការយល់ដឹងអំពីបញ្ញត្តិ ខ្លឹមសារ មេរៀនដែលទាក់ទងនឹងប្រធានបទ ។ សម្ភារៈរូបី សំដៅលើប្រភេទសម្ភារៈដូចជា កែវ ថូ គ្រឿងអលង្ការ សម្ភារៈប្រើប្រាស់បុរាណ ចម្លាក់ សិលាចារឹក ទីកន្លែងជាក់ស្តែង ។ល។

- **សម្ភារៈពាក់កណ្តាលរូបី** សម្ភារៈរូបី ឬលក្ខណៈជាក់ស្តែងមិនអាចឆ្លើយតបទៅនឹងស្ថានភាពនៃការសិក្សា តាមតំបន់នានាបានឡើយ គឺទាមទារឱ្យគ្រូបង្រៀនចេះផលិត និងប្រើប្រាស់សម្ភារៈពាក់កណ្តាលរូបី ។ សម្ភារៈពាក់កណ្តាលរូបី សំដៅលើប្រភេទសម្ភារៈមួយចំនួនដែលផលិតតំណាងពីរូបពិត វត្ថុពិត ឬទីកន្លែងពិត ។ សម្ភារៈទាំងនេះមានដូចជា រូបថត ឬរូបភាពមនុស្ស សត្វ វត្ថុ រុក្ខជាតិ ធម្មជាតិ ទីកន្លែង ដែលគ្រូផលិតឡើង សម្រាប់ជាជំនួយក្នុងការរៀន និងបង្រៀន ។

- **សម្ភារៈអរូបី** ជាសម្ភារៈដែលមិនមែនជាក់ស្តែង និងមិនមែនជារូបថត ឬរូបភាពសម្គាល់ច្បាស់លាស់នោះទេ វាគ្រាន់តែត្រូវគេលើកមកជាតំណាង សន្មត ឬជាគ្រឿងសម្គាល់ឈ្មោះមនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង ... ។ សម្ភារៈទាំងនោះ គ្រូផលិត ឬលើកឡើងសម្រាប់ជាជំនួយក្នុងការបង្រៀន និងរៀន ។

- **សម្ភារៈអេឡិកត្រូនិក** ក្រៅពីសម្ភារៈសំខាន់ៗទាំងបីប្រភេទខាងលើនេះ លោកគ្រូ អ្នកគ្រូ ក៏ត្រូវមានសមត្ថភាពក្នុងការប្រើប្រាស់សម្ភារៈអេឡិកត្រូនិកទំនើបៗមួយចំនួនដូចជា ៖

+ **សម្ភារៈអេឡិកត្រូនិកសម្រាប់ធ្វើបទបង្ហាញ** ជាសម្ភារៈដែលទាក់ទាញអារម្មណ៍អ្នកសិក្សាឱ្យចូលរួមបានជាច្រើន ។ សម្ភារៈនេះ ទាមទារឱ្យមានការរៀបចំ និងចងក្រងខ្លឹមសារមេរៀន ឬប្រធានបទនានា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើប ដោយប្រើប្រាស់កម្មវិធីមួយចំនួនរបស់កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង ព្រមទាំងសម្ភារៈមួយចំនួនទៀតដូចជា ឌីវីឌី ម៉ាញ៉េវីដេអូជាដើម ។

+ **សម្ភារៈអេឡិកត្រូនិកសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងផ្តល់ព័ត៌មាន** ជាសម្ភារៈដូចជា កុំព្យូទ័រ អ៊ីនធើណែត ហ្វេសប៊ុក តេឡេក្រាម អ៊ីមែល យូធូប និងទូរសព្ទជាដើម ។ សម្ភារៈទាំងនេះ ទាមទារឱ្យគ្រូបង្រៀនត្រូវមានសមត្ថភាពគ្រប់គ្រាន់ និងចំណេះដឹងពីបច្ចេកវិទ្យាព័ត៌មានឱ្យបានច្បាស់លាស់ ។ ដើម្បីប្រើប្រាស់សម្ភារៈទាំងនេះឱ្យមានប្រសិទ្ធភាព ទាមទារឱ្យគ្រូបង្រៀនត្រូវមានចំណេះដឹងផ្នែកភាសាបរទេសថែមទៀត ។ នៅក្នុងកម្មវិធីទាំងនេះ យើងអាចមើលឃើញឯកសារជាច្រើនជុំវិញពិភពលោក និងការចែករំលែក ។ ការសិក្សាស្រាវជ្រាវដែលអាចប្រើប្រាស់សម្ភារៈទាំងនេះ ធ្វើឱ្យគ្រូបង្រៀនមានការយល់ដឹង កាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពថែមទៀត ។

# ជំពូកទី៣
# វិធីសាស្ត្រសិក្សាស្រាវជ្រាវ

## ៣.១. ការប្រមូលទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរស្រាវជ្រាវខាងលើ វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យត្រូវបានជ្រើសរើសយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យពីអ្នកដែលពាក់ព័ន្ធនានា។ មុននឹងប្រមូលទិន្នន័យទាំងនេះ កម្រងសំណួរចំនួនបីប្រភេទ ត្រូវបានបង្កើតឡើង សម្រាប់អ្នកចូលរួមចំនួនបីប្រភេទផ្សេងគ្នាឆ្លើយ រួមមាន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ និងសិស្សានុសិស្សថ្នាក់ទី១២ ។ កម្រងសំណួរទាំងនេះត្រូវបានបង្កើតឡើងតាមរយៈការអាន និងពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើឯកសារគោលនានាដូចជា ឯកសារកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ លិខិតនិងសេចក្តីណែនាំរបស់ក្រសួង សៀវភៅសិក្សាគោល ព្រមទាំងឯកសារពាក់ព័ន្ធនានា បានមកពីការសិក្សាស្រាវជ្រាវដែលមានស្រាប់ទាំងក្នុងស្រុក និងក្រៅប្រទេសមួយចំនួននៅក្នុងតំបន់ និងសកលលោក ។

## ៣.២. ទីតាំងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកវិទ្យាល័យគោលដៅចំនួន ១៤ ក្នុងខេត្តកំពង់ចាម រួមមាន៖ (១) វិទ្យាល័យ ហ៊ុន សែន កំពង់ចាម (២) វិទ្យាល័យ សំបួរមាស (៣) វិទ្យាល័យ សម្តេច ហ៊ុន សែន ពាមជីកង (៤) វិទ្យាល័យ ហ៊ុន សែន ខ្ចៅ (៥) វិទ្យាល័យ ហ៊ុន សែន ចំការលើ (៦) វិទ្យាល័យបុសខ្នុរ (៧) វិទ្យាល័យ នរោត្តម រណឫទ្ធិ គន្ធបុប្ផា (៨) វិទ្យាល័យ ស្រេង គីម (៩) វិទ្យាល័យ ហ៊ុន សែន ស្គន់ (១០) វិទ្យាល័យ ហ៊ុន សែន ផ្តៅជុំ (១១) វិទ្យាល័យ ហ៊ុន សែន សំពងជ័យ (១២) វិទ្យាល័យ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន មានជ័យ (១៣) វិទ្យាល័យ ហោ ណាំហុង ព្រៃញា និង (១៤) វិទ្យាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បាធាយ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ និងច្បាស់លាស់ ។

មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសយកវិទ្យាល័យទាំងនោះ សម្រាប់ធ្វើការស្រាវជ្រាវដោយសារសាលារៀនទាំងនោះ ស្ថិតនៅក្នុងស្រុកផ្សេងៗគ្នា (វិទ្យាល័យចំនួន ២ស្ថិតនៅក្នុងប្រជុំជនទីរួមខេត្ត និង ១២ ផ្សេងទៀតស្ថិតនៅតាមស្រុកចំនួន០៥) ។

## ៣.៣. ការជ្រើសរើសសំណាក

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមបែបគោលបំណងក្នុងការប្រមូលទិន្នន័យ ដោយដៅតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្ដល់នូវទិន្នន័យបានជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូច្នេះ ធាតុសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចទទួលបានទិន្នន័យដែលអាចជឿទុកចិត្តបាននោះមានបីប្រភេទរួមមាន៖ គណៈគ្រប់គ្រងសាលារៀនចំនួន ១៤នាក់ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរថ្នាក់ទី១២ ចំនួន ២៤នាក់ និងសិស្សានុសិស្សថ្នាក់ទី១២ ចំនួន១៣០០នាក់ ចេញពីវិទ្យាល័យចំនួន ១៤ ក្នុងក្រុង០១ និងស្រុកចំនួន០៥ ផ្សេងៗគ្នា នៅក្នុងខេត្តកំពង់ចាម ។
ប្រភេទទី១ គឺ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំងអស់ ត្រូវបានជ្រើសរើសសម្រាប់បំពេញកម្រងសំណួរ ។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសយកគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ដោយសារមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ក្នុងកម្រិតថ្នាក់នេះ ជាមុខវិជ្ជាមួយដែលត្រូវបានក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិផងដែរ ទាំងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ។ ដូច្នេះអ្នកសិក្សាស្រាវជ្រាវជឿជាក់ថា លោកគ្រូ អ្នកគ្រូពិតជាអាចប្រាប់ពីស្ថានភាពដែលគាត់ជួបប្រទះក្នុងការអនុវត្តការបង្រៀនប្រចាំថ្ងៃ និងព័ត៌មានលម្អិតទាំងអស់មកធ្វើការវិភាគបានស៊ីជម្រៅជាមិនខាន ។ ប្រភេទទី២ គឺ ការជ្រើសរើសយកសិស្សថ្នាក់ទី១២មកធ្វើជាសំណាក ព្រោះតែពួកគេជាអ្នកសិក្សាមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ជាមួយគ្រូអក្សរសាស្ត្រខ្មែរ របស់ពួកគេផ្ទាល់ ។ ហេតុដូច្នេះ ពួកគេប្រាកដជាអាចផ្ដល់ព័ត៌មានបន្ថែម ទាក់ទងនឹងប្រធានបទបានគ្រប់ជ្រុងជ្រោយ សម្រាប់ឱ្យអ្នកសិក្សាស្រាវជ្រាវយកមកធ្វើការវិភាគ ។ ប្រភេទទី៣ គឺការសម្ភាសផ្ទាល់ និងឱ្យគណៈគ្រប់គ្រងសាលារៀនជួយបំពេញនូវកម្រងសំណួរបន្ថែម ។ មូលហេតុដែលជ្រើសរើសគណៈគ្រប់គ្រងសាលារៀន ក្នុងការផ្ដល់ព័ត៌មានក្នុងការស្រាវជ្រាវនេះពីព្រោះតែនាយកសាលាក៏ជាអ្នកដែលអាចផ្ដល់ព័ត៌មានទូទៅស្ដីពីការបង្រៀន ការរៀន របស់លោកគ្រូអ្នកគ្រូ និងសិស្ស ជាពិសេស គណៈគ្រប់គ្រងសាលារៀន គឺជាអ្នកធ្វើអធិការកិច្ចផ្ទាល់នៅសាលារៀន ក្នុងការតាមដានការអនុវត្តការងារប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ ។

## ៣.៤. ឧបករណ៍សិក្សាស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតកម្រងសំណួរស្រាវជ្រាវចំនួនបី ដើម្បីឆ្លើយតបនឹងវត្ថុបំណងនៃការស្រាវជ្រាវរួមមាន៖ ទី១ កម្រងសំណួរ

សម្រាប់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទី២គឺ កម្រងសំណួរសម្រាប់សិស្សថ្នាក់ទី១២ និងទី៣ គឺកម្រងសំណួរសម្រាប់ឱ្យគណៈគ្រប់គ្រងសាលារៀនបំពេញ ។

កម្រងសំណួរទី១ ៖កម្រងសំណួរសម្រាប់គ្រូបង្រៀន អ្នកសិក្សាស្រាវជ្រាវបានរៀបចំជាពីរផ្នែក ៖

**ផ្នែកទី(១)** អំពីព័ត៌មានផ្ទាល់ខ្លួនរបស់គ្រូបង្រៀន ចែកចេញជា៣ចំណុចគឺ (១) ក្របខណ្ឌ (២) កម្រិតវប្បធម៌ និង (៣) បទពិសោធការងារ ។

**ផ្នែកទី(២)** បង្ហាញពីស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ នៅក្នុងខេត្តកំពង់ចាម ដែលចែកចេញជា ៣ចំណុចធំៗ គឺ ៖

(១) ដំណើរការនៃការបង្រៀនរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា១៧ចំណុចតូចៗ គឺ ៖

ក. មកបង្រៀនបានទៀងទាត់តាមម៉ោងចេញ និងម៉ោងចូល

ខ. មានគ្រូបង្រៀនអក្សរសាស្ត្រខ្មែរផ្សេងទៀតជំនួស ពេលលោកគ្រូ អ្នកគ្រូ អវត្តមាន

គ. មានកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការបានទៀងទាត់

ឃ. បានដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែកិច្ចការសិស្សជាប្រចាំ

ង. បានវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំក្នុងពេល ឬក្រោយបង្រៀនចប់មេរៀន

ច. បានផ្តល់សៀវភៅតាមដានការសិក្សាសិស្ស ដល់អាណាព្យាបាលសិស្ស

ឆ. បានផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន

ជ. បានប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បង្រៀន

ឈ. ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រងសាលារៀន

ញ. ធ្លាប់ទទួលបានការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីរបស់ក្រសួង

ដ. មានភាពលម្អៀងចំពោះសិស្សក្នុងពេលបង្រៀន

ឋ. បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបរិះរក (IBL) ក្នុងពេលបង្រៀន

ឌ. បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL) ក្នុងពេលបង្រៀន

ឍ. បានប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងពេលបង្រៀន

ណ. បានប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌលក្នុងពេលបង្រៀន

ត. បានបង្រៀនតាមកាលវិភាគដែលគណៈគ្រប់គ្រងបានកំណត់

ថ. បានបង្រៀនចប់តាមកម្មវិធីសិក្សាដែលក្រសួងបានកំណត់

(២) បញ្ហាប្រឈមរបស់លោកគ្រូ អ្នកគ្រូ ក្នុងពេលបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា០៩ចំណុចតូចៗ គឺ ៖

ក. បញ្ហាប្រឈមទី១

ខ. បញ្ហាប្រឈមទី២

គ. បញ្ហាប្រឈមទី៣

ឃ. ផ្សេងៗ

(៣) ដំណោះស្រាយ ឬវិធានការដោះស្រាយរបស់លោកគ្រូ អ្នកគ្រូ ចំពោះបញ្ហាប្រឈម ក្នុងពេលបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា០៤ចំណុចតូចៗ គឺ៖

ក. ដំណោះស្រាយទី១

ខ. ដំណោះស្រាយទី២

គ. ដំណោះស្រាយទី៣

ឃ. ផ្សេងៗ

**កម្រងសំណួរទី២៖** កម្រងសំណួរសម្រាប់សិស្ស អ្នកសិក្សាស្រាវជ្រាវរៀបចំជា២ផ្នែក៖

**ផ្នែកទី(១)** ព័ត៌មានទូទៅរបស់សិស្ស ចែកចេញជា៣ចំណុចគឺ (១)ឈ្មោះវិទ្យាល័យរបស់សិស្ស (២) ថ្នាក់ទី (៣) ប្រភេទថ្នាក់វិទ្យាសាស្ត្រ ឬថ្នាក់វិទ្យាសាស្ត្រសង្គម ។

**ផ្នែកទី(២)** បង្ហាញពីស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ នៅក្នុងខេត្តកំពង់ចាម ដែលចែកចេញជា ៣ចំណុចធំៗ គឺ៖

(១) ដំណើរការនៃការរៀនរបស់សិស្ស ថ្នាក់ទី១២ ចែកចេញជា១៥ចំណុចតូចៗ គឺ៖

ក. មករៀនបានទៀងទាត់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ខ. ចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

គ. បង្កើតក្លឹបសិក្សាដោយខ្លួនឯង និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ

ឃ. បានធ្វើកិច្ចការដែលគ្រូបានដាក់ឱ្យ និងទទួលបានការកែលម្អពីគ្រូជាប្រចាំ

ង. ចូលរួមក្នុងការវាយតម្លៃលទ្ធផលសិក្សាក្នុងពេលរៀន ឬក្រោយពេលរៀនមេរៀនចប់

ច. បានទទួលសៀវភៅតាមដានការសិក្សាពីគ្រូបង្រៀន បានទៀងទាត់

ឆ. មានភាពក្លាហានក្នុងការឆ្លើយសំណួររបស់គ្រូ

ជ. សហការគ្នាពិភាក្សាជាក្រុម ក្នុងពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ឈ. បានជួយមិត្តភក្តិពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ញ. យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ដ. រៀនគួរបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ឋ. ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របង្រៀនបែបរិះរក (IBL)

ឌ. ធ្លាប់បានទទួលការបង្រៀនវិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL)

ឍ. ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល
ណ. ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល
(២) បញ្ហាប្រឈមរបស់ប្អូនៗ ក្នុងការរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា០៤ ចំណុចតូចៗ គឺ ៖
ក. បញ្ហាប្រឈមទី១
ខ. បញ្ហាប្រឈមទី២
គ. បញ្ហាប្រឈមទី៣
ឃ. ផ្សេងៗ
(៣) ដំណោះស្រាយ ឬវិធានការដោះស្រាយរបស់ប្អូនៗចំពោះបញ្ហាប្រឈម ក្នុងពេលបង្រៀន មុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា០៤ចំណុចតូចៗ គឺ ៖
ក. ដំណោះស្រាយទី១
ខ. ដំណោះស្រាយទី២
គ. ដំណោះស្រាយទី៣
ឃ. ផ្សេងៗ

កម្រងសំណួរទី៣៖ កម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលារៀន នៅក្នុងកម្រងសំណួរនេះអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា ០២ ផ្នែក ៖

**ផ្នែកទី(១)** ព័ត៌មានផ្ទាល់ខ្លួន ចែកចេញជា០៣ចំណុច មាន (១) មុខតំណែង (២) កម្រិតវប្បធម៌ (៣) បទពិសោធការងារ ។

**ផ្នែកទី(២)** បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង លើការងារបង្រៀន និងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ នៅក្នុងខេត្តកំពង់ចាម ដែលចែកចេញជា ៣ចំណុចធំៗ គឺ ៖
(១) ដំណើរការនៃការដឹកនាំ និងគ្រប់គ្រង លើការងារបង្រៀន និងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ របស់គណៈគ្រប់គ្រងសាលារៀន ចែកចេញជា១៧ចំណុចតូចៗ គឺ ៖
ក. បែងចែកគ្រូទៅតាមឯកទេសវិជ្ជាជីវៈរបស់គ្រូនីមួយៗ
ខ. គ្រប់គ្រងបុគ្គលិក ម៉ោងចេញ ម៉ោងចូលរបស់គ្រូ និងសិស្ស
គ. មានការប្រជុំបច្ចេកទេសទៀងទាត់លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ
ឃ. មានការដឹកនាំថ្នាក់និទស្សន៍អភិវឌ្ឍសមត្ថភាពគ្រូលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ
ង. ផ្តល់ឱកាសឱ្យគ្រូអក្សរសាស្ត្រខ្មែរ ទទួលបានការបំប៉នពីវិធីសាស្ត្រថ្មីៗ សម្បូរបែប
ច. ត្រួតពិនិត្យគ្រូក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សាលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ
ឆ. មានកម្មវិធីប្រឡងសិស្សពូកែអក្សរសាស្ត្រខ្មែរ ទាក់ទាញសិស្សចូលប្រឡង

ជ. ទទួលបានការបំប៉នពីក្របខណ្ឌកម្មវិធីសិក្សាថ្មី
ឈ. ផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់គ្រូបង្រៀន
ញ. ជំរុញ និងគាំទ្រគ្រូមុខវិជ្ជាអក្សរសាស្ត្រខ្មែរប្រើវិធីសាស្ត្របង្រៀនថ្មីៗ
ដ. មានការតាមដានលើការសិក្សារបស់សិស្សជាប្រចាំ
ឋ. មានការលើកទឹកចិត្តដល់សិស្សរៀនពូកែ
ឌ. ផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀន
ឍ. រៀបចំថែទាំបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងសាលារៀន
ណ. មានកម្មវិធីបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ
ត. វាយតម្លៃការបង្រៀនរបស់គ្រូ
ថ. មាន LCD និងឧបករណ៍ ICT ផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងពេលបង្រៀន
(២) បញ្ហាប្រឈមរបស់លោក លោកស្រី ក្នុងការដឹកនាំ និងគ្រប់គ្រង លើការបង្រៀន និងរៀន មុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា០៤ចំណុចតូចៗ គឺ៖
ក. បញ្ហាប្រឈមទី១
ខ. បញ្ហាប្រឈមទី២
គ. បញ្ហាប្រឈមទី៣
ឃ. ផ្សេងៗ
(៣) ដំណោះស្រាយ ឬវិធានការដោះស្រាយរបស់លោក លោកស្រី ចំពោះបញ្ហាប្រឈម ក្នុងការដឹកនាំ និងគ្រប់គ្រង លើការងារបង្រៀន និងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចែកចេញជា០៤ចំណុចតូចៗ គឺ៖
ក. ដំណោះស្រាយទី១
ខ. ដំណោះស្រាយទី២
គ. ដំណោះស្រាយទី៣
ឃ. ផ្សេងៗ

## ៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ

ក្រោយពីទទួលបានការណែនាំ និងឯកភាពពីគ្រូណែនាំ ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១១៩ វជអ.ផក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្ដីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញា

បត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី - ខេត្តនានា និងលិខិតជូនដំណឹងពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៨៨៥ អយក.វជអ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ស្ដីពីការស្នើទៅប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម សុំជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី ខេត្តនានា។ មូលហេតុនៃការស្នើសុំទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាមនេះ ដោយសារតែវិទ្យាល័យគោលដៅ យកមកធ្វើការស្រាវជ្រាវទាំងនេះ ស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ។ បន្ទាប់ពីទទួលបាននូវការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាមតាមរយៈលិខិតលេខ ៨៧៥/១៩ ឧទន.រប ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ស្ដីពីការសម្រួលដល់ការចុះសិក្សាស្រាវជ្រាវនៅតាមក្រុង ស្រុកគោលដៅនានា ក្នុងខេត្តកំពង់ចាមមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដោយធ្វើការទំនាក់ទំនងសាលាគោលដៅដោយផ្ទាល់ ។ មូលហេតុគឺដើម្បីជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលារៀន ដើម្បីកំណត់កាលបរិច្ឆេទក្នុងការណាត់ជួបគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ ដែលបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ និងសិស្សថ្នាក់ទី១២ ក្នុងការបំពេញកម្រងសំណួរដែលត្រៀមទុកជាមុន ធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ដល់ការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស ។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលា អំពីគោលបំណង និងផែនការទាំងមូលនៃការសិក្សា ស្រាវជ្រាវ ។ ក្រោយពីគណៈគ្រប់គ្រងសាលារៀនបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡា ក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយ គាត់ក៏បានអនុញ្ញាតឱ្យរៀបចំការប្រមូលទិន្នន័យ តាមផែនការដែលឯកភាពគ្នា តាមដំណាក់កាលនីមួយៗ ។

មុនការចុះប្រមូលទិន្នន័យផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់នៅសាលាមួយក្នុងខេត្តកំពង់ចាម ។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរថាតើអាចយកមកប្រមូលទិន្នន័យផ្លូវការបានដែរឬទេ ។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងនេះ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថាការសាកល្បងនេះពិតជាទទួលបានផលល្អមែន ព្រោះយើងរកឃើញចំណុចខ្វះខាតមួយចំនួនរបស់កម្រងសំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនេះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបាននូវយោបល់ត្រឹមត្រូវក្នុងការកែលម្អ កម្រងសំណួរឡើងវិញ។ ក្រោយពីការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្ដើមចុះប្រមូលទិន្នន័យតែម្ដង ។

## ៣.៦. ការវិភាគទិន្នន័យ

នៅក្នុងការសិក្សា ស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើសទៅតាមកម្រិតនីមួយៗ ព្រមជាមួយកម្រងសំណួរជាទម្រង់បើក សម្រាប់ស្វែងរកធាតុចូល ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅលើលក្ខណវិនិច្ឆ័យនៃគ្រូបង្រៀនល្អ នាយកសាលាល្អ វិធីសាស្ត្របង្រៀន សម្ភារៈបង្រៀន កម្មវិធីសិក្សា បញ្ហាប្រឈម និងដំណោះស្រាយបញ្ហា ។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់វិធីកម្មវិធីវិភាគ ស្ថិតិ សម្រាប់ស្វែងរកចំនួនប្រេកង់គិតជាចំនួន និងភាគរយ កម្មវិធី Microsoft Excel សម្រាប់សង់តារាង និងបកស្រាយព័ត៌មាន។ ការវិភាគបែបសំណួរបើក ជាការប្រមូលផ្តុំគំនិតទស្សនៈការយល់ឃើញនានារបស់អ្នកបំពេញកម្រងសំណួរ ដោយចាប់បញ្ចូលនូវចំណុចដែលដូច ឬប្រហាក់ប្រហែលគ្នា ដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រចំពោះទិន្នន័យ នៃការវិភាគតាមបែបបរិមាណវិស័យ ។ បន្ទាប់មកអ្នកសិក្សា ស្រាវជ្រាវ បានលើកជាសំណូមពរ ចំពោះចំណុចខ្វះខាត និងកែលម្អចំណុចខ្វះខាតទាំងនោះឱ្យបានប្រសើរឡើង។

## ៣.៧. ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានផ្តោតយកចិត្តទុកដាក់ពីបញ្ហាក្រមសីលធម៌ ពីព្រោះវាមានសារៈសំខាន់ណាស់ក្នុងការធានាប្រសិទ្ធភាព នៃការស្រាវជ្រាវក៏ដូចជាបង្កើននូវភាពទុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ ក៏ដូចជាទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ មានការព្រមព្រៀងគ្នារវាងអ្នកផ្តល់ចម្លើយ និងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់ និងមានប្រសិទ្ធភាព ហើយអាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាការសម្ងាត់ លើកលែងតែឈ្មោះសាលាដែលត្រូវបានបង្ហាញ ប៉ុន្តែ ក៏មានការឯកភាពពីគណៈគ្រប់គ្រងវិទ្យាល័យគោលដៅនីមួយៗ អ្នកសិក្សាស្រាវជ្រាវ បាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយ ហើយក៏បានសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលពួកគាត់បំពេញកម្រងសំណួរ ។ ការធ្វើបែបនេះមានន័យថា អ្នកផ្តល់ចម្លើយយល់នូវគោលបំណង នៃការស្រាវជ្រាវជាមុន ហើយអ្នកស្រាវជ្រាវក៏រំពឹងផងដែរថានឹងទទួលបានចម្លើយ ឬព័ត៌មានដែលពិត។ ការធ្វើដូច្នេះ ធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូកទី៤
# លទ្ធផលនៃការសិក្សាស្រាវជ្រាវ

## ៤.១. អ្នកចូលរួម និងព័ត៌មានទូទៅ

បន្ទាប់ពីការចុះប្រមូលទិន្នន័យ នៅតាមវិទ្យាល័យគោលដៅទាំង ១៤ រួចមក អ្នកសិក្សាស្រាវជ្រាវទទួលបានអ្នកចូលរួមសរុបចំនួន ១៣៣៨នាក់ ក្នុងនោះមានគណៈគ្រប់គ្រងសាលារៀន ចំនួន ១៤ នាក់ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ចំនួន ២៤នាក់ និងសិស្សានុសិស្សដែលកំពុងរៀនក្នុងថ្នាក់ទី១២ ចំនួន ១៣០០ នាក់ ។

**តារាងទី១ ៖ អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ**

| អ្នកចូលរួម | សរុប |
|---|---|
| គណៈគ្រប់គ្រងសាលារៀន | ១៤ |
| គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | ២៤ |
| សិស្សថ្នាក់ទី១២ | ១៣០០ |
| **សរុប** | ១៣៣៨ នាក់ |

## ៤.២. លទ្ធផលនៃការសិក្សាស្រាវជ្រាវតាមប្រភេទកម្រងសំណួរនីមួយៗ

### ៤.២.១. លទ្ធផលនៃកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀន

**តារាងទី២ ៖ លទ្ធផលនៃកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀន**

**គិតជាចំនួននាក់ និងភាគរយ**

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ច្រើនបំផុត | | ច្រើន | | មធ្យម | | តិច | | តិចបំផុត | |
| | ការដឹកនាំ និងគ្រប់គ្រង | ចំ. | % | ចំ. | % | ចំ. | % | ចំ. | % | ចំ. | % |
| ១ | ការបែងចែកគ្រូទៅតាមឯកទេសវិជ្ជាជីវៈរបស់គ្រូនីមួយៗ | 4 | 29 | 8 | 57 | 1 | 7 | 1 | 7 | 0 | 0 |
| ២ | ការគ្រប់គ្រងបុគ្គលិក ម៉ោងចេញ ម៉ោងចូលរបស់គ្រូ សិស្ស | 5 | 36 | 7 | 50 | 2 | 14 | 0 | 0 | 0 | 0 |
| ៣ | ប្រជុំបច្ចេកទេសទៀងទាត់លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 2 | 14 | 7 | 50 | 3 | 22 | 2 | 14 | 0 | 0 |
| ៤ | ការដឹកនាំថ្នាក់និទស្សន៍អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន | 1 | 7 | 3 | 22 | 5 | 36 | 3 | 21 | 2 | 14 |
| ៥ | ផ្តល់ឱកាសឲ្យគ្រូបង្រៀនទទួលបានការបំប៉នពីវិធីសាស្ត្រថ្មីៗ | 3 | 21 | 5 | 36 | 5 | 36 | 0 | 0 | 1 | 7 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៦ | ត្រួតពិនិត្យគ្រូបង្រៀនក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សា | 2 | 14 | 9 | 65 | 1 | 7 | 1 | 7 | 1 | 7 |
| ៧ | កម្មវិធីប្រឡងសិស្សពូកែអក្សរសាស្ត្រខ្មែរ ទាក់ទាញសិស្ស | 5 | 36 | 7 | 50 | 1 | 7 | 0 | 0 | 1 | 7 |
| ៨ | ទទួលបានការបំប៉នពីក្របខណ្ឌកម្មវិធីសិក្សាថ្មី | 0 | 0 | 4 | 29 | 4 | 29 | 3 | 21 | 3 | 21 |
| ៩ | ផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់គ្រូបង្រៀន | 2 | 15 | 7 | 50 | 1 | 7 | 2 | 14 | 2 | 14 |
| ១០ | ជំរុញ និងគាំទ្រគ្រូឱ្យប្រើវិធីសាស្ត្របង្រៀនថ្មីៗ | 3 | 21 | 8 | 58 | 2 | 14 | 0 | 0 | 1 | 7 |
| ១១ | ការតាមដានលើការសិក្សារបស់សិស្សជាប្រចាំ | 3 | 21 | 9 | 65 | 2 | 14 | 0 | 0 | 0 | 0 |
| ១២ | ការលើកទឹកចិត្តដល់សិស្សរៀនពូកែ | 5 | 36 | 7 | 50 | 1 | 7 | 0 | 0 | 1 | 7 |
| ១៣ | ផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀន | 2 | 14 | 5 | 36 | 6 | 43 | 0 | 0 | 1 | 7 |
| ១៤ | រៀបចំថែទាំបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងសាលា | 3 | 21 | 10 | 72 | 1 | 7 | 0 | 0 | 0 | 0 |
| ១៥ | មានកម្មវិធីបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 1 | 7 | 7 | 50 | 4 | 29 | 1 | 7 | 1 | 7 |
| ១៦ | វាយតម្លៃការបង្រៀនរបស់គ្រូ | 1 | 7 | 10 | 72 | 1 | 7 | 1 | 7 | 1 | 7 |
| ១៧ | មាន LCD និងឧបករណ៍ ICT ផ្សេងទៀតសម្រាប់ប្រើប្រាស់ | 1 | 7 | 1 | 7 | 5 | 36 | 0 | 0 | 7 | 50 |

តាមតារាងលេខនេះ បានបង្ហាញលទ្ធផលនៃការស្រាវជ្រាវដូចតទៅ ៖

### ៤.២.១.១. ការបែងចែកគ្រូបង្រៀនទៅតាមឯកទេសវិជ្ជាជីវៈរបស់គ្រូបង្រៀននីមួយៗ

ការបែងចែកគ្រូបង្រៀនទៅតាមឯកទេសវិជ្ជាជីវៈរបស់គ្រូបង្រៀននីមួយៗ របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៤នាក់ ត្រូវជា ២៩ % កម្រិតច្រើន មានចំនួន ០៨នាក់ ត្រូវជា ៥៧ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតតិច មានចំនួន ០១នាក់ ត្រូវជា ៧ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.១.២. ការគ្រប់គ្រងបុគ្គលិក ម៉ោងចេញ ម៉ោងចូល របស់គ្រូបង្រៀន និងសិស្ស

ការគ្រប់គ្រងបុគ្គលិក ម៉ោងចេញ ម៉ោងចូលរបស់គ្រូបង្រៀន និងសិស្សានុសិស្ស របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតច្រើន មានចំនួន ០៧នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ០២នាក់ ត្រូវជា ១៤ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.១.៣. ការប្រជុំបច្ចេកទេសទៀងទាត់លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ការដឹកនាំប្រជុំបច្ចេកទេសទៀងទាត់លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា

១៤ % កម្រិតច្រើន មានចំនួន ០៧នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ០៣នាក់ ត្រូវជា ២២ % កម្រិតតិច មានចំនួន ០២នាក់ ត្រូវជា ១៤ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០.០០ % ។

### ៤.២.១.៤. ការដឹកនាំថ្នាក់និទស្សន៍អភិវឌ្ឍសមត្ថភាពគ្រូលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ការដឹកនាំថ្នាក់និទស្សន៍ អភិវឌ្ឍសមត្ថភាពគ្រូ លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ០៣នាក់ ត្រូវជា ២២ % កម្រិតមធ្យម មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតតិច មានចំនួន ០៣នាក់ ត្រូវជា ២១ % និងកម្រិតតិចបំផុត មានចំនួន ០២នាក់ ត្រូវជា ១៤ % ។

### ៤.២.១.៥. ការផ្តល់ឱកាសឱ្យគ្រូបង្រៀនទទួលបានការបំប៉នពីវិធីសាស្ត្រថ្មីៗសម្បូរបែប

ការផ្តល់ឱកាសឱ្យគ្រូបង្រៀនទទួលបានការបំប៉នពីវិធីសាស្ត្រថ្មីៗ សម្បូរបែបរបស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ២១ % កម្រិតច្រើន មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតមធ្យម មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៧. % ។

### ៤.២.១.៦. ការត្រួតពិនិត្យគ្រូក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សាលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ការត្រួតពិនិត្យគ្រូបង្រៀន ក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សា លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា ១៤ % កម្រិតច្រើន មានចំនួន ០៩នាក់ ត្រូវជា ៦៥ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតតិច មានចំនួន ០១នាក់ ត្រូវជា ៧ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % ។

### ៤.២.១.៧. កម្មវិធីប្រឡងសិស្សពូកែអក្សរសាស្ត្រខ្មែរ ដើម្បីទាក់ទាញសិស្សចូលប្រឡង

កម្មវិធីប្រឡងសិស្សពូកែអក្សរសាស្ត្រខ្មែរ ដើម្បីទាក់ទាញសិស្សចូលប្រឡង របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតច្រើន មានចំនួន ០៧នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០.០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % ។

### ៤.២.១.៨. ការទទួលនូវការបំប៉នពីក្របខណ្ឌកម្មវិធីសិក្សាថ្មី

ការទទួលបាននូវការបំប៉នពីក្របខណ្ឌកម្មវិធីសិក្សាថ្មី របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតច្រើន មានចំនួន ០៤នាក់ ត្រូវជា ២៩ % កម្រិតមធ្យម មានចំនួន ០៤នាក់ ត្រូវជា ២៩ % កម្រិតតិច មានចំនួន ០៣នាក់ ត្រូវជា ២១ % និងកម្រិតតិចបំផុត មានចំនួន ០៣នាក់ ត្រូវជា ២១ % ។

### ៤.២.១.៩. ការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់គ្រូបង្រៀន

ការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់គ្រូបង្រៀន របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា ១៥ % កម្រិតច្រើន មានចំនួន ០៧នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតតិច មានចំនួន ០២នាក់ ត្រូវជា ១៤ % និងកម្រិតតិចបំផុត មានចំនួន ០២នាក់ ត្រូវជា ១៤ % ។

### ៤.២.១.១០. ការជំរុញ និងគាំទ្រគ្រូអក្សរសាស្ត្រខ្មែរប្រើវិធីសាស្ត្របង្រៀនថ្មីៗ

ការជំរុញ និងគាំទ្រគ្រូអក្សរសាស្ត្រខ្មែរប្រើវិធីសាស្ត្របង្រៀនថ្មីៗ របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ២១ % កម្រិតច្រើន មានចំនួន ០៨នាក់ ត្រូវជា ៥៨ % កម្រិតមធ្យម មានចំនួន ០២នាក់ ត្រូវជា ១៤ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % ។

### ៤.២.១.១១. ការតាមដានលើការសិក្សារបស់សិស្សជាប្រចាំ

ការតាមដានលើការសិក្សារបស់សិស្សជាប្រចាំ របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ២១ % កម្រិតច្រើន មានចំនួន ០៩នាក់ ត្រូវជា ៦៥ % កម្រិតមធ្យម មានចំនួន ០២នាក់ ត្រូវជា ១៤ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.១.១២. ការលើកទឹកចិត្តដល់សិស្សរៀនពូកែ

ការលើកទឹកចិត្តដល់សិស្សរៀនពូកែ របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតច្រើន

មានចំនួន ០៧នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា៧ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % ។

### ៤.២.១.១៣. ការផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀន

ការផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀន របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤ វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា ១៤ % កម្រិតច្រើន មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតមធ្យម មានចំនួន ០៦នាក់ ត្រូវជា៤៣ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % ។

### ៤.២.១.១៤. ការរៀបចំថែទាំបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងសាលារៀន

ការរៀបចំថែទាំបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងសាលារៀន របស់គណៈគ្រប់គ្រងសាលារៀនទាំង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ២១ % កម្រិតច្រើន មានចំនួន ១០នាក់ ត្រូវជា ៧២ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.១.១៥. កម្មវិធីបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

កម្មវិធីបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ របស់គណៈគ្រប់គ្រងសាលារៀន ទាំង ១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ០៧នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ០៤នាក់ ត្រូវជា២៩ % កម្រិតតិច មានចំនួន ០១នាក់ ត្រូវជា ៧ % និងកម្រិតតិចបំផុត មានចំនួន០១នាក់ ត្រូវជា ៧ % ។

### ៤.២.១.១៦. ការវាយតម្លៃការបង្រៀនរបស់គ្រូបង្រៀន

ការវាយតម្លៃការបង្រៀនរបស់គ្រូបង្រៀន របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៤ វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ១០នាក់ ត្រូវជា ៧២ % កម្រិតមធ្យម មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតតិច មានចំនួន ០១នាក់ ត្រូវជា ៧ % និងកម្រិតតិចបំផុត មានចំនួន០១នាក់ ត្រូវជា ៧ % ។

៤.២.១.១៧. ការបំពាក់ LCD និងឧបករណ៍ ICTផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងពេលបង្រៀន

ការបំពាក់ LCD និងឧបករណ៍ ICT ផ្សេងទៀត សម្រាប់ប្រើប្រាស់ ក្នុងពេលបង្រៀន របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតមធ្យម មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និង កម្រិតតិចបំផុត មានចំនួន ០៧នាក់ ត្រូវជា ៥០ % ។

## ៤.២.២. លទ្ធផលនៃកម្រងសំណួររបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២

**តារាងទី៣ ៖ លទ្ធផលនៃកម្រងសំណួររបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២**

**គិតជាចំនួននាក់ និងភាគរយ**

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ច្រើនបំផុត | | ច្រើន | | មធ្យម | | តិច | | តិចបំផុត | |
| | ដំណើរការនៃការបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | ចំ. | % | ចំ | % | ចំ. | % | ចំ. | % | ចំ. | % |
| ១ | មកបង្រៀនបានទៀងទាត់ តាមម៉ោងចេញ និងម៉ោងចូល | 8 | 33 | 16 | 67 | 0 | 0 | 0 | 0 | 0 | 0 |
| ២ | មានគ្រូផ្សេងទៀតបង្រៀនជំនួស ពេលអវត្តមាន | 0 | 0 | 0 | 0 | 3 | 13 | 4 | 17 | 17 | 70 |
| ៣ | មានកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការ | 7 | 29 | 8 | 33 | 9 | 38 | 0 | 0 | 0 | 0 |
| ៤ | បានដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែកិច្ចការសិស្ស | 6 | 25 | 16 | 67 | 2 | 8 | 0 | 0 | 0 | 0 |
| ៥ | បានវាយតម្លៃលទ្ធផលសិក្សាសិស្សក្នុងពេល ក្រោយបង្រៀន | 7 | 29 | 14 | 58 | 3 | 13 | 0 | 0 | 0 | 0 |
| ៦ | បានផ្តល់សៀវភៅតាមដានការសិក្សាដល់អាណាព្យាបាល | 9 | 38 | 8 | 33 | 7 | 29 | 0 | 0 | 0 | 0 |
| ៧ | បានផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន | 3 | 13 | 6 | 25 | 12 | 50 | 2 | 8 | 1 | 4 |
| ៨ | បានប្រើប្រាស់សម្ភារៈឧបទេសក្នុងពេលបង្រៀន | 3 | 13 | 5 | 20 | 16 | 67 | 0 | 0 | 0 | 0 |
| ៩ | ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រង | 2 | 8 | 9 | 38 | 12 | 50 | 0 | 0 | 1 | 4 |
| ១០ | ធ្លាប់ទទួលបានការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មី | 2 | 8 | 10 | 42 | 6 | 25 | 0 | 0 | 6 | 25 |
| ១១ | មានភាពលម្អៀងចំពោះសិស្សក្នុងពេលបង្រៀន | 0 | 0 | 0 | 0 | 4 | 17 | 0 | 0 | 20 | 83 |
| ១២ | បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបរិះរក (IBL) | 0 | 0 | 13 | 54 | 4 | 17 | 1 | 4 | 6 | 25 |
| ១៣ | បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL) | 0 | 0 | 9 | 38 | 5 | 20 | 2 | 8 | 8 | 34 |
| ១៤ | បានប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងពេលបង្រៀន | 7 | 29 | 15 | 63 | 2 | 8 | 0 | 0 | 0 | 0 |
| ១៥ | បានប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌលក្នុងពេលបង្រៀន | 1 | 4 | 5 | 20 | 13 | 55 | 4 | 17 | 1 | 4 |
| ១៦ | បានបង្រៀនតាមកាលវិភាគដែលគណៈគ្រប់គ្រងបានកំណត់ | 10 | 42 | 14 | 58 | 0 | 0 | 0 | 0 | 0 | 0 |
| ១៧ | បានបង្រៀនចប់តាមកម្មវិធីសិក្សាដែលក្រសួងបានកំណត់ | 8 | 34 | 9 | 38 | 7 | 28 | 0 | 0 | 0 | 0 |

### ៤.២.២.១. ការមកបង្រៀនបានទៀងទាត់តាមម៉ោងចេញម៉ោងចូល

ការមកបង្រៀនបានទៀងទាត់តាមម៉ោងចេញម៉ោងចូល របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៨នាក់ ត្រូវជា ៣៣ % កម្រិតច្រើន មានចំនួន ១៦នាក់ ត្រូវជា ៦៧ % កម្រិតមធ្យម មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និង កម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.២. មានគ្រូបង្រៀនអក្សរសាស្ត្រខ្មែរផ្សេងទៀតជំនួស ពេលអវត្តមាន

ការមានគ្រូបង្រៀនអក្សរសាស្ត្រខ្មែរផ្សេងទៀតជំនួស ពេលអវត្តមាន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតច្រើន មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតមធ្យម មានចំនួន ០៣នាក់ ត្រូវជា ១៣ % កម្រិតតិច មានចំនួន ០៤នាក់ ត្រូវជា ១៧ % និងកម្រិតតិចបំផុត មានចំនួន ១៧នាក់ ត្រូវជា ៧០ % ។

### ៤.២.២.៣. មានកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការបានទៀងទាត់

ការមានកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការបានទៀងទាត់ របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៧នាក់ ត្រូវជា ២៩ % កម្រិតច្រើន មានចំនួន ០៨នាក់ ត្រូវជា ៣៣ % កម្រិតមធ្យម មានចំនួន ០៩នាក់ ត្រូវជា ៣៨ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.៤. បានដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែកិច្ចការសិស្សជាប្រចាំ

ការដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែកិច្ចការសិស្សជាប្រចាំ របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៦នាក់ ត្រូវជា ២៥ % កម្រិតច្រើន មានចំនួន ១៦នាក់ ត្រូវជា ៦៧ % កម្រិតមធ្យម មានចំនួន ០២នាក់ ត្រូវជា ៨ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.៥. បានវាយតម្លៃលទ្ធផលសិក្សាសិស្សជាប្រចាំ មុន ឬក្រោយពេលបង្រៀន

ការបានវាយតម្លៃលទ្ធផលសិក្សាសិស្សជាប្រចាំ មុន ឬក្រោយពេលបង្រៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជាកម្រិត

ច្រើនបំផុត មានចំនួន ០៧នាក់ ត្រូវជា ២៩ % កម្រិតច្រើន មានចំនួន ១៤នាក់ ត្រូវជា ៥៨ % កម្រិតមធ្យម មានចំនួន ០៣នាក់ ត្រូវជា ១៣ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.៦. ការផ្ដល់សៀវភៅតាមដានការសិក្សាសិស្សដល់អាណាព្យាបាលសិស្ស

ការផ្ដល់សៀវភៅតាមដានការសិក្សាសិស្សដល់អាណាព្យាបាលសិស្សរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៩នាក់ ត្រូវជា ៣៨ % កម្រិតច្រើន មានចំនួន ០៨នាក់ ត្រូវជា ៣៣ % កម្រិតមធ្យម មានចំនួន ០៧នាក់ ត្រូវជា ២៩ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.៧ ការផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន

ការផលិតសម្ភារៈឧបទេសសម្រាប់បង្រៀនរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ១៣ % កម្រិតច្រើន មានចំនួន ០៦នាក់ ត្រូវជា ២៥ % កម្រិតមធ្យម មានចំនួន ១២ នាក់ ត្រូវជា ៥០ % កម្រិតតិច មានចំនួន ០២នាក់ ត្រូវជា ៨ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៤ % ។

### ៤.២.២.៨. ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បង្រៀន

ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បង្រៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ១៣ % កម្រិតច្រើន មានចំនួន ០៥នាក់ ត្រូវជា ២០ % កម្រិតមធ្យម មានចំនួន ១៦នាក់ ត្រូវជា ៦៧ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.៩. ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រងសាលារៀន

ការធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រងសាលារៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា ៨ % កម្រិតច្រើន មានចំនួន ០៩នាក់ ត្រូវជា ៣៨ % កម្រិតមធ្យម មានចំនួន ១២នាក់ ត្រូវជា ៥០ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៤ % ។

### ៤.២.២.១០. ធ្លាប់ទទួលបានការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីរបស់ក្រសួង

ការធ្លាប់ទទួលបានការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីរបស់ក្រសួង របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា ៨ % កម្រិតច្រើន មានចំនួន ១០នាក់ ត្រូវជា ៤២ % កម្រិតមធ្យម មានចំនួន ០៦នាក់ ត្រូវជា ២៥ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០៦នាក់ ត្រូវជា ២៥ % ។

### ៤.២.២.១១. មានភាពលម្អៀងចំពោះសិស្សក្នុងពេលបង្រៀន

ការមានភាពលម្អៀងចំពោះសិស្ស ក្នុងពេលបង្រៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតច្រើន មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតមធ្យម មានចំនួន ០៤នាក់ ត្រូវជា ១៧ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ២០នាក់ ត្រូវជា ៨៣ % ។

### ៤.២.២.១២. ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបរិះរក (IBL) ក្នុងពេលបង្រៀន

ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបរិះរក (IBL) ក្នុងពេលបង្រៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតច្រើន មានចំនួន ១៣នាក់ ត្រូវជា ៥៤ % កម្រិតមធ្យម មានចំនួន ០៤នាក់ ត្រូវជា ១៧ % កម្រិតតិច មានចំនួន ០១នាក់ ត្រូវជា ៤ % និងកម្រិតតិចបំផុត មានចំនួន ០៦នាក់ ត្រូវជា ២៥ % ។

### ៤.២.២.១៣. ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL) ក្នុងពេលបង្រៀន

ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL) ក្នុងពេលបង្រៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតច្រើន មានចំនួន ០៩នាក់ ត្រូវជា ៣៨ % កម្រិតមធ្យម មានចំនួន ០៥នាក់ ត្រូវជា ២០ % កម្រិតតិច មានចំនួន ០២នាក់ ត្រូវជា ៨ % និងកម្រិតតិចបំផុត មានចំនួន ០៨នាក់ ត្រូវជា ៣៤ % ។

### ៤.២.២.១៤. ការប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល ក្នុងពេលបង្រៀន

ការប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល ក្នុងពេលបង្រៀន របស់គ្រូបង្រៀនអក្សរ

សាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៧នាក់ ត្រូវជា ២៩ % កម្រិតច្រើន មានចំនួន ១៥នាក់ ត្រូវជា ៦៣ % កម្រិតមធ្យម មានចំនួន ០២នាក់ ត្រូវជា ៨ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.១៥. ការប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌល ក្នុងពេលបង្រៀន

ការប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌល ក្នុងពេលបង្រៀន របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៤ % កម្រិតច្រើន មានចំនួន ០៥នាក់ ត្រូវជា ២០ % កម្រិតមធ្យម មានចំនួន ១៣នាក់ ត្រូវជា ៥៥ % កម្រិតតិច មានចំនួន ០៤នាក់ ត្រូវជា ១៧ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៤ % ។

### ៤.២.២.១៦. ការបង្រៀនតាមកាលវិភាគដែលគណៈគ្រប់គ្រងបានកំណត់

ការបង្រៀនតាមកាលវិភាគដែលគណៈគ្រប់គ្រងបានកំណត់ របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ១០នាក់ ត្រូវជា ៤២ % កម្រិតច្រើន មានចំនួន ១៤នាក់ ត្រូវជា ៥៨ % កម្រិតមធ្យម មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

### ៤.២.២.១៧. ការបង្រៀនតាមកម្មវិធីសិក្សាដែលក្រសួង បានកំណត់

ការបង្រៀនតាមកម្មវិធីសិក្សាដែលក្រសួង បានកំណត់ របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ០៨នាក់ ត្រូវជា ៣៤ % កម្រិតច្រើន មានចំនួន ០៩នាក់ ត្រូវជា ៣៨ % កម្រិតមធ្យម មានចំនួន ០៧នាក់ ត្រូវជា ២៨ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។

## ៤.២.៣. លទ្ធផលនៃកម្រងសំណួររបស់សិស្សានុសិស្ស ថ្នាក់ទី១២

### តារាងទី៤ ៖ លទ្ធផលនៃកម្រងសំណួររបស់សិស្សានុសិស្ស ថ្នាក់ទី១២

### គិតជាចំនួននាក់ និងភាគរយ

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ច្រើនបំផុត | | ច្រើន | | មធ្យម | | តិច | | តិចបំផុត | |
| | ដំណើរការនៃការរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | ចំ. | % | ចំ. | % | ចំ. | % | ចំ. | % | ចំ. | % |
| ១ | មករៀនបានទៀងទាត់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 599 | 47 | 585 | 45 | 107 | 8 | 5 | 0 | 4 | 0 |
| ២ | ចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 351 | 27 | 621 | 48 | 298 | 23 | 24 | 2 | 6 | 0 |
| ៣ | បង្កើតក្លឹបសិក្សា និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ | 20 | 2 | 198 | 15 | 600 | 46 | 327 | 25 | 155 | 12 |
| ៤ | បានធ្វើកិច្ចការគ្រូ និងបានទទួលការកែលម្អពីគ្រូជាប្រចាំ | 213 | 16 | 543 | 42 | 410 | 32 | 108 | 8 | 26 | 2 |
| ៥ | ចូលរួមវាយតម្លៃលទ្ធផលសិក្សាពេលរៀន ឬក្រោយបង្រៀន | 96 | 7 | 436 | 34 | 580 | 45 | 143 | 10 | 45 | 4 |
| ៦ | បានទទួលសៀវភៅតាមដានការសិក្សាពីគ្រូបង្រៀន | 527 | 41 | 443 | 34 | 246 | 19 | 56 | 4 | 28 | 2 |
| ៧ | មានភាពក្លាហានក្នុងការឆ្លើយសំណួររបស់គ្រូ | 148 | 11 | 442 | 34 | 593 | 45 | 97 | 8 | 20 | 2 |
| ៨ | សហការគ្នាពិភាក្សាជាក្រុម ក្នុងពេលរៀន | 271 | 21 | 520 | 40 | 357 | 28 | 111 | 8 | 41 | 3 |
| ៩ | បានជួយមិត្តភក្តិពេលម៉ោងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 142 | 11 | 395 | 30 | 531 | 41 | 180 | 14 | 52 | 4 |
| ១០ | យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ពេលម៉ោងរៀន | 482 | 37 | 643 | 50 | 156 | 11 | 12 | 1 | 7 | 1 |
| ១១ | រៀនគួរបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 256 | 20 | 434 | 33 | 325 | 25 | 169 | 13 | 116 | 9 |
| ១២ | ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបរិះរក (IBL) | 75 | 6 | 350 | 27 | 532 | 41 | 224 | 17 | 119 | 9 |
| ១៣ | ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបបញ្ញត្តិ (CBL) | 47 | 4 | 240 | 19 | 568 | 44 | 285 | 22 | 160 | 11 |
| ១៤ | ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល | 86 | 7 | 294 | 23 | 522 | 40 | 256 | 20 | 142 | 10 |
| ១៥ | ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល | 136 | 11 | 342 | 26 | 449 | 35 | 225 | 17 | 148 | 11 |

### ៤.២.៣.១. ការមករៀនបានទៀងទាត់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ការមករៀនបានទៀងទាត់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង១៣០០នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៥៩៩នាក់ ត្រូវជា ៤៧ % កម្រិតច្រើន មានចំនួន ៥៨៥នាក់ ត្រូវជា ៤៥ % កម្រិតមធ្យម មានចំនួន ១០៧នាក់ ត្រូវជា ៨ % កម្រិតតិច មានចំនួន ០៥នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០៤នាក់ ត្រូវជា ០០ % ។

### ៤.២.៣.២. ការចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ការចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរថ្នាក់ទី១២ ទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៣៥១នាក់ ត្រូវជា ២៧ % កម្រិតច្រើន មានចំនួន ៦២១នាក់ ត្រូវជា ៤៨ % កម្រិតមធ្យម មានចំនួន ២៩៨នាក់ ត្រូវជា ២៣ % កម្រិតតិច មានចំនួន ២៤នាក់ ត្រូវជា ២ % និងកម្រិតតិចបំផុត មានចំនួន ០៦នាក់ ត្រូវជា ០០ % ។

### ៤.២.៣.៣. ការបង្កើតក្លឹបសិក្សាដោយខ្លួនឯង និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ

ការបង្កើតក្លឹបសិក្សាដោយខ្លួនឯង និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ ទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ២០នាក់ ត្រូវជា ២ % កម្រិតច្រើន មានចំនួន ១៩៨នាក់ ត្រូវជា ១៥ % កម្រិតមធ្យម មានចំនួន ៦០០នាក់ ត្រូវជា ៤៦ % កម្រិតតិច មានចំនួន ៣២៧នាក់ ត្រូវជា ២៥ % និងកម្រិតតិចបំផុត មានចំនួន ១៥៥នាក់ ត្រូវជា ១២ % ។

### ៤.២.៣.៤. ការធ្វើកិច្ចការដែលគ្រូបានដាក់ឱ្យ និងទទួលបានការកែលម្អពីគ្រូជាប្រចាំ

ការធ្វើកិច្ចការដែលគ្រូបានដាក់ឱ្យ និងទទួលបានការកែលម្អពីគ្រូជាប្រចាំ ទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ២១៣នាក់ ត្រូវជា ១៦ % កម្រិតច្រើន មានចំនួន ៥៤៣នាក់ ត្រូវជា ៤២ % កម្រិតមធ្យម មានចំនួន ៤១០នាក់ ត្រូវជា ៣២ % កម្រិតតិច មានចំនួន ១០៨នាក់ ត្រូវជា ៨ % និងកម្រិតតិចបំផុត មានចំនួន ២៦នាក់ ត្រូវជា ២ % ។

### ៤.២.៣.៥. ការចូលរួមក្នុងការវាយតម្លៃលទ្ធផលសិក្សា ក្នុងពេល ឬក្រោយពេលរៀនចប់

ការចូលរួមក្នុងការវាយតម្លៃលទ្ធផលសិក្សា ក្នុងពេល ឬក្រោយពេលរៀនមេរៀនចប់ ទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៩៦នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ៤៣៦នាក់ ត្រូវជា ៣៤ % កម្រិតមធ្យម មានចំនួន ៥៨០នាក់ ត្រូវជា ៤៥ % កម្រិតតិច មានចំនួន ១៤៣នាក់ ត្រូវជា ១០ % និងកម្រិតតិចបំផុត មានចំនួន ៤៥នាក់ ត្រូវជា ៤ % ។

### ៤.២.៣.៦. ការទទួលបានសៀវភៅតាមដានការសិក្សាពីគ្រូបង្រៀនបានទៀងទាត់

ការទទួលបានសៀវភៅតាមដានការសិក្សាពីគ្រូបង្រៀន បានទៀងទាត់ ទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៥២៧នាក់ ត្រូវជា

៤១ % កម្រិតច្រើន មានចំនួន ៥៤៣នាក់ ត្រូវជា ៣៤ % កម្រិតមធ្យម មានចំនួន ២៤៦ នាក់ ត្រូវជា ១៩ % កម្រិតតិច មានចំនួន ៥៦នាក់ ត្រូវជា ៤ % និងកម្រិតតិចបំផុត មានចំនួន ២៨នាក់ ត្រូវជា ២ % ។

**៤.២.៣.៧. មានភាពក្លាហានក្នុងការឆ្លើយសំណួររបស់គ្រូបង្រៀន**

សិស្សដែលមានភាពក្លាហានក្នុងការឆ្លើយសំណួរ របស់គ្រូបង្រៀន ទាំង១៣០០នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ១៤៨នាក់ ត្រូវជា ១១ % កម្រិតច្រើន មានចំនួន ៤៤២នាក់ ត្រូវជា ៣៤ % កម្រិតមធ្យម មានចំនួន ៥៩៣នាក់ ត្រូវជា ៤៥ % កម្រិតតិច មានចំនួន ៩៧នាក់ ត្រូវជា ៨ % និងកម្រិតតិចបំផុត មានចំនួន ២០នាក់ ត្រូវជា ២ % ។

**៤.២.៣.៨. សហការគ្នាពិភាក្សាជាក្រុម ក្នុងពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ**

សិស្សសហការគ្នាពិភាក្សាជាក្រុម ក្នុងពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ទាំង១៣០០ នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ២៧១នាក់ ត្រូវជា ២១ % កម្រិតច្រើន មានចំនួន ៥២០នាក់ ត្រូវជា ៤០ % កម្រិតមធ្យម មានចំនួន ៣៥៧ នាក់ ត្រូវជា ២៨ % កម្រិតតិច មានចំនួន ១១១នាក់ ត្រូវជា ៨ % និងកម្រិតតិចបំផុត មានចំនួន ៤១នាក់ ត្រូវជា ៣ % ។

**៤.២.៣.៩. ការជួយមិត្តភក្តិពេលម៉ោងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ**

ការជួយមិត្តភក្តិ ក្នុងម៉ោងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ទាំង១៣០០នាក់នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ១៤២នាក់ ត្រូវជា ១១ % កម្រិតច្រើន មានចំនួន ៣៩៥នាក់ ត្រូវជា ៣០ % កម្រិតមធ្យម មានចំនួន ៥៣១នាក់ ត្រូវជា ៤១ % កម្រិតតិច មានចំនួន ១៨០នាក់ ត្រូវជា ១៤ % និងកម្រិតតិចបំផុត មានចំនួន ៥២នាក់ ត្រូវជា ៤ % ។

**៤.២.៣.១០. ការយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ**

ការយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ទាំង១៣០០ នាក់ នៅក្នុង១៥វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៤៨២នាក់ ត្រូវជា ៣៧ % កម្រិតច្រើន មានចំនួន ៦៤៣នាក់ ត្រូវជា ៥០ % កម្រិតមធ្យម មានចំនួន ១៥៦ នាក់ ត្រូវជា ១១ % កម្រិតតិច មានចំនួន ១២នាក់ ត្រូវជា ១ % និងកម្រិតតិចបំផុត មានចំនួន ០៧នាក់ ត្រូវជា ១ % ។

### ៤.២.៣.១១. ការរៀនគួរបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

ការរៀនគួរបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ទាំង១៣០០នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ២៥៦នាក់ ត្រូវជា ២០ % កម្រិតច្រើន មានចំនួន ៤៣៤នាក់ ត្រូវជា ៣៣ % កម្រិតមធ្យម មានចំនួន ៣២៥នាក់ ត្រូវជា ២៥ % កម្រិតតិច មានចំនួន ១៦៩នាក់ ត្រូវជា ១៣ % និងកម្រិតតិចបំផុត មានចំនួន ១១៦នាក់ ត្រូវជា ៩ % ។

### ៤.២.៣.១២. ការធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបរិះរក (IBL)

ការធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបរិះរក (IBL) ទាំង១៣០០នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៧៥នាក់ ត្រូវជា ៦ % កម្រិតច្រើន មានចំនួន ៣៥០នាក់ ត្រូវជា ២៧ % កម្រិតមធ្យម មានចំនួន ៥៣២នាក់ ត្រូវជា ៤១ % កម្រិតតិច មានចំនួន ២២៤នាក់ ត្រូវជា ១៧ % និងកម្រិតតិចបំផុត មានចំនួន ១១៩នាក់ ត្រូវជា ៩ % ។

### ៤.២.៣.១៣. ការធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបបញ្ញត្តិ (CBL)

ការធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបបញ្ញត្តិ (CBL) ទាំង១៣០០នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៤៧នាក់ ត្រូវជា ៤ % កម្រិតច្រើន មានចំនួន ២៤០នាក់ ត្រូវជា ១៩ % កម្រិតមធ្យម មានចំនួន ៥៦៨នាក់ ត្រូវជា ៤៤ % កម្រិតតិច មានចំនួន ២៨៥នាក់ ត្រូវជា ២២ % និងកម្រិតតិចបំផុត មានចំនួន ១៦០នាក់ ត្រូវជា ១១ % ។

### ៤.២.៣.១៤. ការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល

ការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល ទាំង១៣០០នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ៨៦នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ២៩៤នាក់ ត្រូវជា ២៣ % កម្រិតមធ្យម មានចំនួន ៥២២នាក់ ត្រូវជា ៤០ % កម្រិតតិច មានចំនួន ២៥៦នាក់ ត្រូវជា ២០ % និងកម្រិតតិចបំផុត មានចំនួន ១៤២នាក់ ត្រូវជា ១០ % ។

### ៤.២.៣.១៥ ការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល

ការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល ទាំង១៣០០នាក់ នៅក្នុង១៨វិទ្យាល័យ ដូចជា កម្រិតច្រើនបំផុត មានចំនួន ១៣៦នាក់ ត្រូវជា ១១ % កម្រិត

ច្រើន មានចំនួន ៣៤២នាក់ ត្រូវជា ២៦ % កម្រិតមធ្យម មានចំនួន ៤៩៩នាក់ ត្រូវជា ៣៥ % កម្រិតតិច មានចំនួន ២២៥នាក់ ត្រូវជា ១៧ % និងកម្រិតតិចបំផុត មាន ចំនួន ១៤៨នាក់ ត្រូវជា ១១ % ។

# ជំពូកទី៥
# ការពិភាក្សា សន្និដ្ឋាន និងសំណូមពរ

## ៥.១. ការពិភាក្សា

ការសិក្សាស្រាវជ្រាវខាងលើនេះ ផ្តោតទៅលើវត្ថុបំណងសំខាន់ៗចំនួនពីរគឺ ៖

១. សិក្សាពីស្ថានភាពនៃការដឹកនាំ គ្រប់គ្រង ការបង្រៀន ការរៀន និងបញ្ហាប្រឈមនានា ដែលបានជួបប្រទះក្នុងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២

២. សិក្សាពីវិធានការដោះស្រាយនូវបញ្ហាប្រឈមនានា ក្នុងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ។

### ៥.១.១. ការពិភាក្សាលើវត្ថុបំណងទី១

៥.១.១.១. បញ្ហាប្រឈមរបស់គណៈគ្រប់គ្រងសាលារៀន

តារាងលទ្ធផលវិភាគ របស់គណៈគ្រប់គ្រងសាលារៀន គិតជាចំនួននាក់ និងភាគរយ

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ច្រើនបំផុត | | ច្រើន | | មធ្យម | | តិច | | តិចបំផុត | |
| | ការដឹកនាំ និងគ្រប់គ្រង | ចំ. | % | ចំ | % | ចំ. | % | ចំ. | % | ចំ. | % |
| ១ | ការបែងចែកគ្រូទៅតាមឯកទេសវិជ្ជាជីវៈរបស់គ្រូនីមួយៗ | 4 | 29 | 8 | 57 | 1 | 7 | 1 | 7 | 0 | 0 |
| ២ | ការគ្រប់គ្រងបុគ្គលិក ម៉ោងចេញ ម៉ោងចូលរបស់គ្រូ សិស្ស | 5 | 36 | 7 | 50 | 2 | 14 | 0 | 0 | 0 | 0 |
| ៣ | ប្រជុំបច្ចេកទេសទៀងទាត់លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 2 | 14 | 7 | 50 | 3 | 22 | 2 | 14 | 0 | 0 |
| ៤ | ការដឹកនាំថ្នាក់និទស្សន៍អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន | 1 | 7 | 3 | 22 | 5 | 36 | 3 | 21 | 2 | 14 |
| ៥ | ផ្តល់ឱកាសឲ្យគ្រូបង្រៀនទទួលបានការបំប៉នពីវិធីសាស្ត្រថ្មីៗ | 3 | 21 | 5 | 36 | 5 | 36 | 0 | 0 | 1 | 7 |
| ៦ | ត្រួតពិនិត្យគ្រូបង្រៀនក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សា | 2 | 14 | 9 | 65 | 1 | 7 | 1 | 7 | 1 | 7 |
| ៧ | កម្មវិធីប្រឡងសិស្សពូកែអក្សរសាស្ត្រខ្មែរ ទាក់ទាញសិស្ស | 5 | 36 | 7 | 50 | 1 | 7 | 0 | 0 | 1 | 7 |
| ៨ | ទទួលបានការបំប៉នពីក្របខណ្ឌកម្មវិធីសិក្សាថ្មី | 0 | 0 | 4 | 29 | 4 | 29 | 3 | 21 | 3 | 21 |
| ៩ | ផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់គ្រូបង្រៀន | 2 | 15 | 7 | 50 | 1 | 7 | 2 | 14 | 2 | 14 |
| ១០ | ជំរុញ និងគាំទ្រគ្រូឱ្យប្រើវិធីសាស្ត្របង្រៀនថ្មីៗ | 3 | 21 | 8 | 58 | 2 | 14 | 0 | 0 | 1 | 7 |
| ១១ | ការតាមដានលើការសិក្សារបស់សិស្សជាប្រចាំ | 3 | 21 | 9 | 65 | 2 | 14 | 0 | 0 | 0 | 0 |
| ១២ | ការលើកទឹកចិត្តដល់សិស្សរៀនពូកែ | 5 | 36 | 7 | 50 | 1 | 7 | 0 | 0 | 1 | 7 |
| ១៣ | ផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀន | 2 | 14 | 5 | 36 | 6 | 43 | 0 | 0 | 1 | 7 |
| ១៤ | រៀបចំថែទាំបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងសាលា | 3 | 21 | 10 | 72 | 1 | 7 | 0 | 0 | 0 | 0 |
| ១៥ | មានកម្មវិធីបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 1 | 7 | 7 | 50 | 4 | 29 | 1 | 7 | 1 | 7 |
| ១៦ | វាយតម្លៃការបង្រៀនរបស់គ្រូ | 1 | 7 | 10 | 72 | 1 | 7 | 1 | 7 | 1 | 7 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១៧ | មាន LCD និងឧបករណ៍ ICT ផ្សេងទៀតសម្រាប់ប្រើប្រាស់ | 1 | 7 | 1 | 7 | 5 | 36 | 0 | 0 | 7 | 50 |

តាមរយៈលទ្ធផលនៅក្នុងតារាងវិភាគរបស់ គណៈគ្រប់គ្រងសាលារៀន បានបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវ ស្ដីពីបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលគណៈគ្រប់គ្រងវិទ្យាល័យទាំង១៤នាក់ បានលើកឡើងដូចជា ៖

**ក. បញ្ហាប្រឈមទី១ " ការដឹកនាំធ្វើថ្នាក់និទស្សន៍ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន "**

ការដឹកនាំប្រជុំបច្ចេកទេស ជាការងារសំខាន់ក្នុងការផ្លាស់ប្ដូរយោបល់ រវាងគ្រូបង្រៀន និងគ្រូបង្រៀន និងដោះស្រាយបញ្ហាលើវិធីសាស្ត្របង្រៀន ការបង្ហាញពីការលំបាកក្នុងពេលបង្រៀន ដោយប្រធានក្រុមបច្ចេកទេសជាអ្នកដឹកនាំ និងមានការចូលរួមជាមួយនាយកសាលាក្នុងគោលបំណងរៀបចំដំណើរការ នូវការធ្វើថ្នាក់និទស្សន៍ប្រចាំខែ ថ្នាក់សាលារៀន ឬថ្នាក់កម្រងសាលារៀន ចែករំលែកនូវចំណេះដឹង និងបទពិសោធក្នុងការបង្រៀនឱ្យគ្នា ទៅវិញទៅមក។ ជាក់ស្ដែងតាមរយៈលទ្ធផលនៃកម្រងសំណួរលើគណៈគ្រប់គ្រងសាលារៀនបានបង្ហាញថា ការដឹកនាំធ្វើថ្នាក់និទស្សន៍ ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរថ្នាក់ទី១២ នៅមានកម្រិតនៅឡើយ គឺលទ្ធផលកម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ០៣នាក់ ត្រូវជា ២២ % កម្រិតមធ្យម មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតតិច មានចំនួន ០៣នាក់ ត្រូវជា ២១ % និងកម្រិតតិចបំផុត មានចំនួន ០២នាក់ ត្រូវជា ១៤ % ។ លទ្ធផលនេះ សបញ្ជាក់ឱ្យឃើញថា ការដឹកនាំ និងរៀបចំសកម្មភាពនេះនៅមានចំណុចខ្វះខាត ទាមទារឱ្យមានការកែលម្អ ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនបន្ថែមទៀត ។

**ខ. បញ្ហាប្រឈមទី២ " ការទទួលបានការបំប៉នពីក្របខណ្ឌនៃកម្មវិធីសិក្សាថ្មី "**

ក្របខណ្ឌកម្មវិធីសិក្សាថ្មី ជាធាតុចូលមួយដ៏មានសារៈសំខាន់បំផុត សម្រាប់ផ្ដល់ឱ្យទៅតាមសាលារៀន ដោយគ្រូបង្រៀនទាំងអស់នៅទូទាំងប្រទេស ត្រូវអនុវត្តរួមគ្នានូវក្របខណ្ឌនៃកម្មវិធីសិក្សាថ្មី ដែលក្រសួងអប់រំបានកំណត់ឱ្យប្រើប្រាស់ ។ កម្មវិធីសិក្សា ជាអ្នកនាំផ្លូវដល់គ្រូបង្រៀន ដោយគ្រូបង្រៀនត្រូវបង្រៀនឱ្យស្របទៅតាមខ្លឹមសារមេរៀនថ្មី ដែលបានអភិវឌ្ឍក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្មីផងដែរ ។ កម្មវិធីសិក្សាថ្មី បានកំណត់យ៉ាងច្បាស់នូវចំណេះដឹងជាក់លាក់ សម្រាប់ឱ្យសិស្សានុសិស្សទទួលបាន នៅពេលដែលពួកគេបានបញ្ចប់ភូមិសិក្សានីមួយៗ ។ យ៉ាងណាមិញ គ្រូបង្រៀន និងនាយកសាលាត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់

និងស៊ីជម្រៅថា តើកម្មវិធីសិក្សាចង់បានលទ្ធផលសម្រេចយ៉ាងដូចម្ដេច ? ស្របទៅនឹងគោលនយោបាយរបស់ក្រសួងបានចងក្រងឡើងដែរឬទេ ? ដូច្នេះហើយ ទើបក្រសួងអប់រំ បានកែប្រែនូវកម្មវិធីសិក្សាថ្មី ឱ្យស្របទៅនឹងបរិបទសង្គមកម្ពុជាបច្ចុប្បន្ននេះ ហើយថែមទាំងបានផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលជូនដល់នាយកសាលារៀន និងគ្រូបង្រៀនឱ្យបានទូលំទូលាយ ដើម្បីគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ។ តាមរយៈលទ្ធផលនៃកម្រងសំណួរលើគណៈគ្រប់គ្រងសាលារៀនបានបង្ហាញថា ការទទួលបានការបំប៉ន ពីក្របខណ្ឌកម្មវិធីសិក្សាថ្មី សម្រាប់កម្រិតច្រើនបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % កម្រិតច្រើន មានចំនួន ០៥នាក់ ត្រូវជា ២៩ % កម្រិតមធ្យម មានចំនួន ០៤នាក់ ត្រូវជា២៩ % កម្រិតតិច មានចំនួន ០៣នាក់ ត្រូវជា ២១ % និងកម្រិតតិចបំផុត មានចំនួន ០៣នាក់ ត្រូវជា ២១ % ។ តាមរយៈលទ្ធផលខាងលើ យើងអាចវាយតម្លៃបានថា ការបំប៉ន និងផ្សព្វផ្សាយនូវក្របខណ្ឌនៃកម្មវិធីសិក្សាថ្មីដល់គណៈគ្រប់គ្រង និងគ្រូបង្រៀននៅតាមមូលដ្ឋាននៅមានកម្រិតនៅឡើយ ពុំទាន់បានឆ្លើយតបពេញលេញទៅនឹងគោលដៅនៃការអប់រំ ដើម្បីធានាគុណភាព និងប្រសិទ្ធភាពអប់រំ។

**គ.បញ្ហាប្រឈមទី៣ " ការបំពាក់LCD និងឧបករណ៍ICTសម្រាប់ប្រើក្នុងពេលបង្រៀន "**

ការបង្រៀន និងរៀន ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ក្នុងយុគសម័យឌីជីថលពិតជាមានសារប្រយោជន៍ខ្លាំងណាស់ ក្នុងការជួយសម្រួលដល់គ្រូបង្រៀន ឱ្យបង្រៀនសិស្សបានល្អប្រកបដោយគុណភាព ស្របតាមបរិបទថ្មីនៃការអប់រំនៅក្នុងសតវត្សទី២១នេះ ។ តាមរយៈលទ្ធផលនៃកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀនបានបង្ហាញថា ការបំពាក់ LCD និងឧបករណ៍ ICT ផ្សេងទៀត សម្រាប់ប្រើប្រាស់ ក្នុងពេលបង្រៀន របស់គណៈគ្រប់គ្រងសាលារៀន ទាំង១៤វិទ្យាល័យ សម្រាប់កម្រិតច្រើនបំផុត មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ០១នាក់ ត្រូវជា ៧ % កម្រិតមធ្យម មានចំនួន ០៥នាក់ ត្រូវជា ៣៦ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុតមានចំនួន ០៧នាក់ ត្រូវជា ៥០ % ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ ពីកង្វះខាតនៃការប្រើប្រាស់ LCD និងឧបករណ៍ ICT ផ្សេងទៀតសម្រាប់ប្រើប្រាស់ ក្នុងពេលបង្រៀន នៅតាមវិទ្យាល័យទាំង១៤ នៅពុំទាន់បានគ្រប់គ្រាន់ និងធានាបាននូវប្រសិទ្ធភាពនៅឡើយ ព្រមជាមួយនឹងចំណេះដឹងផ្នែក បច្ចេកវិទ្យាព័ត៌មានវិទ្យារបស់គ្រូបង្រៀននៅតាមសាលារៀន ក៏នៅមានកម្រិតទាបនៅឡើយផងដែរ ។

### ៥.១.១.២. បញ្ហាប្រឈមរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២

### តារាងលទ្ធផលវិភាគរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ គិតជាចំនួននាក់ និងភាគរយ

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ច្រើនបំផុត | | ច្រើន | | មធ្យម | | តិច | | តិចបំផុត | |
| | ដំណើរការនៃការបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | ចំ. | % | ចំ | % | ចំ. | % | ចំ. | % | ចំ. | % |
| ១ | មកបង្រៀនបានទៀងទាត់ តាមម៉ោងចេញ និងម៉ោងចូល | 8 | 33 | 16 | 67 | 0 | 0 | 0 | 0 | 0 | 0 |
| ២ | មានគ្រូផ្សេងទៀតបង្រៀនជំនួស ពេលអវត្តមាន | 0 | 0 | 0 | 0 | 3 | 13 | 4 | 17 | 17 | 70 |
| ៣ | មានកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការ | 7 | 29 | 8 | 33 | 9 | 38 | 0 | 0 | 0 | 0 |
| ៤ | បានដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែកិច្ចការសិស្ស | 6 | 25 | 16 | 67 | 2 | 8 | 0 | 0 | 0 | 0 |
| ៥ | បានវាយតម្លៃលទ្ធផលសិក្សាសិស្សក្នុងពេល ក្រោយបង្រៀន | 7 | 29 | 14 | 58 | 3 | 13 | 0 | 0 | 0 | 0 |
| ៦ | បានផ្តល់សៀវភៅតាមដានការសិក្សាដល់អាណាព្យាបាល | 9 | 38 | 8 | 33 | 7 | 29 | 0 | 0 | 0 | 0 |
| ៧ | បានផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន | 3 | 13 | 6 | 25 | 12 | 50 | 2 | 8 | 1 | 4 |
| ៨ | បានប្រើប្រាស់សម្ភារៈឧបទេសក្នុងពេលបង្រៀន | 3 | 13 | 5 | 20 | 16 | 67 | 0 | 0 | 0 | 0 |
| ៩ | ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រង | 2 | 8 | 9 | 38 | 12 | 50 | 0 | 0 | 1 | 4 |
| ១០ | ធ្លាប់ទទួលបានការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មី | 2 | 8 | 10 | 42 | 6 | 25 | 0 | 0 | 6 | 25 |
| ១១ | មានភាពលម្អៀងចំពោះសិស្សក្នុងពេលបង្រៀន | 0 | 0 | 0 | 0 | 4 | 17 | 0 | 0 | 20 | 83 |
| ១២ | បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបរិះរក (IBL) | 0 | 0 | 13 | 54 | 4 | 17 | 1 | 4 | 6 | 25 |
| ១៣ | បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL) | 0 | 0 | 9 | 38 | 5 | 20 | 2 | 8 | 8 | 34 |
| ១៤ | បានប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងពេលបង្រៀន | 7 | 29 | 15 | 63 | 2 | 8 | 0 | 0 | 0 | 0 |
| ១៥ | បានប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌលក្នុងពេលបង្រៀន | 1 | 4 | 5 | 20 | 13 | 55 | 4 | 17 | 1 | 4 |
| ១៦ | បានបង្រៀនតាមកាលវិភាគដែលគណៈគ្រប់គ្រងបានកំណត់ | 10 | 42 | 14 | 58 | 0 | 0 | 0 | 0 | 0 | 0 |
| ១៧ | បានបង្រៀនចប់តាមកម្មវិធីសិក្សាដែលក្រសួងបានកំណត់ | 8 | 34 | 9 | 38 | 7 | 28 | 0 | 0 | 0 | 0 |

តាមរយៈលទ្ធផលនៅក្នុងតារាងវិភាគរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ បានបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវ ស្តីពីបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ បានលើកឡើងដូចជា ៖

**ក.បញ្ហាប្រឈមទី១ " ការផលិតសម្ភារៈឧបទេសសម្រាប់បម្រើឱ្យការបង្រៀននិងរៀន "**

សម្ភារៈឧបទេស គឺជាឧបករណ៍ ឬមធ្យោបាយមួយសម្រាប់បម្រើ និងពង្រឹងសមត្ថភាពសកម្មភាពបង្រៀន និងរៀន ឱ្យមានគុណភាព និងប្រសិទ្ធភាព ។ សម្ភារៈឧបទេសដែលល្អ គឺជាសម្ភារៈឧបទេសដែលបម្រើឱ្យខ្លឹមសារមេរៀន មានសុវត្ថិភាព មានច្រើនឈុតសម្រាប់ទាំងគ្រូ និងសិស្ស មានទំហំសមស្របដែលអាចឱ្យសិស្សទូទាំងថ្នាក់រៀនមើលឃើញ សង្កេតបានច្បាស់លាស់ ។ ចំពោះសម្ភារៈរូបីងាយៗដែលគ្រូ ឬសិស្សអាចរកបាន ផលិតបាន គួរប្រើ

ប្រាស់សម្ភារៈរូបីនេះ បម្រើឱ្យការបង្រៀន និងរៀន ។ ការបង្រៀន និងរៀនមានដំណើរការរលូន និងសិស្សទទួលបានលទ្ធផលល្អ ទាមទារឱ្យគ្រូបង្រៀនត្រូវចំណាយពេលវេលា និងមានសមត្ថភាពក្នុងការផលិតសម្ភារៈឧបទេស និងបានយកសម្ភារៈដែលបានផលិតនោះទៅប្រើប្រាស់ឱ្យស្របតាមខ្លឹមសារមេរៀន ។ តាមរយៈលទ្ធផល បានបង្ហាញថា ការផលិតសម្ភារៈឧបទេសសម្រាប់បង្រៀនរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ ក្នុង១៤វិទ្យាល័យ សម្រាប់កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ១៣ % កម្រិតច្រើន មានចំនួន ០៦នាក់ ត្រូវជា ២៥ % កម្រិតមធ្យម មានចំនួន ១២នាក់ ត្រូវជា ៥០ % កម្រិតតិច មានចំនួន ០២នាក់ ត្រូវជា ៨ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៤ % ។ លទ្ធផលនេះបានបញ្ជាក់ឱ្យឃើញថា ការផលិតសម្ភារៈឧបទេសសម្រាប់បម្រើឱ្យការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ នៅតាមសាលារៀននៅមានកម្រិតមធ្យមនៅឡើយ ពុំទាន់អាចឆ្លើយតបបានពេញលេញទៅនឹងស្តង់ដានៃការបង្រៀន និងរៀនឱ្យបានល្អប្រសើរនៅឡើយ ។

**<u>ខ. បញ្ហាប្រឈមទី២ " ការប្រើប្រាស់សម្ភារៈឧបទេស សម្រាប់បម្រើឱ្យការបង្រៀន</u>**

ការបង្កើតសម្ភារៈឧបទេសជារឿងដ៏សំខាន់សម្រាប់គ្រូបង្រៀន តែការប្រើប្រាស់សម្ភារៈឧបទេស នៅក្នុងថ្នាក់រៀនឱ្យសម្បូរបែប រឹតតែជារឿងដ៏សំខាន់ទៅទៀត ព្រោះការប្រើប្រាស់សម្ភារៈឧបទេស ជាកត្តាមួយដែលធ្វើឱ្យថ្នាក់រៀនមានសោភណភាព ទាក់ទាញអារម្មណ៍ ជួយលើកទឹកចិត្តសិស្សហើយក៏ជាធនធានសម្រាប់បម្រើការសិក្សា នៅក្នុងថ្នាក់រៀន ប្រកបដោយប្រសិទ្ធភាព។តាមរយៈលទ្ធផលបានបង្ហាញថា ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បង្រៀនរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៤វិទ្យាល័យ សម្រាប់កម្រិតច្រើនបំផុត មានចំនួន ០៣នាក់ ត្រូវជា ១៣ % កម្រិតច្រើន មានចំនួន ០៥នាក់ ត្រូវជា ២០ % កម្រិតមធ្យម មានចំនួន ១៦នាក់ ត្រូវជា ៦៧ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០០នាក់ ត្រូវជា ០០ % ។ តាមរយៈលទ្ធផលនេះ យើងអាចវាយតម្លៃបានថា ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បម្រើឱ្យការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ នៅតាមសាលារៀននៅមានកម្រិតមធ្យមនៅឡើយ ពុំទាន់អាចឆ្លើយតបបានពេញលេញ ទៅនឹងស្តង់ដានៃការបង្រៀន និងរៀនឱ្យបានល្អប្រសើរនៅឡើយ ទាមទារឱ្យមានការជំរុញ លើកទឹកចិត្ត និងអនុវត្តការប្រើប្រាស់បន្ថែមទៀត ។

**<u>គ. បញ្ហាប្រឈមទី៣ " ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រង "</u>**

ចាប់តាំងពីឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់វិស័យអប់រំចំនួន១៥ចំណុច ក្នុងនោះការងារអធិការកិច្ច ស្ថិតក្នុងកំណែទម្រង់ទី៥ ដើម្បីឱ្យការអប់រំមាន

គុណភាពទៅបាន លុះត្រាតែពង្រឹងការងារអធិការកិច្ចនៅតាមសាលារៀន ។ សមត្ថភាពរបស់គ្រូបង្រៀនមានសារៈសំខាន់ណាស់ ក្នុងការលើកកម្ពស់នូវគុណភាពសិក្សា និងលទ្ធផលសិក្សារបស់សិស្ស ទើបបានជាក្រសួងបានដាក់ចេញ ឱ្យគ្រឹះស្ថានសិក្សាគ្រប់លំដាប់ថ្នាក់ខិតខំអនុវត្តគោលការណ៍អធិការកិច្ច (ផ្ទៃក្នុង) ដើម្បីជាការធ្វើស្វ័យវាយតម្លៃ ផ្លាស់ប្តូរនូវវិធីសាស្ត្របង្រៀន បច្ចេកទេសផ្ទេរចំណេះដឹងដល់សិស្ស និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនក្នុងអង្គភាពផងដែរ ជាពិសេស ដើម្បីឱ្យធាតុចេញដែលផលិតបានមកប្រកបដោយគុណភាពខ្ពស់ ។ អធិការកិច្ចនៅក្នុងសាលារៀនសំដៅលើគណៈគ្រប់គ្រងសាលារៀន មាននាយក នាយករង ផ្នែកបច្ចេកទេស ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន (សម្រាប់ការងារបច្ចេកទេសបង្រៀនក្នុងសាលាផ្ទាល់)។ កិច្ចការនេះត្រូវផ្តោតទៅលើការងារ ទាក់ទងនឹងគុណភាពអប់រំផ្ទៃក្នុងកម្រិតសាលារៀន ដោយប្រើប្រាស់ធនធានផ្ទៃក្នុង ឬធនធានមូលដ្ឋាន ។ ការធ្វើអធិការកិច្ចផ្ទៃក្នុងត្រូវរៀបចំ និងអនុវត្តជាប្រចាំដោយមានការកែតម្រូវផ្សេងៗទៅលើការងារគ្រប់គ្រង កិច្ចតែងការបង្រៀន ការរៀបចំឯកសាររដ្ឋបាលសម្រាប់ការបង្រៀនជាដើម ។ តាមរយៈលទ្ធផលបានបង្ហាញថា ការធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀន ពីគណៈគ្រប់គ្រងសាលារៀនរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទាំង២៤នាក់ នៅក្នុង១៨វិទ្យាល័យ សម្រាប់កម្រិតច្រើនបំផុត មានចំនួន ០២នាក់ ត្រូវជា ៨ % កម្រិតច្រើន មានចំនួន ០៩នាក់ ត្រូវជា ៣៨ % កម្រិតមធ្យម មានចំនួន ១២នាក់ ត្រូវជា ៥០ % កម្រិតតិច មានចំនួន ០០នាក់ ត្រូវជា ០០ % និងកម្រិតតិចបំផុត មានចំនួន ០១នាក់ ត្រូវជា ៤ % ។ លទ្ធផលនេះបានបញ្ជាក់ថា ការងារអធិការកិច្ចនៅតាមសាលារៀននៅមានកម្រិតមធ្យមនៅឡើយ ពុំទាន់បានពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយទេ ។

### ៥.១.១.៣. បញ្ហាប្រឈមរបស់សិស្សានុសិស្ស ថ្នាក់ទី១២

**តារាងលទ្ធផលវិភាគរបស់សិស្សានុសិស្ស ថ្នាក់ទី១២ គិតជាចំនួននាក់ និងភាគរយ**

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ច្រើនបំផុត | | ច្រើន | | មធ្យម | | តិច | | តិចបំផុត | |
| | ដំណើរការនៃការរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | ចំ. | % | ចំ. | % | ចំ. | % | ចំ. | % | ចំ. | % |
| ១ | មករៀនបានទៀងទាត់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 599 | 47 | 585 | 45 | 107 | 8 | 5 | 0 | 4 | 0 |
| ២ | ចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 351 | 27 | 621 | 48 | 298 | 23 | 24 | 2 | 6 | 0 |
| ៣ | បង្កើតក្លឹបសិក្សា និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ | 20 | 2 | 198 | 15 | 600 | 46 | 327 | 25 | 155 | 12 |
| ៤ | បានធ្វើកិច្ចការគ្រូ និងបានទទួលការកែលម្អពីគ្រូជាប្រចាំ | 213 | 16 | 543 | 42 | 410 | 32 | 108 | 8 | 26 | 2 |
| ៥ | ចូលរួមវាយតម្លៃលទ្ធផលសិក្សាពេលរៀន ឬក្រោយបង្រៀន | 96 | 7 | 436 | 34 | 580 | 45 | 143 | 10 | 45 | 4 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៦ | បានទទួលសៀវភៅតាមដានការសិក្សាពីគ្រូបង្រៀន | 527 | 41 | 443 | 34 | 246 | 19 | 56 | 4 | 28 | 2 |
| ៧ | មានភាពក្លាហានក្នុងការឆ្លើយសំណួររបស់គ្រូ | 148 | 11 | 442 | 34 | 593 | 45 | 97 | 8 | 20 | 2 |
| ៨ | សហការគ្នាពិភាក្សាជាក្រុម ក្នុងពេលរៀន | 271 | 21 | 520 | 40 | 357 | 28 | 111 | 8 | 41 | 3 |
| ៩ | បានជួយមិត្តភក្តិពេលម៉ោងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 142 | 11 | 395 | 30 | 531 | 41 | 180 | 14 | 52 | 4 |
| ១០ | យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ពេលម៉ោងរៀន | 482 | 37 | 643 | 50 | 156 | 11 | 12 | 1 | 7 | 1 |
| ១១ | រៀនគួរបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | 256 | 20 | 434 | 33 | 325 | 25 | 169 | 13 | 116 | 9 |
| ១២ | ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបរិះរក (IBL) | 75 | 6 | 350 | 27 | 532 | 41 | 224 | 17 | 119 | 9 |
| ១៣ | ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបបញ្ញត្តិ (CBL) | 47 | 4 | 240 | 19 | 568 | 44 | 285 | 22 | 160 | 11 |
| ១៤ | ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល | 86 | 7 | 294 | 23 | 522 | 40 | 256 | 20 | 142 | 10 |
| ១៥ | ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល | 136 | 11 | 342 | 26 | 449 | 35 | 225 | 17 | 148 | 11 |

តាមរយៈលទ្ធផល នៅក្នុងតារាងវិភាគ របស់សិស្សានុសិស្ស ថ្នាក់ទី១២បានបង្ហាញលទ្ធផលនៃការស្រាវជ្រាវ ស្តីពីបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលសិស្សានុសិស្ស ថ្នាក់ទី១២ ទាំង១៣០០នាក់ បានលើកឡើងដូចជា ៖

**<u>ក. បញ្ហាប្រឈមទី១ " ការបង្កើតក្លឹបសិក្សា និងធ្វើឱ្យក្លឹបមានដំណើរការល្អប្រសើរ "</u>**

នៅតាមសាលារៀន សិស្សខ្លះបានបង្កើតក្លឹបសិក្សាតាមមុខវិជ្ជា ដើម្បីស្វ័យសិក្សានៅពេលមានម៉ោងទំនេរពីម៉ោងដែលរៀននៅក្នុងថ្នាក់ ដោយមានការចូលរួមពីគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស ឬក្រុមសិស្សក្នុងការដឹកនាំសកម្មភាពជួយបង្រៀនគ្នាទៅវិញទៅមក ។ ក្នុងពេលក្លឹបមានដំណើរការល្អ វាបានជួយដល់សិស្សរៀនយឺត និងបង្កើតនូវទម្លាប់ល្អ ឱ្យសិស្សចេះសហការគ្នាក្នុងការរៀនសូត្រ ចែករំលែកនូវចំណេះដឹង បទពិសោធ និងស្មារតីសាមគ្គីភាពប្រកបដោយទំនួលខុសត្រូវ ម្ចាស់ការ ភាពស្និទ្ធស្នាល និងការជួយគ្នាទៅវិញទៅមក ។

តាមរយៈលទ្ធផលបានបង្ហាញថា ការបង្កើតក្លឹបសិក្សាដោយខ្លួនឯង និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ ទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ សម្រាប់កម្រិតច្រើនបំផុត មានចំនួន ២០នាក់ ត្រូវជា ២ % កម្រិតច្រើន មានចំនួន ១៩៨នាក់ ត្រូវជា ១៥ % កម្រិតមធ្យម មានចំនួន ៦០០នាក់ ត្រូវជា ៤៦ % កម្រិតតិច មានចំនួន ៣២៧នាក់ ត្រូវជា ២៥ % និងកម្រិតតិចបំផុត មានចំនួន ១៥៥នាក់ ត្រូវជា ១២ % ។ តាមរយៈ លទ្ធផលនេះ យើងអាចវាយតម្លៃបានថា ដំណើរការក្លឹបសិក្សានៅតាមវិទ្យាល័យនៅមានកម្រិតទាបនៅឡើយ ទាមទារឱ្យមានការយកចិត្តទុកដាក់ និងពង្រឹងគុណភាពបន្ថែមទៀត ។

ខ. បញ្ហាប្រឈមទី២ " ធ្លាប់ទទួលបានការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល "

គោលវិធីសិស្សមជ្ឈមណ្ឌលជាលំនាំនៃការបង្រៀន និងរៀនដោយផ្តោតលើសកម្មភាពរបស់សិស្សជាមូលដ្ឋានដោយទាមទារឱ្យសិស្សមានតួនាទីខិតខំប្រឹងប្រែងធ្វើសកម្មភាពដោយខ្លួនឯងក្រោមដំណឹកនាំរបស់គ្រូ សំដៅសម្រេចឱ្យបាននូវចំណេះដឹង បំណិន និងឥរិយាបថ ។ ដើម្បីឱ្យការសិក្សាតាមគោលវិធីនេះមានប្រសិទ្ធភាព គ្រូបង្រៀនជាអ្នកជួយអន្តរាគមន៍ ដោយត្រូវដាក់បញ្ហា ណែនាំបញ្ហាជាកាតាលីករ សម្របសម្រួល បង្កលក្ខណៈ និងសំយោគនូវអ្វីដែលសិស្សបានធ្វើ ក្នុងគោលបំណងឱ្យសិស្សចេះស្វែងរកចំណេះដឹងដោយខ្លួនឯង ។ តាមរយៈលទ្ធផលបានបង្ហាញថា ការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលទាំង១៣០០នាក់ នៅក្នុង១៤វិទ្យាល័យ សម្រាប់កម្រិតច្រើនបំផុត មានចំនួន ៨៦នាក់ ត្រូវជា ៧ % កម្រិតច្រើន មានចំនួន ២៩៤នាក់ ត្រូវជា ២៣ % កម្រិតមធ្យម មានចំនួន ៥២២នាក់ ត្រូវជា ៤០ % កម្រិតតិច មានចំនួន ២៥៦នាក់ ត្រូវជា ២០ % និងកម្រិតតិចបំផុត មានចំនួន ១៤២នាក់ ត្រូវជា ១០ % ។ លទ្ធផលនេះបញ្ជាក់ថា ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៅតាមវិទ្យាល័យមានកម្រិតមធ្យម ពុំទាន់បានល្អប្រសើរ តាមគោលដៅអប់រំចង់បាននៅឡើយទេ ទាមទារឱ្យមានការកែលម្អ និងជំរុញការអនុវត្តសកម្មភាពបន្ថែមទៀត ។

## ៥.១.២. ការពិភាក្សាលើវត្ថុបំណងទី២

### ៥.១.២.១. វិធានការ ឬដំណោះស្រាយរបស់គណៈគ្រប់គ្រងសាលារៀន

តាមរយៈតារាងលទ្ធផលវិភាគ នៅក្នុងកម្រងសំណួរ របស់គណៈគ្រប់គ្រងសាលារៀន និងបញ្ហាប្រឈមសំខាន់ៗ នៅក្នុងវត្ថុបំណងទី១ យើងអាចរៀបចំជាវិធានការ ឬដំណោះស្រាយលើបញ្ហាប្រឈមសំខាន់ៗ មួយចំនួន ដូចជា ៖

ក. បញ្ហាប្រឈមទី១ " ការដឹកនាំធ្វើថ្នាក់និទស្សន៍ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន "

**ក. ដំណោះស្រាយបញ្ហាប្រឈមទី១**

- រៀបចំការប្រជុំបច្ចេកទេសឱ្យបានទៀងទាត់ ដោយពិភាក្សាគ្នាពីយន្តការ និងរបៀបធ្វើថ្នាក់និទស្សន៍ ថ្នាក់សាលារៀន និងថ្នាក់កម្រងសាលារៀនឱ្យបានទៀងទាត់ ផ្លាស់វេនគ្នាតាមមុខវិជ្ជាផ្សេងៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធឱ្យគ្នាទៅវិញទៅមក
- ជ្រើសរើស និងជំរុញគ្រូបង្រៀនតាមមុខវិជ្ជា ដែលមានសមត្ថភាព និងវិធីសាស្ត្របង្រៀនខ្ពស់ ឱ្យបង្រៀនថ្នាក់និទស្សន៍ជាគំរូ និងបន្តផ្លាស់គ្រូបង្រៀនតាមឯកទេសឱ្យបង្រៀនថ្នាក់និទស្សន៍បន្តជាប្រចាំ ក្នុងពេលប្រជុំបច្ចេកទេស

តាមផែនការ និងពង្រឹងគុណភាពនៃការបង្រៀន និងរៀនជាប្រចាំ

- រៀបចំផែនការពង្រឹងសមត្ថភាពនៃការបង្រៀនរបស់គ្រូបង្រៀន តាមរយៈដំណើរទស្សនកិច្ចសិក្សា ទៅសាលារៀនល្អ ដើម្បីដកស្រង់យកបទពិសោធល្អៗ យកមកបំប៉ន និងអនុវត្តសមត្ថភាពបង្រៀន និងរៀនឱ្យបានល្អប្រសើរ
- រៀបចំសិក្ខាសាលា បំប៉ននូវសមត្ថភាពបន្ថែម ដល់ប្រធាន អនុប្រធាន និងសមាជិកក្រុមបច្ចេកទេស ទាក់ទងនឹងវិធីសាស្ត្របង្រៀនថ្មីៗ ការផលិត និងប្រើប្រាស់សម្ភារៈឧបទេសដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ។

**<u>ខ. បញ្ហាប្រឈមទី២ " ការទទួលបានការបំប៉នពីក្របខណ្ឌនៃកម្មវិធីសិក្សាថ្មី "</u>**

**ខ. ដំណោះស្រាយបញ្ហាប្រឈមទី២**

- រៀបចំសិក្សាស្វែងយល់បន្ថែមពីក្របខណ្ឌនៃកម្មវិធីសិក្សាថ្មី ដោយខិតខំស្រាវជ្រាវទៅលើឯកសារយោង សៀវភៅសិក្សាគោល និងការប្រើប្រាស់នូវសម្ភារៈឧបទេសឱ្យស្របទៅតាមខ្លឹមសារនៃកម្មវិធីសិក្សាឱ្យបានទូលាយ
- ប្រើប្រាស់នូវវិធីសាស្ត្របង្រៀនសម្បូរបែប ស្របទៅតាមគោលការណ៍នៃកម្មវិធីសិក្សាថ្មី ដើម្បីពង្រឹងគុណភាពនៃការអនុវត្តឱ្យបានល្អប្រសើរ
- ធ្វើការវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សាថ្មីតាមលំដាប់ គ្រប់ជ្រុងជ្រោយ និងវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយនៃក្របខណ្ឌកម្មវិធីសិក្សាថ្មី
- រៀបចំផ្សព្វផ្សាយ និងបំប៉នបន្ថែមលើខ្លឹមសារនៃក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធ ដើម្បីបានជ្រួតជ្រាប និងអនុវត្តឱ្យបានទូលំទូលាយនៅតាមមូលដ្ឋាន ។

**<u>គ.បញ្ហាប្រឈមទី៣ " ការបំពាក់LCD និងឧបករណ៍ICTសម្រាប់ប្រើក្នុងពេលបង្រៀន "</u>**

**គ. ដំណោះស្រាយបញ្ហាប្រឈមទី៣**

- ធ្វើសំណើសុំ LCD និងឧបករណ៍ ICT ផ្សេងទៀត ទៅថ្នាក់លើតាមឋានានុក្រម
- រៀបចំកសាងផែនការអភិវឌ្ឍសាលារៀន ដោយប្រើប្រាស់ថវិកាក្នុងការទិញ LCD និងឧបករណ៍ ICT ផ្សេងទៀត ដែលបម្រើឱ្យការងារបង្រៀន និងរៀន
- ស្វែងរកអង្គការដៃគូ ឬសប្បុរសជននានា ក្នុងការជួយជាឧបករណ៍ LCD និងឧបករណ៍ ICT ផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន និងរៀន
- រៀបចំវគ្គបំប៉ន ឬសិក្ខាសាលាអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើចំណេះដឹងស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យា និងការប្រើប្រាស់ ICT នៅក្នុងការបង្រៀន និងរៀនឱ្យបានចេះដឹងគ្រប់ៗគ្នា សំដៅសម្រេចឱ្យបាននូវគុណភាពនៃការអប់រំ ។

**៥.១.២.២. វិធានការ ឬដំណោះស្រាយរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២**

តាមរយៈតារាងលទ្ធផលវិភាគ នៅក្នុងកម្រងសំណួរ របស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ និងបញ្ហាប្រឈមសំខាន់ៗ នៅក្នុងវត្ថុបំណងទី១ យើងអាចរៀបចំជាវិធានការ ឬដំណោះស្រាយលើបញ្ហាប្រឈមសំខាន់ៗ មួយចំនួន ដូចជា ៖

**ក.បញ្ហាប្រឈមទី១ " ការផលិតសម្ភារៈឧបទេសសម្រាប់បម្រើឱ្យការបង្រៀននិងរៀន "**

**ក. ដំណោះស្រាយបញ្ហាប្រឈមទី១**

- ធ្វើសំណើសុំសម្ភារៈឧបទេសពីគណៈគ្រប់គ្រងសាលារៀន សម្រាប់បម្រើឱ្យការងារបង្រៀន និងរៀន
- ជំរុញ និងលើកទឹកចិត្តដល់គ្រូបង្រៀន ក្នុងការផលិតសម្ភារៈឧបទេសឱ្យបានច្រើនទៅតាមលទ្ធភាពដែលអាចធ្វើបាន សមស្របតាមខ្លឹមសារមេរៀន
- កែច្នៃ និងផលិតសម្ភារៈឧបទេសងាយៗ ដែលមានស្រាប់ក្នុងមូលដ្ឋាន
- ខិតខំសិក្សា ស្រាវជ្រាវស្វែងយល់បន្ថែមពីវិធីសាស្ត្រថ្មីៗ ទំនើបៗ សម្បូរបែបក្នុងការផលិតសម្ភារៈឧបទេស ឱ្យឆ្លើយតបនឹងតម្រូវការបង្រៀនជាក់ស្ដែង។

**ខ. បញ្ហាប្រឈមទី២ " ការប្រើប្រាស់សម្ភារៈឧបទេស សម្រាប់បម្រើឱ្យការបង្រៀន**

**ខ. ដំណោះស្រាយបញ្ហាប្រឈមទី២**

- កំណត់វត្ថុបំណង និងសម្ភារៈឧបទេសដែលត្រូវប្រើប្រាស់ តាមរយៈការធ្វើកិច្ចតែងការបង្រៀនជាមុន ឱ្យបានជាប្រចាំ ងាយស្រួលក្នុងការបង្រៀន និងរៀន
- អនុវត្តការប្រើប្រាស់សម្ភារៈឧបទេសដែលទាក់ទងនឹងខ្លឹមសារមេរៀន ដើម្បីឱ្យសិស្សងាយយល់ ឆាប់ចេះ និងទទួលចំណេះដឹងបានពេញលេញ
- ប្រើប្រាស់ឧបករណ៍ងាយៗ និងសម្ភារៈដែលមានក្នុងមូលដ្ឋាន ដើម្បីទុកជាសម្ភារៈដែលទ្រទ្រង់ក្នុងដំណើរការបង្រៀន និងរៀនប្រកបដោយគុណភាព
- ជំរុញ លើកទឹកចិត្ត និងផ្សព្វផ្សាយពីវិធីសាស្ត្រក្នុងការប្រើប្រាស់សម្ភារៈឧបទេសដល់គ្រូបង្រៀនដូចគ្នាឱ្យបានទូលំទូលាយ ដើម្បីចែករំលែកនូវចំណេះដឹង ស្ដីពីការប្រើប្រាស់សម្ភារៈឧបទេសឱ្យមានប្រសិទ្ធភាព
- ចូលរួមក្នុងការប្រជុំបច្ចេកទេស និងលើកយកប្រធានបទស្ដីពីការប្រើប្រាស់សម្ភារៈឧបទេសមកផ្សព្វផ្សាយ និងចែករំលែកគ្នាទៅវិញទៅមក ។

**គ. បញ្ហាប្រឈមទី៣ " ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រង "**

**គ. ដំណោះស្រាយបញ្ហាប្រឈមទី៣**

- រៀបចំកសាងផែនការអធិការកិច្ចថ្នាក់រៀន តាមខែនីមួយៗឱ្យបានទៀងទាត់

- ជំរុញ និងលើកទឹកចិត្តដល់ប្រធានក្រុមបច្ចេកទេសគ្រប់មុខវិជ្ជា ក្នុងការជួយពង្រឹងនូវការងារបង្រៀន និងរៀន និងធានានូវគុណភាពនៃការធ្វើអធិការកិច្ច
- រៀបចំការបំប៉នសមត្ថភាពដល់ប្រធានក្រុមបច្ចេកទេស និងអ្នកពាក់ព័ន្ធក្នុងការចុះជួយលោកគ្រូ អ្នកគ្រូលើដំណើរការនៃការបង្រៀន និងរៀន ការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន និងការធ្វើអធិការកិច្ចជាប្រចាំ
- បង្កើត ពង្រឹង និងពង្រីកតួនាទីនៃក្រុមត្រួតពិនិត្យ តាមដានថ្នាក់ក្រុង ស្រុក DTMT នៅតាមកម្រងសាលារៀន និងថ្នាក់សាលារៀននៅតាមក្រុង ស្រុក ។

### ៥.១.២.៣. វិធានការ ឬដំណោះស្រាយរបស់សិស្សានុសិស្ស ថ្នាក់ទី១២

តាមរយៈតារាងលទ្ធផលវិភាគ នៅក្នុងកម្រងសំណួររបស់សិស្សានុសិស្ស ថ្នាក់ទី១២ យើងអាចរៀបចំជាវិធានការ ឬដំណោះស្រាយបញ្ហាប្រឈមសំខាន់ៗ ដូចជា ៖

**ក. បញ្ហាប្រឈមទី១ " ការបង្កើតក្លឹបសិក្សា និងធ្វើឱ្យក្លឹបមានដំណើរការល្អប្រសើរ "**

**ក. ដំណោះស្រាយបញ្ហាប្រឈមទី១**

- រៀបចំពង្រឹង អនុវត្តតួនាទី និងដំណើរការនៃក្រុមប្រឹក្សាកុមារ ជាពិសេសក្លឹបធនធានវ័យក្មេងឱ្យមានដំណើរការល្អប្រសើរ
- ជំរុញ លើកទឹកចិត្ត និងផ្សព្វផ្សាយដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់ គ្រប់មុខវិជ្ជា ឱ្យបង្កើតក្លឹបសិក្សាដោយខ្លួនឯង ជាក្រុមតូច ឬធំទៅតាមលទ្ធភាព
- ជួយឧបត្ថម្ភជាសម្ភារៈ ឯកសារជំនួយ និងបទពិសោធល្អៗ សម្រាប់សម្រួល និងលើកកម្ពស់ដល់ដំណើរការនៃក្លឹបសិក្សា តាមមុខវិជ្ជា នៅក្នុងសាលារៀន
- បំប៉ន និងបណ្តុះបណ្តាលចំណេះដឹងបន្ថែម ដល់សមាជិកក្លឹបតាមមុខវិជ្ជា ដើម្បីចែករំលែកចំណេះដឹង បទពិសោធ និងបង្រៀនគ្នាទៅវិញទៅមក
- រៀបចំការប្រកួតប្រជែងយកជ័យលាភី និងលើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រតាមក្លឹបសិក្សាឱ្យបានទូលំទូលាយ ។

**ខ. បញ្ហាប្រឈមទី២ " ទទួលបានការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល "**

**ខ. ដំណោះស្រាយបញ្ហាប្រឈមទី២**

- ប្រជុំ ផ្សព្វផ្សាយ និងលើកទឹកចិត្តគ្រូបង្រៀនឱ្យប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលឱ្យបានច្រើន ទៅតាមលទ្ធភាពជាក់ស្តែង
- រៀបចំការបំប៉ន ឬសិក្ខាសាលាអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើប្រធានបទស្តីពីវិធីសាស្ត្រក្នុងការប្រើប្រាស់ និងអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

- ជំរុញ និងលើកទឹកចិត្តគ្រូបង្រៀនក្នុងការប្រើប្រាស់ឯកសារស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យបានល្អប្រសើរ និងអស់ពីលទ្ធភាពជាក់ស្តែង
- ពង្រឹងតួនាទី និងភារកិច្ចក្នុងការធ្វើអធិការកិច្ចជាប្រចាំ លើការងារបង្រៀន និងរៀន ឱ្យបានទៀងទាត់ ទាន់ពេលវេលា ។

## ៥.២. សន្និដ្ឋាន

តាមរយៈការវិភាគ និងពិភាក្សាលើលទ្ធផលនៃការសិក្សា និងស្រាវជ្រាវខាងលើនេះ ធ្វើឱ្យយើងអាចសន្និដ្ឋានបានថា ស្ថានភាពជាក់ស្តែង ទាក់ទងទៅនឹងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅកម្រិតថ្នាក់ទី១២ មានភាពល្អប្រសើរច្រើន ដោយក្នុងនោះ គ្រូបង្រៀនរហូតដល់ទៅ ៩១.៧០% ដែលបង្រៀននៅថ្នាក់ទី១២ មានក្របខណ្ឌជាគ្រូបង្រៀនកម្រិតឧត្តម **(តារាងទី៣)** និងគ្រូបង្រៀនចំនួន ៩៥.៨០% មានកម្រិតសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ **(តារាងទី៣)** ។ ជាងនេះទៅទៀត លោកគ្រូ អ្នកគ្រូ ចំនួន ៦២.៥០% តែងតែធ្វើកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការបង្រៀន ជាប្រចាំ **(តារាងទី៣)** ព្រមជាមួយទម្លាប់ល្អក្នុងការដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែលម្អលើកិច្ចការសិស្ស បានដល់ទៅ ៩១.៧០% **(តារាងទី៣)** ការវាយតម្លៃក្នុងពេល និងក្រោយការបង្រៀនមេរៀនចប់បាន ៨៧.៥០% **(តារាងទី៣)** និងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានល្អប្រសើរ ដល់ទៅ ៩១.៧០% **(តារាងទី៣)** នៅក្នុងពេលបង្រៀន និងរៀន ។ ឆ្លងតាមរយៈ លទ្ធផលស្រាវជ្រាវនេះ បានបង្ហាញយ៉ាងច្បាស់ថា គ្រូបង្រៀននៅតាមវិទ្យាល័យគោលដៅទាំងនោះពិតជាអាចបង្រៀនសិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ចំណែកឯសិស្សានុសិស្សវិញ ក៏មានចំណាង់ចំណូលចិត្តចូលចិត្តរៀន និងមករៀនម៉ោងអក្សរសាស្ត្រខ្មែរបានយ៉ាងល្អប្រសើរ ក្នុងនោះ សិស្ស ៩១.៧០ % **(តារាងទី៤)** បានមករៀនទៀងទាត់ តាមម៉ោងចេញ និងម៉ោងចូល ហើយសិស្ស ៧៤.៨០ % **(តារាងទី៤)** ចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ គួបផ្សំនឹងការយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់មេរៀនបានយ៉ាងល្អប្រសើរ ដល់ទៅ ៨៧.៦០% **(តារាងទី៤)** ។

ពាក់ព័ន្ធទៅនឹងការងារដឹកនាំ និងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀនវិញ ក៏បានបង្ហាញលទ្ធផលវិជ្ជមានមួយចំនួនផងដែរ ដូចជា ការបែងចែកគ្រូបង្រៀន តាមឯកទេសវិជ្ជាជីវៈ ការគ្រប់គ្រងម៉ោងចេញ ម៉ោងចូលរបស់បុគ្គលិក មានចំនួន ៨៥.៧០% **(តារាងទី២)** ព្រមជាមួយនឹងការរៀបចំបរិស្ថាន សោភណភាព និងអនាម័យសាលារៀន ឱ្យក្លាយជាសាលាកុមារមេត្រីដើម្បីទាក់ទាញអារម្មណ៍សិស្សក្នុងការសិក្សាមានចំនួន ៩២.៨០% **(តារាងទី២)** ជា

ពិសេស ការចូលរួមក្នុងការតាមដានលទ្ធផលនៃការសិក្សារបស់សិស្ស មានចំនួន៨៥.៧០% (**តារាងទី២**) ការលើកទឹកចិត្តដល់សិស្សដែលរៀនពូកែ មានចំនួន ៨៥.៧០% (**ក្រាបទី១៦**) និងការរៀបចំប្រឡងសិស្សពូកែមុខវិជ្ជាអក្សរសាស្ត្រខ្មែរ សម្រាប់ទាក់ទាញសិស្ស ឱ្យចូលប្រឡងសិស្សពូកែឱ្យបានច្រើន មានចំនួន ៨៥.៧០% (**តារាងទី២**) ។

ទន្ទឹមនឹងចំណុចវិជ្ជមានខាងលើ ក្នុងនោះក៏មានចំណុចខ្វះខាតមួយចំនួនដែលជាបញ្ហាប្រឈមទាមទារឱ្យមានដំណោះស្រាយផងដែរ។ បញ្ហាទាំងនោះរួមមានដូចជាកង្វះសម្ភារៈសម្រាប់ទ្រទ្រង់ចាំបាច់ សម្រាប់ការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរមួយចំនួន រួមមានម៉ាញ៉េចាក់កាសែត ឬស៊ីឌី សម្រាប់បង្រៀនលើអត្ថបទស្តាប់ ការប្រើប្រាស់ស្លាយ LCD សម្រាប់ចាក់ជាវីដេអូបញ្ចាំងស្នាដៃរឿងអក្សរសិល្ប៍ ឱ្យសិស្សបានមើលជាក់ស្តែង ដោយសារទិន្នន័យដែលទទួលបានបានបង្ហាញថាការបំពាក់ LCD និងឧបករណ៍ ICT ផ្សេងទៀត សម្រាប់ប្រើប្រាស់ ក្នុងពេលបង្រៀន មានចំនួនត្រឹមតែ ១៤.២០% (**តារាងទី២**) ហើយគ្រូបង្រៀនដែលបានផលិតសម្ភារៈឧបទេសបង្រៀនជាប្រចាំ មានត្រឹមតែ ៣៧.៥០% (**តារាងទី៣**) និងគ្រូបង្រៀនដែលបានប្រើប្រាស់សម្ភារៈឧបទេសសម្រាប់បង្រៀនជាប្រចាំមានត្រឹមតែ ៣៣.៣០% (**តារាងទី៣**) ។ ម្យ៉ាងទៀត ការធ្វើអធិការកិច្ចផ្ទៃក្នុងនៅកម្រិតសាលារៀននៅមានកម្រិតទាប ពុំទាន់បានឆ្លើយតបពេញលេញទៅនឹងការពង្រឹងគុណភាពនៃការអប់រំនៅឡើយ គឺមានចំនួនត្រឹមតែ ៤៦ % តែប៉ុណ្ណោះ (**តារាងទី៣**) ។

ក្រៅពីនេះ សកម្មភាពក្លឹបសិក្សារបស់សិស្សមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អនៅតាមវិទ្យាល័យ នៅមានកម្រិតទាបនៅឡើយ ដោយលទ្ធផលបានបង្ហាញថា មានសិស្សត្រឹមតែ ១៦.៧០% ប៉ុណ្ណោះ (**តារាងទី៤**) ដែលតែងតែចូលរួមជាប្រចាំក្នុងសកម្មភាពក្លឹបសិក្សាលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ។ រីឯការធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលក៏នៅមានកម្រិតទាបនៅឡើយដែរ ដោយសិស្សានុសិស្សភាគច្រើនបានវាយតម្លៃលើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមតែ ៣០% តែប៉ុណ្ណោះ (**តារាងទី៤**) ដែលអនុវត្តបានល្អប្រសើរ ។

ម៉្យាងវិញទៀត ការរៀបចំធ្វើថ្នាក់និទស្សន៍ជាប្រចាំនៅតាមវិទ្យាល័យ ក៏ជាបញ្ហាប្រឈមផងដែរ ដោយទិន្នន័យបានបង្ហាញថា ការរៀបចំដឹកនាំធ្វើថ្នាក់និទស្សន៍ ដើម្បីអភិវឌ្ឍនូវសមត្ថភាពរបស់គ្រូបង្រៀននៅមានចំនួនតិចតួចនៅឡើយ ត្រឹមតែចំនួន ២៨.៥០% ប៉ុណ្ណោះ (**តារាងទី២**) ដែលបានរៀបចំធ្វើថ្នាក់និទស្សន៍ និងប្រជុំបច្ចេកទេសជាប្រចាំ បានល្អប្រសើរ ។

## ៥.៣. សំណូមពរ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងជួយបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ អ្នកសិក្សាស្រាវជ្រាវ បានលើកជាសំណូមពរមួយចំនួនដូចខាងក្រោម៖

### ក. ក្រសួងអប់រំ យុវជន និងកីឡា

- គួរតែរៀបចំបើកវគ្គបំប៉នក្នុងការបណ្ដុះបណ្ដាលដល់គណៈគ្រប់គ្រងសាលារៀន និងដល់គ្រូបង្រៀន ស្ដីពីវិធីសាស្ត្របង្រៀនថ្មីៗ ទំនើបៗ ការផលិតនិងប្រើប្រាស់សម្ភារៈឧបទេស និងចិត្ត-គរុកោសល្យ ការបំប៉នចំណេះដឹងស្ដីពីបច្ចេកវិទ្យា និងព័ត៌មានវិទ្យា ដើម្បីធ្វើបច្ចុប្បន្នភាពនៃការបង្រៀន ដើរឱ្យទាន់សតវត្សទី២១ ជាពិសេស វិធីសាស្ត្របង្រៀនបែបរិះរក ការគិតស៊ីជម្រៅ ការសហការ ការដោះស្រាយបញ្ហា ដើម្បីបង្រៀន និងអប់រំសិស្សឱ្យក្លាយជាពលរដ្ឋសាកល សមស្របទៅតាមក្របខណ្ឌនៃកម្មវិធីសិក្សាថ្មី នាពេលបច្ចុប្បន្ននេះ
- គួរតែផ្ដល់ឱ្យសាលារៀននូវសម្ភារៈឧបទេស សម្រាប់ទ្រទ្រង់ការបង្រៀន និងរៀន មុខវិជ្ជាអក្សរសាស្ត្រខ្មែរដែលចាំបាច់មួយចំនួនដូចជា ឧបករណ៍សម្រាប់បម្រើឱ្យអត្ថបទស្ដាប់ សៀវភៅគ្រូ សៀវភៅរឿងទាក់ទងនឹងបំណិនស្ដាប់ ស្លាយ LCD សម្រាប់បញ្ចាំងវីដេអូស្នាដៃអក្សរសិល្ប៍ឱ្យសិស្សមើល និងសម្រួលដល់ការធ្វើបទបង្ហាញពេលបង្រៀន និងរៀនឱ្យមានភាពងាយស្រួល និងទទួលបានលទ្ធផលល្អប្រសើរ
- គួរតែពិនិត្យលទ្ធភាពផ្ដល់ជូននូវសៀវភៅសិក្សាគោលទៅឱ្យសាលារៀន ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ស្របតាមតម្រូវការជាក់ស្ដែង តាមឆ្នាំសិក្សានីមួយៗ
- គួរតែជំរុញ និងកែសម្រួលម៉ោងបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ នៅតាមវិទ្យាល័យឱ្យបានចំនួនច្រើនជាងបច្ចុប្បន្ន ដើម្បីពង្រឹងការអនុវត្តកម្មវិធីសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

### ខ. មន្ទីរអប់រំ យុវជន និងកីឡារាជធានី - ខេត្ត

- គួរតែចុះជួយពិនិត្យតាមដាន ជាប្រចាំ ទៅលើការបង្រៀន និងរៀននៅតាមសាលា
- គួរតែចូលរួមដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលា និងរាយការណ៍បន្តទៅថ្នាក់លើ
- គួរតែចុះពង្រឹង និងធ្វើអធិការកិច្ចឱ្យបានញឹកញាប់នៅតាមសាលារៀន ដោយផ្ដោតសំខាន់លើរដ្ឋបាលគ្រូបង្រៀន ការធ្វើកិច្ចតែងការបង្រៀន និងនិយ័តភាពក្នុងការបង្រៀនរបស់គ្រូបង្រៀនឱ្យបានទៀងទាត់

- គួរតែជំរុញ លើកទឹកចិត្ត និងបំផុសស្មារតីដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ឱ្យរៀបចំការបង្រៀនបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ជាពិសេស នៅថ្ងៃអាទិត្យ

**គ. គណៈគ្រប់គ្រងសាលារៀន**

- ជំរុញ និងលើកទឹកចិត្តគ្រូបង្រៀន ឱ្យផលិត និងប្រើប្រាស់នូវសម្ភារៈឧបទេសងាយៗ សម្រាប់បម្រើឱ្យការងារបង្រៀននិងរៀន តាមរយៈការប្រជុំបច្ចេកទេសប្រចាំខែនីមួយៗ និងប្រើប្រាស់សម្ភារៈឧបទេសរាល់ការបង្រៀនឱ្យអស់លទ្ធភាព
- ពង្រឹងបទបញ្ញត្តិ របស់សាលារៀន និងវិន័យគ្រូ សិស្ស ឱ្យមានប្រសិទ្ធភាពខ្ពស់
- សហការជាមួយដៃគូអភិវឌ្ឍ និងសប្បុរសជននានា ដើម្បីឧបត្ថម្ភជាសម្ភារៈបង្រៀន ដែលលោកគ្រូ អ្នកគ្រូមិនអាចផលិតដោយខ្លួនឯងបាន
- រៀបចំផែនការចុះអធិការកិច្ចគ្រូបង្រៀនតាមប្រចាំខែ និងឆមាសឱ្យបានទៀងទាត់ ។

**ឃ. ចំពោះលោកគ្រូ អ្នកគ្រូ**

- ខិតខំ ស្វ័យសិក្សា និងស្រាវជ្រាវបន្ថែមទៀត ពីវិធីសាស្ត្របង្រៀនថ្មីៗ ល្អៗ ទំនើបៗ ជាប្រចាំ ពិសេស ពង្រឹងចំណេះដឹងលើជំនាញឯកទេសរបស់ខ្លួន
- គោរពពេលវេលាបង្រៀន ស្របតាមកាលវិភាគ និងភារកិច្ចដែលបានផ្តល់ជូន
- ព្យាយាមច្នៃប្រតិដ្ឋក្នុងការផលិត និងប្រើប្រាស់នូវសម្ភារៈឧបទេសថ្មីៗ ងាយៗ សម្រាប់ជាជំនួយដល់ការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ឱ្យទទួលបានលទ្ធផលល្អប្រសើរ
- ជំរុញ លើកទឹកចិត្ត ណែនាំ និងពន្យល់សិស្សានុសិស្សឱ្យពួកគេទទួលស្គាល់ពីគុណតម្លៃ និងសារប្រយោជន៍នៃការសិក្សាអក្សរសាស្ត្រខ្មែរ

**ង. ចំពោះសិស្សានុសិស្ស**

- ពង្រឹង និងពង្រីកនូវសមត្ថភាព និងចំណេះដឹងរបស់ខ្លួនឱ្យស្ទាត់ជំនាញ ទៅលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ឱ្យបានទូលំទូលាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត។
- ខិតខំព្យាយាមសិក្សាស្រាវជ្រាវលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ដោយផ្តោតសំខាន់ទៅលើអំណាន សំណេរ តែងសេចក្តី អក្ខរាវិរុទ្ធ សម្រាប់ជាប្រយោជន៍តទៅថ្ងៃខាងមុខ ។

## ៥.៤. ការស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវមួយនេះ បានធ្វើឡើងតែទៅលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ នៅកម្រិតថ្នាក់ទី១២ នៅតាមវិទ្យាល័យគោលដៅចំនួន ១៤ ក្នុងក្រុង ០១ និងស្រុកចំនួន ០៥ ក្នុង

ខេត្តកំពង់ចាមតែប៉ុណ្ណោះ ដូច្នេះ លទ្ធផលដែលរកឃើញពិតជានៅមានចន្លោះប្រហោងនៅឡើយ។ ហេតុនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្តលើប្រធានបទនេះ គួរតែពង្រីកដែនកំណត់ និងវិសាលភាពរបស់ខ្លួនឱ្យបានធំជាងនេះ ប្រសិនបើនៅតែមានបំណងចង់សិក្សានៅក្នុងខេត្តកំពង់ចាម ដដែល ។ ក្រៅពីនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗ ក៏អាចយកប្រធានបទនេះទៅសិក្សានៅតំបន់ទីប្រជុំជន ឬតំបន់ដាច់ស្រយាលនៅតាមបណ្តាខេត្តនានាផងដែរ ដោយសារតែគុណភាពសាលារៀន គុណភាពគ្រូបង្រៀន និងចំណេះដឹងមុខវិជ្ជាអក្សរសាស្ត្រខ្មែរ របស់សិស្សនៅទីនោះ អាចមានភាពខុសគ្នាឆ្ងាយពីស្ថានភាពនៅក្នុងក្រុង០១ និងស្រុកទាំង ០៥ នៃខេត្តកំពង់ចាម ។

# ឯកសារយោង


- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (១៩៦៧) វចនានុក្រមខ្មែរ ភាគ១ និងភាគ២
- រាជរដ្ឋាភិបាលកម្ពុជា (២០១៩) គោលនយោបាយជាតិស្ដីពីភាសាខ្មែរ
- រាជរដ្ឋាភិបាលកម្ពុជា (២០១៨) យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨ - ២០២៣
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា. (២០១៥). ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស. ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា .
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា. (២០១៨). កម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរកម្រិតមធ្យមសិក្សាទុតិយភូមិ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា .
- គណៈកម្មការវាយតម្លៃថ្នាក់ជាតិ (២០១៦) ឧបករណ៍វាយតម្លៃនាយក - នាយិកាសាលារៀនល្អ ក្រសួងអប់រំ យុវជន និងកីឡា .
- គណៈកម្មការវាយតម្លៃថ្នាក់ជាតិ (២០១៦) ឧបករណ៍វាយតម្លៃគ្រូបង្រៀនល្អ ក្រសួងអប់រំ យុវជន និងកីឡា .
- អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) (២០១៥) វិស័យអប់រំឆ្នាំ២០៣០ សេចក្ដីប្រកាសទីក្រុងអ៊ីនឈុន និង ក្របខណ្ឌសកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និង ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា. អ៊ីនឈុន .

# ឧបសម្ព័ន្ធទី ១

# កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន

ប្រធានបទស្រាវជ្រាវ៖ « ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ករណីសិក្សា ៖ ខេត្តកំពង់ចាម »

ខ្ញុំបាទឈ្មោះ **សាម សុនិត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ។

សព្វថ្ងៃខ្ញុំបាទជានាយករងនៃវិទ្យាល័យ ហ៊ុន សែន ស្ទួន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឥឡូវនេះ ខ្ញុំបាទបាននឹងកំពុងធ្វើការស្រាវជ្រាវមួយក្រោមប្រធានបទ « **ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ករណីសិក្សា ៖ ខេត្តកំពង់ចាម** »

ការស្រាវជ្រាវនេះមានគោលបំណងធំៗចំនួនពីរគឺ៖

**១. សិក្សាពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង បញ្ហាប្រឈម ការបង្រៀន និងការរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២**

**២. សិក្សាពីដំណោះស្រាយ ឬវិធានការដោះស្រាយចំពោះបញ្ហាប្រឈមក្នុងការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ**

**ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន**

**សេចក្តីណែនាំ៖** សូមលោក - លោកស្រី គូស " ✓" នៅក្នុងប្រអប់ " ☐ " ខាងក្រោម ៖

**១. មុខតំណែង**

☐ នាយក/នាយិកា ☐ នាយករង/នាយិការង

**២. កម្រិតវប្បធម៌**

☐ ទាបជាងបរិញ្ញាបត្រ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់

☐ បណ្ឌិត

**៣. បទពិសោធការងារ**

☐ តិចជាង១០ឆ្នាំ ☐ ១០ឆ្នាំទៅ២០ឆ្នាំ ☐ ច្រើនជាង២០ឆ្នាំ

**ផ្នែកទី២៖ ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ក្នុងខេត្តកំពង់ចាម**

**សេចក្តីណែនាំ៖** សូមលោក-លោកស្រីគូស"✓"ទៅតាមការកម្រិតនៃការប្រតិបត្តិតាមការយល់ឃើញរបស់លោក-លោកស្រី៖

៥ មានន័យថា មានការប្រតិបត្តិច្រើនបំផុត

៤ មានន័យថា មានការប្រតិបត្តិច្រើន

៣ មានន័យថា មានការប្រតិបត្តិមធ្យម

២ មានន័យថា មានការប្រតិបត្តិតិច

១ មានន័យថា មានការប្រតិបត្តិតិចបំផុត

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | | ៥ ច្រើនបំផុត | ៤ ច្រើន | ៣ មធ្យម | ២ តិច | ១ តិចបំផុត |
| | **I. ការដឹកនាំ និងគ្រប់គ្រង** | | | | | |
| ១ | បែងចែកគ្រូទៅតាមឯកទេសវិជ្ជាជីវៈរបស់គ្រូនីមួយៗ | | | | | |
| ២ | គ្រប់គ្រងបុគ្គលិក ម៉ោងចេញ ម៉ោងចូលរបស់គ្រូ និងសិស្ស | | | | | |
| ៣ | មានការប្រជុំបច្ចេកទេសទៀងទាត់លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ៤ | មានការដឹកនាំថ្នាក់និទស្សន៍អភិវឌ្ឍសមត្ថភាពគ្រូលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ៥ | ផ្តល់ឱកាសឱ្យគ្រូអក្សរសាស្ត្រខ្មែរ ទទួលបានការបំប៉នពីវិធីសាស្ត្រថ្មីៗសម្បូរបែប | | | | | |
| ៦ | ត្រួតពិនិត្យគ្រូក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សាលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ៧ | មានកម្មវិធីប្រឡងសិស្សពូកែអក្សរសាស្ត្រខ្មែរ ទាក់ទាញសិស្សចូលប្រឡង | | | | | |
| ៨ | ទទួលបានការបំប៉នពីក្របខណ្ឌកម្មវិធីសិក្សាថ្មី | | | | | |
| ៩ | ផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីដល់គ្រូបង្រៀន | | | | | |
| ១០ | ជំរុញ និងគាំទ្រគ្រូមុខវិជ្ជាអក្សរសាស្ត្រខ្មែរប្រើវិធីសាស្ត្របង្រៀនថ្មីៗ | | | | | |
| ១១ | មានការតាមដានលើការសិក្សារបស់សិស្សជាប្រចាំ | | | | | |
| ១២ | មានការលើកទឹកចិត្តដល់សិស្សរៀនពូកែ | | | | | |
| ១៣ | ផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀន | | | | | |
| ១៤ | រៀបចំថែទាំបរិស្ថាន សោភ័ណភាព និងអនាម័យក្នុងសាលារៀន | | | | | |
| ១៥ | មានកម្មវិធីបំប៉នបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ១៦ | វាយតម្លៃការបង្រៀនរបស់គ្រូ | | | | | |
| ១៧ | មាន LCD និងឧបករណ៍ ICT ផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងពេលបង្រៀន | | | | | |

**II. បញ្ហាប្រឈមរបស់លោក - លោកស្រីចំពោះការបង្រៀន និងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ**

**១. បញ្ហាប្រឈមទី១**

.......................................................................................................................................

.......................................................................................................................................

**២. បញ្ហាប្រឈមទី២**

.......................................................................................................................................

.......................................................................................................................................

**៣. បញ្ហាប្រឈមទី៣**

.......................................................................................................................................

.......................................................................................................................................

**៤. ផ្សេងៗ**

.......................................................................................................................................

| III. ដំណោះស្រាយ ឬវិធានការដោះស្រាយរបស់លោក - លោកស្រីចំពោះបញ្ហាប្រឈមខាងលើនេះ |
| --- |
| ១. ដំណោះស្រាយទី១<br>............................................................<br>............................................................<br>២. ដំណោះស្រាយទី២<br>............................................................<br>............................................................<br>៣. ដំណោះស្រាយទី៣<br>............................................................<br>............................................................<br>៤. ផ្សេងៗ<br>............................................................<br>............................................................<br>............................................................ |

*សូមអរគុណ សម្រាប់ការចូលរួមរបស់លោក - លោកស្រី !*

**ករណីសិក្សា ៖ ខេត្តកំពង់ចាម »**

ខ្ញុំបាទឈ្មោះ **សាម សុនិត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ

សព្វថ្ងៃខ្ញុំបាទជានាយករងនៃវិទ្យាល័យ ហ៊ុន សែន សួន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឥឡូវនេះ ខ្ញុំបាទបាននឹងកំពុងធ្វើការស្រាវជ្រាវមួយក្រោមប្រធានបទ « **ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ករណីសិក្សា ៖ ខេត្តកំពង់ចាម »**

ការស្រាវជ្រាវនេះមានគោលបំណងធំៗចំនួនពីរគឺ៖

**១. សិក្សាពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង បញ្ហាប្រឈម ការបង្រៀន និងការរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២**

**២. សិក្សាពីដំណោះស្រាយ ឬវិធានការដោះស្រាយចំពោះបញ្ហាប្រឈមក្នុងការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ**

**ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន**

**សេចក្ដីណែនាំ៖** សូមលោកគ្រូ - អ្នកគ្រូ គូស " ✓" នៅក្នុងប្រអប់ " ☐ " ខាងក្រោម ៖

**១. ក្របខណ្ឌ**

☐ គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐ គ្រូបង្រៀនកម្រិតឧត្តម

**២. កម្រិតវប្បធម៌**

☐ ទាបជាងបរិញ្ញាបត្រ ☐ បរិញ្ញាបត្រ ☐ ខ្ពស់ជាងបរិញ្ញាបត្រ

**៣. បទពិសោធការងារ**

☐ តិចជាង១០ឆ្នាំ ☐ ១០ឆ្នាំទៅ២០ឆ្នាំ ☐ ច្រើនជាង២០ឆ្នាំ

**ផ្នែកទី២៖ ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ក្នុងខេត្តកំពង់ចាម**

**សេចក្ដីណែនាំ៖** សូមលោកគ្រូ-អ្នកគ្រូ គូស"✓"ទៅតាមការកម្រិតនៃការប្រតិបត្តិតាមការយល់ឃើញរបស់លោកគ្រូ-អ្នកគ្រូ៖

៥ មានន័យថា មានការប្រតិបត្តិច្រើនបំផុត
៤ មានន័យថា មានការប្រតិបត្តិច្រើន
៣ មានន័យថា មានការប្រតិបត្តិមធ្យម
២ មានន័យថា មានការប្រតិបត្តិតិច
១ មានន័យថា មានការប្រតិបត្តិតិចបំផុត

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | | ៥ | ៤ | ៣ | ២ | ១ |

| | I. ដំណើរការនៃការបង្រៀនរបស់គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
|---|---|---|---|---|---|---|
| ១ | មកបង្រៀនបានទៀងទាត់ តាមម៉ោងចេញ និងម៉ោងចូល | | | | | |
| ២ | មានគ្រូអក្សរសាស្ត្រខ្មែរផ្សេងទៀតបង្រៀនជំនួស ពេលលោកគ្រូ អ្នកគ្រូអវត្តមាន | | | | | |
| ៣ | មានកិច្ចតែងការបង្រៀន និងបង្រៀនតាមកិច្ចតែងការបានទៀងទាត់ | | | | | |
| ៤ | បានដាក់កិច្ចការឱ្យសិស្សធ្វើ និងបានកែកិច្ចការសិស្សជាប្រចាំ | | | | | |
| ៥ | បានវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំក្នុងពេល ឬក្រោយបង្រៀនចប់មេរៀន | | | | | |
| ៦ | បានផ្តល់សៀវភៅតាមដានការសិក្សាសិស្សដល់អាណាព្យាបាលសិស្ស | | | | | |
| ៧ | បានផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន | | | | | |
| ៨ | បានប្រើប្រាស់សម្ភារៈឧបទេសក្នុងពេលបង្រៀន | | | | | |
| ៩ | ធ្លាប់ទទួលបានការធ្វើអធិការកិច្ចថ្នាក់រៀនពីគណៈគ្រប់គ្រងសាលារៀន | | | | | |
| ១០ | ធ្លាប់ទទួលបានការផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីសិក្សាថ្មីរបស់ក្រសួង | | | | | |
| ១១ | មានភាពលម្អៀងចំពោះសិស្សក្នុងពេលបង្រៀន | | | | | |
| ១២ | បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបរិះរក (IBL) ក្នុងពេលបង្រៀន | | | | | |
| ១៣ | បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបបញ្ញត្តិ (CBL) ក្នុងពេលបង្រៀន | | | | | |
| ១៤ | បានប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងពេលបង្រៀន | | | | | |
| ១៥ | បានប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌលក្នុងពេលបង្រៀន | | | | | |
| ១៦ | បានបង្រៀនតាមកាលវិភាគដែលគណៈគ្រប់គ្រងបានកំណត់ | | | | | |
| ១៧ | បានបង្រៀនចប់តាមកម្មវិធីសិក្សាដែលក្រសួងបានកំណត់ | | | | | |

**II. បញ្ហាប្រឈមរបស់លោកគ្រូ- អ្នកគ្រូចំពោះការបង្រៀន និងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ**

**១. បញ្ហាប្រឈមទី១**

..................................................................................................................................................

..................................................................................................................................................

**២. បញ្ហាប្រឈមទី២**

..................................................................................................................................................

..................................................................................................................................................

**៣. បញ្ហាប្រឈមទី៣**

..................................................................................................................................................

..................................................................................................................................................

**៤. ផ្សេងៗ**

..................................................................................................................................................

**III. ដំណោះស្រាយ ឬវិធានការដោះស្រាយរបស់លោកគ្រូ - អ្នកគ្រូចំពោះបញ្ហាប្រឈមខាងលើនេះ**

| |
|---|
| ១. ដំណោះស្រាយទី១<br>.................................................................................................................................................<br><br>.................................................................................................................................................<br>២. ដំណោះស្រាយទី២<br>.................................................................................................................................................<br><br>.................................................................................................................................................<br>៣. ដំណោះស្រាយទី៣<br>.................................................................................................................................................<br><br>.................................................................................................................................................<br>៤. ផ្សេងៗ<br>.................................................................................................................................................<br><br>.................................................................................................................................................<br><br>................................................................................................................................................. |

*សូមអរគុណ សម្រាប់ការចូលរួមរបស់លោកគ្រូ - អ្នកគ្រូ !*

# គម្រូវសំណួរសម្រាប់សិស្ស

# វិទ្យាល័យ .............................. ថ្នាក់ទី១២ ........

☐ ថ្នាក់វិទ្យាសាស្ត្រ ☐ ថ្នាក់វិទ្យាសាស្ត្រសង្គម

**ប្រធានបទស្រាវជ្រាវ៖ « ស្ថានភាពនៃការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ករណីសិក្សា ៖ ខេត្តកំពង់ចាម »**

ខ្ញុំបាទឈ្មោះ **សាម សុនិត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ

សព្វថ្ងៃខ្ញុំបាទជានាយករងនៃវិទ្យាល័យ ហ៊ុន សែន សួន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឥឡូវនេះ ខ្ញុំបាទបាននឹងកំពុងធ្វើការស្រាវជ្រាវមួយ ក្រោមប្រធានបទ **« ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី១២ ករណីសិក្សា ៖ ខេត្តកំពង់ចាម »**

ការស្រាវជ្រាវនេះមានគោលបំណងធំៗចំនួនពីរគឺ៖

**១. សិក្សាពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង បញ្ហាប្រឈម ការបង្រៀន និងការរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២**

**២. សិក្សាពីដំណោះស្រាយ ឬវិធានការដោះស្រាយចំពោះបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរ**

**សេចក្តីណែនាំ៖**

សូមប្អូនៗ គូស " ✓" ទៅតាមការកម្រិតនៃការប្រតិបត្តិតាមការយល់ឃើញរបស់ប្អូនៗ ៖

៥ មានន័យថា មានការប្រតិបត្តិច្រើនបំផុត

៤ មានន័យថា មានការប្រតិបត្តិច្រើន

៣ មានន័យថា មានការប្រតិបត្តិមធ្យម

២ មានន័យថា មានការប្រតិបត្តិតិច

១ មានន័យថា មានការប្រតិបត្តិតិចបំផុត

| លេខរៀង | ស្ថានភាពនៃការបង្រៀន និងរៀន អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | **I. ដំណើរការនៃការរៀនរបស់សិស្សានុសិស្សថ្នាក់ទី១២** | ៥ ច្រើនបំផុត | ៤ ច្រើន | ៣ មធ្យម | ២ តិច | ១ តិចបំផុត |
| ១ | មករៀនបានទៀងទាត់ ពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ២ | ចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ៣ | បង្កើតក្លឹបសិក្សាដោយខ្លួនឯង និងធ្វើឱ្យក្លឹបសិក្សាមានដំណើរការល្អ | | | | | |
| ៤ | បានធ្វើកិច្ចការដែលគ្រូបានដាក់ឱ្យ និងបានទទួលការកែលម្អពីគ្រូជាប្រចាំ | | | | | |
| ៥ | ចូលរួមក្នុងការវាយតម្លៃលទ្ធផលសិក្សាក្នុងពេលរៀន ឬក្រោយពេលរៀនមេរៀនចប់ | | | | | |
| ៦ | បានទទួលសៀវភៅតាមដានការសិក្សាពីគ្រូបង្រៀន បានទៀងទាត់ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | មានភាពក្លាហានក្នុងការឆ្លើយសំណួររបស់គ្រូ | | | | | |
| ៨ | សហការគ្នាពិភាក្សាជាក្រុម ក្នុងពេលរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ៩ | បានជួយមិត្តភក្តិពេលម៉ោងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ១០ | យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ពេលម៉ោងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ១១ | រៀនគួរបន្ថែមលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ | | | | | |
| ១២ | ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបរិះរក (IBL) | | | | | |
| ១៣ | ធ្លាប់បានទទួលការបង្រៀនតាមវិធីសាស្ត្របែបបញ្ញត្តិ (CBL) | | | | | |
| ១៤ | ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល | | | | | |
| ១៥ | ធ្លាប់បានទទួលការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល | | | | | |

**II. បញ្ហាប្រឈមរបស់ប្អូនៗ ចំពោះការបង្រៀន និងរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ**

១. បញ្ហាប្រឈមទី១

..........................................................................................................................................

..........................................................................................................................................

២. បញ្ហាប្រឈមទី២

..........................................................................................................................................

..........................................................................................................................................

៣. បញ្ហាប្រឈមទី៣

..........................................................................................................................................

..........................................................................................................................................

៤. ផ្សេងៗ

..........................................................................................................................................

**III. ដំណោះស្រាយ ឬវិធានការដោះស្រាយរបស់ប្អូនៗ ចំពោះបញ្ហាប្រឈមខាងលើនេះ**

១. ដំណោះស្រាយទី១

..........................................................................................................................................

..........................................................................................................................................

២. ដំណោះស្រាយទី២

..........................................................................................................................................

..........................................................................................................................................

៣. ដំណោះស្រាយទី៣

..........................................................................................................................................

| | |
|---|---|
| ........................................................................................................................................................<br>៤. ផ្សេងៗ<br>........................................................................................................................................................<br><br>........................................................................................................................................................<br><br>........................................................................................................................................................ | |

*សូមអរគុណ សម្រាប់ការចូលរួមរបស់ប្អូនៗ ជាសិស្សានុសិស្ស !*

# ឧបសម្ព័ន្ធទី ២